**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Driot et des Sciences Economiques

ROYAL UNIVERSITY OF LAW AND ECONOMICS

## សារណាបញ្ចប់ការសិក្សា

# ការបង្កើត ការអនុវត្តន៍ និង ការត្រួតពិនិត្យថវិការដ្ឋ

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ច័ន្ទ ទីន**

**បេត នីតា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **វ័ន្ត ទីន** និង **បេត នីតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ក្រុម L4C4ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០២២ ។

**សូមគោរពថ្លែងអំណរគុណនិងសម្តែងនូវកតញ្ញូតាធម៌ការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

**លោកឪពុក អ្នកម្តាយ** ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេង ដែលមិនអាចកាត់ថ្លៃបាន លោកទាំងពីរបានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាតាំងពីនៅក្នុងផ្ទៃនៅឡើយទំនុកបំរុងប្រកបដោយព្រហ្មវិហារធម៌ ទូន្មានប្រៀនប្រដៅដាស់តឿនកូនឱ្យប្រព្រឹត្តល្អរាប់អានមិត្តភក្តិរហូតកូនបានធំដឹងក្តី។ ម៉្យាងទៀតលោកផ្គត់ផ្គង់ ជ្រោមជ្រែងឧបត្ថម្ភទាំងសម្ភារៈសិក្សា និងបានតស៊ូខិតខំធ្វើការទាំងថ្ងៃក្តៅថ្ងៃរងារត្រជាក់ដើម្បីបានថវិកាជំរុញលើកទឹកចិត្តអោយកូនបានសិក្សាតាំងពីថ្នាក់មត្តេយ្យរហូតដល់កូនបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងក្លាយជាធនធាមនុស្សដ៏ល្អ ប្រកបដោយ សីលធម៌ គុណធម៌ មួយដែលសង្គមមិនអាចខ្វះបាន។ កូនសូមបួងសួងដល់វត្ថុសក្តិសិទ្ធតាមថែរក្សាលោកទាំងពីរអោយប្រកបតែសេចក្តីសុខ សុខភាពរឹងមាំ។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំង**សាកលវិទ្យាធិការង គណៈកម្មការ ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ** ដែលបានយកចិត្តទុកដាក់ទដោយទំនួលខុសត្រូវយ៉ាងខ្ពង់ខ្ពស់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាន់ ប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងទទួលបានពុទ្ធិច្បាស់លាស់ក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្សដើម្បីក្លាយជាសរសរទ្រូងរបស់ជាតិ។

**លោកគ្រូសាស្ត្រាចារ្យបណ្ឌិត ទេព សុខ** ដែលជាសាស្ត្រាចារ្យណែនាំយើងខ្ញុំទាំងពីរនាក់ក្នុងការសរសេរសារណាផ្តល់ជាគំនិតទ្រឹស្តី និងការអនុវត្ត ក្នុងការសិក្សាស្វែងយល់វិធីសាស្ត្រល្អៗ ជួយកែសម្រួលផ្តល់បទពិសោធន៍ដ៏មានគុណតម្លៃដោយគ្មានការលាក់លៀមប្រកបដោយស្នាមញញឹមមិនអ៊្រូទាំ នឿយហត់ ឬមានការធុញទ្រាន់ចំពោះការផ្តល់នូវគំនិតយោបល់អ្វីឡើយ ថែមទាំងមានសេចក្តីស្រឡាញ់ចំពោះនិស្សិតរហូតដល់សារណាបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមគោរពប្រសិទ្ធពរជ័យសិរីសួរស្តី វិបុលសុខ បវរ ដ៏ប្រសើរដល់ **ឯកឧត្តម លោកជំទាវ ជាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិក** ដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់អោយទទួលបានសុខភាពល្អ សំណាងល្អ សុភមង្គលក្នុងគ្រួសារជោគជ័យគ្រប់ភារៈកិច្ច ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីខាន។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំទី៤ ថ្នាក់L4C4 នៃឆ្នាំសិក្សា ២០២១-២០២២ យើងមានសេចក្តីសោមនស្សរីករាយ បន្ទាប់ពីយើងខ្ញុំបាននិងកំពុងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយការចងក្រងនូវសារណាដ៏សំខាន់មួយក្រោមប្រធានបទ"**ការបង្កើត ការអនុវត្តន៍ និងការត្រួតពិនិត្យថវិការជ្ជ**" សារណាបញ្ចប់ការសិក្សាជំនាញនីតិសាស្ត្រនៅចំពោះមុខនេះ គឺជាសមិទ្ធិផលដែលកើតចេញពីការខិតខំប្រឹងប្រែងស្រាវជ្រាវចងក្រងដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានាដែលជាការរួមចំណែកមួយ ដើម្បីផ្សព្វផ្សាយចែករំលែកនូវចំណេះដឹង និងបង្ហាញអោយយើងបានយល់ពីការរៀបចំ នៃការបង្កើត ការអនុវត្តន៍ និងការត្រួតពិនិត្យថវិការជ្ជនាពេលបច្ចុប្បន្ន។ ទាំងនេះជាការចែករំលែកចំណេះដឹងពុទ្ធិ និងទស្សនៈទានសំខាន់ៗ ជូនដល់ពលរដ្ឋ សិស្សនិស្សិតអោយកាន់តែជ្រាបច្បាស់បន្ថែមទៀត។ អស់រយៈពេល៤ឆ្នាំ កន្លងមកនេះ យើងខ្ញុំបានក្រេបជញ្ជក់ និងទទួលបាននូវពុទ្ធិ ក៏ដូចជាចំណេះដឹង បទពិសោធន៍ជាច្រើន ទាក់ទងនឹងវិស័យច្បាប់ និងចំណេះដឹងទូទៅផ្សេងៗមួយចំនួនទៀត។ ទន្ទឹមនិងនេះ យើងខ្ញុំបានចាត់ទុកសាលាជាភូមិកំណើតដែលជាថ្នាលបង្កើតគំនិត ពីព្រោះសាលាមិនត្រឹមតែផ្តល់នូវចំណេះដឹងដល់យើងប៉ុណ្ណោះទេ ប៉ុន្តែផ្តល់ជាគុណធម៌និងសីលធម៌ដល់យើងខ្ញុំហើយធ្វើអោយខ្ញុំប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវវិន័យជាប់ប្រាណជានិច្ច។

ម៉្យាងវិញទៀតប្រទេសកម្ពុជាប្រទេសដែលប្រកាន់យករបបទីផ្សារសេរី ហើយក៏ជាប្រទេសកំពុងអភិវឌ្ឍន៍ ដូចនេះហើយធ្វើអោយប្រទេសកម្ពុជាមានការនាំចេញនាំចូលច្រើន មានការប្រកួតប្រជែងនៃវិស័យជាច្រើនដែលកំពុងកើតមានឡើង។

ទោះបីជាខ្លឹមសារទាំងស្រុងក្នុងសារណាមានការត្រួតពិនិត្យយកចិត្តទុកដាក់យ៉ាងណាក្តី យើងខ្ញុំយល់ថាវាចារអត្ថបទនេះនៅតែមានន័យមិនពេញលេញឬអាចខុសនូវអក្ខរាវិរុទ្ធខ្លះ នាងខ្ញុំរង់ចាំទទួលការរិះគន់ស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តអ្នកអាន អ្នកស្រាវជ្រាវ វាយតម្លៃអត្ថបទសារណានេះ នូវរាល់កំហុសឆ្គងទាំងឡាយណាដែលកើតឡើងដោយអចេតនានៃការសរសេរពាក្យពេជនច៍ វគ្គឃ្លា វេយ្យាករណ៍ ដើម្បីចូលរួមជួយកែលំអរអោយសៀវភៅនេះកាន់តែប្រសើរជាងនេះទៀត។

យើងខ្ញុំសូមជូនពរ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យមិត្តអ្នកអាន អ្នកស្រាវជ្រាវ និង មិត្តនិស្សិតទាំងអស់ ទទួលបាននៅភាពជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១ ទិដ្ឋភាពទូទៅនៃនីតិថវិកា**

**ផ្នែកទី១ សញ្ញាណទូទៅនៃនីតិថវិកា**........................................ ៤

១.១ និយមន័យ........................................................ ៤

១.២ លក្ខណៈពិសេសនៃថវិការដ្ឋ ........................................ ៥

១.៣ ប្រវត្តិនៃការកកើត........................................................ ៦

១.៣.១ បាតុភូតធម្មនុញ្ញ ........................................................ ៦

១.៣.២ បាតុភូតនយោបាយ ........................................................ ៦

១.៣.៣ បាតុភូតសេដ្ឋកិច្ច........................................................ ៧

១.៣.៤ បាតុភូតសង្គម........................................................ ៧

**ផ្នែកទី២ ការបែងចែកចំណាត់ថ្នាក់មុខងាររចនាសម្ព័ន្ធនៃថវិកា** ........................ ៧

២.១ ការរៀបចំវិធានក្នុងថវិការដ្ឋ ........................................ ៧

២.១.១ ថវិកាទូទៅរបស់រដ្ឋ........................................................ ៨

២.១.២ ថវិកាឧបសម្ព័ន្ធ........................................................ ៨

២.១.៣ ថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល........................................ ៩

២.១.៤ គណនីពិសេសរបស់រតនាគារ ........................................ ៩

២.២ ឯករាជ្យភាពហិរញ្ញវត្ថុបំភាន់ផ្នែក ........................................ ១១

២.២.១ ការបែងចែកចំណាយស្ថាពរ និងចំណាយបណ្តោះអាសន្ន........................ ១១

២.២.២ ការបែងចែករវាងសេវាអនុម័ត និងវិធានការថ្មី ........................ ១២

២.២.២.១ សេវាអនុម័ត  នឹងវិធានការថ្មី........................................ ១២

២.២.២.២ អត្ថប្រយោជន៍នៃការបែកចែកឥណទានជាពីរផ្នែក ........................ ១៣

២.៣ មាតិកាថវិកា........................................................ ១៣

២.៣.១ ប្រភេទចំណាយនៃថវិការដ្ឋ ........................................ ១៣

២.៣.១.១ មធ្យោបាយសេវាកម្ម ........ ១៤
២.៣.២ ប្រភេទចំណូលនៃថវិការដ្ឋ ........ ១៥
២.៣.២.១ ប្រភេទចំណូល ........ ១៥
២.៣.២.២ ធាតុផ្សំនៃចំណូល ........ ២១

**ជំពូកទី២ នីតិវិធីនៃការរៀបចំ ការអនុម័ត និងការអនុវត្តន៍ថវិកា**

**ផ្នែកទី១ ដំណើរការនៃនីតិវិធីនៃការរៀបចំ ការអនុម័តថវិកា** ........ ២៣
១.១ នីតិវិធីនៃការរៀបចំថវិកា ........ ២៣
១.១.១ អង្គការមានសមត្ថកិច្ច ........ ២៣
១.១.២ ការប៉ាន់ស្មានចំណូល ........ ២៤
១.១.៣ ការប៉ាន់ស្មានចំណាយ ........ ២៧
១.២ បរិបទ និងប្រតិទិននៃការរៀបចំថវិកានៅកម្ពុជា ........ ៣១
១.២.១ ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា(មិនា-ឧសភា) ........ ៣១
១.២.២ ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា(មិថុនា-កញ្ញា) ........ ៣១
១.២.៣ ការអនុម័តថវិកា (តុលា-ធ្នូ) ........ ៣២
១.៣ នីតិវិធីនៃការអនុម័តថវិកាប្រចាំឆ្នាំ ........ ៣២
១.៣.១ នីតិវិធីធម្មតា ........ ៣២
១.៣.២ នីតិវិធីពិសេសក្នុងការអនុម័តថវិកា ........ ៣២
១.៣.៣ ករណីច្បាប់ខ្មែរក្នុងការអនុម័តថវិកា ........ ៣៣
**ផ្នែកទី២ ដំណាក់កាលនៃការអនុវត្តថវិកា** ........ ៣៤
២.១ មុខងារអាណាប័ក ........ ៣៤
២.២ មុខងារគណនេយ្យករ ........ ៣៥
២.៣ មុខងារមន្រ្តីអភិបាលហិរញ្ញវត្ថុ ........ ៣៥

## ជំពូកទី៣ ការត្រួតពិនិត្យលើការអនុវត្តថវិកា និង ទណ្ឌកម្ម ចំពោះ បទល្មើសផ្សេងៗ

**ផ្នែកទី១ ការត្រួតពិនិត្យលើការអនុវត្តថវិកា** .................................................... ៣៦

១.១ ការត្រួតពិនិត្យតាមបែបរដ្ឋបាល .................................................... ៣៦

១.១.១ ការត្រួតពិនិត្យដោយហានានុក្រម .................................................... ៣៦

១.១.២ ការត្រួតពិនិត្យលើអាណាប័កដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .................................................... ៣៧

១.១.៣ ការត្រួតពិនិត្យអភិបាលហិរញ្ញវត្ថុ .................................................... ៣៧

១.២ ការត្រួតពិនិត្យរបស់សភា .................................................... ៣៨

១.២.១ការត្រួតពិនិត្យថវិកាពេលកំពុងអនុវត្ត .................................................... ៣៨

១.២.២ ការត្រួតពិនិត្យថវិកាក្រោយពេលអនុវត្ត .................................................... ៣៩

១.៣ ការត្រួតពិនិត្យរបស់អាជ្ញាធរសវនកម្មជាតិ .................................................... ៣៩

១.៣.១ កម្មវត្ថុនៃការត្រួតពិនិត្យ .................................................... ៣៩

១.៣.២ ការត្រួតពិនិត្យថវិកាលើរដ្ឋាភិបាលលើអាជ្ញាធសវនកម្មជាតិ .................................................... ៤០

១.៣.៣ សមត្ថកិច្ចក្នុងការធ្វើសវនកម្មលើអាជ្ញាធរសវនកម្មជាតិ .................................................... ៤១

**ផ្នែកទី២ បទល្មើសក្នុងច្បាប់ថវិកា និងទណ្ឌកម្ម** .................................................... ៤១

២.១ បទល្មើសក្នុងច្បាប់ថវិកា .................................................... ៤១

២.១.១ ការទទួលខុសត្រូវរបស់គណនេយ្យករ .................................................... ៤២

២.១.២ ការទទួលខុសត្រូវរបស់របស់អាណាប័ក .................................................... ៤៣

២.២ ទណ្ឌកម្មក្នុងច្បាប់ថវិកា .................................................... ៤៤

**២.២.១ ទោសបញ្ញត្តិ** .................................................... ៤៤

**សេចក្ដីសន្និដ្ឋាន** .................................................... ៤៥

**អនុសាសន៍** .................................................... ៤៧

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងសកលលោកទាំងមូលយើងនេះការអនុវត្តថវិកាជាកត្តាចម្បងដែលជំរុញគម្រោង និងបេសកម្មទាំងអស់របស់អង្គភាពទាំងឡាយ អាចដំណើរការបានល្អជាងមុនដោយរលូនគ្រប់រចនាសម្ព័ន្ធរាប់ទាំងអង្គភាព ឬ ឯកជន រួមទាំងវិស័យសាធារណៈជាដើម។ មានអំណះអំណាងជាច្រើនបញ្ជាក់ថាការបង្កើត ការអនុវត្តន៍ និងការត្រួតពិនិត្យថវិការដ្ឋពិតជាមិនអាចខ្វះបាន និងមានសារៈសំខាន់ក្នុងដំណើរការ ការងារអោយដើរទៅរលូនជាងមុនប្រកបដោយប្រសិទ្ធភាព។ ការរៀបចំដំណើរការថវិកាឱ្យបានត្រឹមត្រូវប្រាកដប្រជាមានតម្លាភាពអាចធ្វើអោយដំណើរការងារ គម្រោងការងារ បេសកម្មទាំងមូលដំណើរការទៅច្បាស់លាស់។ ថវិកាបានបម្រើក្នុងវិស័យឯកជននិងបម្រើដល់ប្រយោជន៍សាធារណៈរួមមានចំណាយធំៗលើវិស័យតុលាការ ការពារជាតិសន្តិសុខជាដើម។ ការគិតពីចំណាយ រដ្ឋត្រូវគិតគូពីប្រភពចំណូលដើម្បីអាចដឹងពីលទ្ធភាពចំណាយលើសចំណូលរបស់ខ្លួន។ ថវិកាមានលក្ខណៈបត់បែនទៅតាមស្ថានភាពជាក់ស្តែងព្រោះចំណូល និងចំណាយអង្គភាពមួយមានការចូល និងចេញមិនច្បាស់លាស់ពីមួយថ្ងៃទៅមួយថ្ងៃ ឬ មួយខែទៅមួយខែ ឬ ពីមួយឆ្នាំទៅមួយឆ្នាំ ដូចចំណូល ឬ ចំណាយអាចមានការប្រែប្រួលតាមពេលវេលា។ ដោយមានការផ្លាស់ប្តូរបត់បែនដូច្នេះ ទើបត្រូវការជាចាំបាច់អ្នកទទួលខុសត្រូវក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ រាល់ពេលនៃដំណើរការថវិកាអោយបានល្អប្រសើរសុក្រឹត្យភាពជារៀងរាល់ឆ្នាំ។

ជាក់ស្តែងបើយើងងាកទៅមើលក្នុងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់គោលដៅរួមនៃការប្រមូលចំណូលដោយបានដាក់ចេញនូវវិធានការចាំបាច់ដែលត្រូវអនុវត្តក្នុងឆ្នាំ ២០២២-២០២៤ ដើម្បីសម្រេចគោលដៅទាំងនេះរដ្ឋាភិបាលបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោលនយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួម។ នៅបច្ចុប្បន្នថវិកាដើរតួនាទីសំខាន់ក្នុងការពិពណ៌នាសម្រាប់ឆ្នាំនីមួយៗ ដែលព្យាករណ៍អនុវត្តចំណូលចំណាយឱ្យប្រមូលចំណូលរបស់រដ្ឋមិនថាវិស័យឯកជន ឬ វិស័យសាធារណៈ ឬ តាមក្រសួងស្ថាប័ននានាសម្រាប់គ្រោងនៃសកម្មភាពបុគ្គល សហគ្រាស អង្គភាពសាធារណៈ និងរដ្ឋសុទ្ធតែបង្កើតនៅកម្មវិធីហិរញ្ញវត្ថុចាំបាច់ត្រូវតែមានការបង្វិលទៅបង្វិលមក សម្រាប់គ្រោងចំណូលចំណាយថវិកា ការកើន ឬ ការថយចុះ ដែលត្រូវអនុវត្ត។ ជាពិសេសថវិកាជាតិ ជួយបញ្ជាក់គ្រប់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់ ក្នុងការគ្រប់គ្រងពីប្រាក់ចំណូលដែលគេរកបានគិតគូរយ៉ាងហ្មត់ចត់ ដោយចាត់ចែងប្រាក់ចំណូលទាំងនេះដោយប្រុងប្រយ័ត្ន ដើម្បីធ្វើយ៉ាងណាឱ្យមានស្ថេរភាពជានិរន្តរ៍។ មិនតែប៉ុណ្ណោះបានជួយសម្រួលបើកថវិកាប្រចាំខែគ្រប់បុគ្គលិក ជូនមន្ត្រីរាជការ ផ្នែកសាធារណៈសម្រាប់ផ្នែករដ្ឋបាល ផ្នែកស៊ីវិល ដែលកំពុងបំពេញភារកិច្ច ក្រៅពីនេះថវិការដ្ឋក៏មានមធ្យបាយហិរញ្ញវត្ថុសម្រាប់ចំណាយកសាង មន្ទីរពេទ្យ សាលារៀន រៀបចំអាគារសាធារណៈដោយមិនរកប្រាក់ចំណេញ ។ ទោះបីជាមានការ

អនុវត្តន៍ និងការត្រួតពិនិត្យថវិកា ឱ្យបានត្រឹមត្រូវមិនថាតាមស្ថាប័នតូចធំ បណ្តាវិស័យឯកជន ឬសាធារណៈតែងតែជួបបញ្ហាប្រឈម ទោះបីជាមានបញ្ហាខ្លះក៏ដោយ ក៏ការអនុវត្ត ការត្រួតពិនិត្យថវិការដ្ឋនេះតែងទទួលបានលទ្ធផលសមស្របរហូតមក។

នៅក្នុងប្រធានបទនៃកិច្ចការស្រាវជ្រាវនេះក្រុមយើងខ្ញុំមានគោលបំណងចំនួនបីគឺៈ

គោលបំណងទី១ ការពិពណ៌នាអំពីលក្ខណៈពិសេសនៃដំណើរការថវិកាជាតិនៅកម្ពុជា ដែលពាក់ព័ន្ធនិងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសារធារណៈដែរជាច្បាប់បញ្ជាក់យ៉ាងលំអិតអំពីថវិកាជាតិទាំងមូល។

គោលបំណងទី២ ស្វែងយល់អំពីអង្គភាពឬស្ថាប័នដែលមានកាតព្វកិច្ចក្នុងការរៀបចំនូវការគ្រប់គ្រងដូចជា ការប៉ាន់ស្មាន ចំណូល ចំណាយ នីតិវិធីនៃការរៀបចំថវិកា ព្រមទាំងការអនុម័តនៅចរន្តថវិកាជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងធ្វើអោយថវិកាជាតិមានភាពប្រសើរឡើង និងជៀសពីការប្រឈមនិងការបាត់ចំណូលចរន្តថវិកាជាតិកម្ពុជា ព្រមទាំងវិធីសាស្ត្រដែលរដ្ឋាភិបាលបានប្រើប្រាស់អំឡុងពេលប្រទេសជាតិជួបវិបត្តិ កូវីត-១៩ ។

គោលបំណងទី៣ ស្វែងយល់បទដ្ឋានគតិយុត្តដែលមានក្នុងដំណើរការត្រួតពិនិត្យលើ ការអនុវត្ត ការអនុម័ត ទណ្ឌកម្មចំពោះបទល្មើស និងការទទួលខុសត្រូវរបស់រដ្ឋ។

សិក្សាស្រាវជ្រាវប្រធានបទស្តីអំពីការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជាពិតជាមានសារៈសំខាន់ណាស់ ចំពោះយើងខ្ញុំមិនត្រឹមតែផ្តល់ការយល់ដឹងកាន់តែច្បាស់ពីដំណើរការរៀបចំ ក្នុងការបង្កើត ការអនុវត្ត និងត្រួតពិនិត្យប៉ុណ្ណោះទេ ថែមទាំងបង្ហាញពីគុណតម្លៃ និងបញ្ហាប្រឈមនានាអោយយើងខ្ញុំចេះរៀបចំទុកជាមុន ដើម្បីការពារ និងអាចដោះស្រាយបញ្ហាទាំងនោះបានទាន់ពេលវេលាផងដែរ។

ការស្រាវជ្រាវនេះក្រុមយើងខ្ញុំផ្តោតសំខាន់លើនីតិវិធីនៃការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យថវិកាជាតិជាមួយស្ថាប័ន ឬ ក្រសួងដែលពាក់ព័ន្ធនានារួមទាំងតួនាទីភារកិច្ចរបស់រដ្ឋាភិបាលផងដែរ។ ដោយក្រុមយើងខ្ញុំបង្ហាញពីលើគន្លឹះសំខាន់ៗនៃ ការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យថវិកាជាតិទាំងមូលចាប់តាំងពីការប្រមូលថវិការហូតដល់ការចំណាយថវិកា ដោយរួមទាំងបទដ្ឋានគតិយុទ្ធដែលមានចែងនៅក្នុង ច្បាប់ អនុក្រឹត្យ សារាចរជាដើម។ ការសិក្សាស្រាវជ្រាវនេះក៏បានលើកយកស្ថានភាពជាក់ស្តែងដែលមាននៅក្នុងដំណើរការថវិការដ្ឋមកបង្ហាញជាឧទាហរណ៍ទៅលើច្បាប់និង បញ្ញាតិដែលបានចែង។

នៅក្នុងសារណានេះបានផ្តោតសំខាន់លើការបង្កើត ការអនុវត្តន៍ និង ការត្រួតពិនិត្យថវិការដ្ឋ ដែលបានអនុវត្តនាពេលកន្លងមក និងបានចោទឡើងនូវសំនួរ **និងបញ្ហាគតិយុត្តជាច្រើនថា តើអ្វីទៅជាថវិកា?**

**កត្តាអ្វីខ្លះដែលនាំអោយមានការបង្កើតនីតិថវិកានេះឡើង? តើស្ថាប័នណាខ្លះជាអ្នកបង្កើត និងត្រួតពិនិត្យអនុវត្តនីតិថវិកានេះ?**

នៅក្នុងកិច្ចការស្រាវជ្រាវលើប្រធានបទនេះ ក្រុមយើងខ្ញុំបានលើកយកឯកសារគតិយុត្តនានាពីគ្រប់ប្រភពពាក់ព័ន្ធទាំងអស់ដើម្បីធ្វើជាអំណះអំណាង។

ដើម្បីងាយស្រួលយល់ក្នុងការបកស្រាយប្រធានបទនេះ ព្រមទាំងឆ្លើយតបបញ្ហាគតិយុត្តខាងលើ យើងខ្ញុំបានរៀបចំរចនាសម្ព័ន្ធជាបីជំពូកធំៗគឺៈ

ជំពូកទី១ៈ និយាយពី និយមន័យថវិការដ្ឋ បាតុភូតដែលនាំឱ្យកើតនីតិថវិកា ការបែងចែកចំណាត់ថ្នាក់ មុខងាររចនាសម្ព័ន្ធនៃថវិកា និង មាតិកាថវិកា។

ជំពូកទី២ៈ បានលើកឡើងពី នីតិវិធីនៃការរៀបចំថវិកា បរិបទ និងប្រតិទិននៃការរៀបចំថវិកា នីតិវិធីនៃការអនុម័តប្រចាំឆ្នាំ ដំណាកាលនៃការអនុវត្តថវិកា។

ជំពូកទី៣ៈ ការត្រួតពិនិត្យលើការអនុវត្តថវិកាមាន ការត្រួតពិនិត្យតាមបែបរដ្ឋបាល ការត្រួតរបស់សភា ការត្រួតពិនិត្យរបស់អាជ្ញាធរសវនកម្មជាតិ បទល្មើសក្នុងច្បាប់ថវិកា និងការដាក់ទណ្ឌកម្ម។

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃនីតិថវិកា

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃនីតិថវិកា

## ផ្នែកទី១៖ សញ្ញាណទូទៅនៃនីតិថវិកា

### ១.១ និយមន័យ

**ថវិកា** គឺជាលិតតូបករណ៍ហិរញ្ញវត្ថុ និងគណនេយ្យដែលមានលក្ខណៈ ជាទម្រង់គតិយុត្តមួយប៉ុណ្ណោះ។ និយមន័យម្យ៉ាងទៀត ជាកិច្ចការដែលព្យាករណ៍ និងអនុវត្តចំណូលនិងចំណាយរបស់រដ្ឋ។ ថវិកា សំដៅសំណុំគណនេយ្យដែលពណ៌នាសម្រាប់ឆ្នាំនីមួយៗ អំពីធនធានអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ឬរបស់ស្ថាប័ន ឬអង្គភាពណាមួយ។[1]

បើនិយមន័យតាមច្បាប់បារាំងមានន័យពីរយ៉ាង គឺនិយមន័យមានលក្ខណៈជាទម្រង់ និងសំភារៈជាលក្ខណៈជាទម្រង់ថវិកា គឺជាកិច្ចការដែកព្យាករណ៍ និងអនុញ្ញាតចំណូលនិងចំណាយរបស់អង្គការសាធារណៈ (រដ្ឋសមូហភាពមូលដ្ឋានគ្រឹស្ថានសាធារណៈរដ្ឋបាលនិងគ្រឹស្ថានសាធារណៈទាំងអស់ ដែលមានលក្ខណៈជាឧស្សាហកម្ម ដែលមានភ្នាក់ងារជាគណនេយ្យ)។ និយមន័យតាមសំភារៈ ថវិកា គឺជាការរាល់បញ្ចូលចំណាយ និងចំណូលដែលត្រូវអនុញ្ញាតហើយសម្រេចឡើង សម្រាប់រយៈពេលពីរឆ្នាំ។ ថវិកាជាលិខិតគតិយុត្តិដែលបានគ្រោងនឹងគ្រោង និង បានអនុញ្ញាតឱ្យប្រមូលចំណូល និង បែងចែកចំណាយប្រចាំឆ្នាំរបស់រដ្ឋ។ ថវិកាជាគណនេយ្យមួយដែលប្រមូលផ្តុំចំណូល និងចំណាយទាំងអស់ ក្នុងមួយឆ្នាំ ហើយដែលសភាដែលនឹងអនុម័ត ឱ្យអនុវត្ត។ ម្យ៉ាងទៀតបើយោងតាមនិយមន័យបែប ពហិលក្ខណៈ ថវិកាគឺជាឯកសារ មួយដែលចែងអំពីការគ្រោងទុក និង អនុញ្ញាតស្តីពីចំណាយ និង ចំណូលនៃអង្គការសាធារណៈ។ ដូចច្នេះនេះគឺជានិយមន័យបែបសម័យជំនាន់មុន ដែលបទបទបញ្ញាទូទៅស្តីពីគណនេយ្យសាធារណៈដែលបានយកមកអនុវត្តដូចគ្នា។ ចំពោះអង្គការសាធារណៈ គេចង់និយាយពីរដ្ឋ ពីសមូហភាពដែនដី ពីគ្រឹស្ថានរដ្ឋបាលសាធារណៈ និងគ្រឹស្ថានសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។[2] ថវិការដ្ឋ គឺមានន័យជាថវិការបស់រដ្ឋ ដោយមិនរាប់បញ្ចូលថវិការបស់ ដែលសមូហភាពសាធារណៈឯទៀត ដូចជាសមូហភាពដែនដី ឬគ្រឹះស្ថានសាធារណៈខ្លះដែលគ្រប់គ្រងដោយគណនីរដ្ឋមក។ គេច្រើនអោយឈ្មោះថាច្បាប់ហិរញ្ញវត្ថុ។ ច្បាប់ហិរញ្ញវត្ថុ ជាច្បាប់ដែលសភាបានត្រួតពិនិត្យ និងអនុម័តតាមការស្នើសុំរបស់រដ្ឋាភិបាល។ ច្បាប់នេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់ការប្រើប្រាស់នៃធនធាន និង បន្ទុកផ្សេងៗរបស់រដ្ឋដោយអនុលោមទៅតាមក្របខណ្ឌសមតាមសេដ្ឋកិច្ច

[1] មាត្រា ៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ ទំព័រ ៤

[2] សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈថវិកា ឆ្នាំ ២០០៦ ទំព័រ១៣

និងហិរញ្ញវត្ថុដែលរដ្ឋបានប្រកាន់យក។[3] ច្បាប់ហិរញ្ញវត្ថុមិនត្រូវមានតែចំណូល និងចំណាយប៉ុណ្ណោះទេ ច្បាប់នេះត្រូវបញ្ចូលពត៌មានជាច្រើនដូចជា មានបញ្ញត្តិនានា ដើម្បីឱ្យសភាមានលទ្ធភាពជ្រាបជាពត៌មាន និងធ្វើការត្រួតពិនិត្យលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពត៌មានស្តីពីការបង្កើតថ្មី បទបញ្ញត្តិដែលចែងពីការទទួលខុសត្រូវនៃមន្ត្រីរាជការក្នុងការចាយវាយ កម្មវិធីវិនិយោគធំៗដែលក្រសួងនីមួយៗមានបំណងនិងសម្រេច។ ហិរញ្ញវត្ថុសំដៅដល់ច្បាប់ដែលគ្រោងចំណូល និងចំណាយប្រចាំឆ្នាំរបស់រដ្ឋ បទបញ្ញត្តិពាក់ព័ន្ធទៅ និងវិស័យហិរញ្ញវត្ថុ និងការទូទាត់ផ្សេងៗ ដែលត្រូវប្រើប្រាស់សម្រាប់អនុវត្តមុខងារកម្មវិធីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយអនុលោមទៅតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពី ហិរញ្ញវត្ថុសាធារណៈ និងបទបញ្ញត្តិស្តីពីវិស័យហិរញ្ញវត្ថុដែលច្បាប់បានកំណត់។[4]

## ១.២ លក្ខណៈពិសេសនៃថវិការដ្ឋ

លក្ខណៈពិសេសនេះមានពិតប្រាកដបើប្រៀបធៀបជាមួយហិរញ្ញវត្ថុឯជនភាពផ្សេងគ្នាមានត្រង់ចំណុចៈ

**គោលដៅ** ចំពោះសហគ្រាស ឯកជន គោលដៅគឺរកផលចំណេញ ចំណែកឯបុគ្គលឯកជនគឺប្រយោជន៍ផ្ទាល់ខ្លួន ។ ប៉ុន្តែអង្គការសាធារណៈ ដូចជារដ្ឋ ជាដើមត្រូវធ្វើការបមម្រើប្រយោជន៍ទូទៅមិនមែនបម្រើប្រយោជន៍ឯកជន ឬក្រុមណាមួយទេ។ បញ្ហាខាតចំណេញជាកត្តាសំខាន់ណាស់សម្រាប់សហគ្រាសឯកជន ប៉ុន្តែចំពោះអង្គការសាធារណៈ វាជាបន្ទាប់បន្សំទៅវិញ។

**មធ្យោបាយធ្វើការ** របៀបធ្វើការរបស់ឯកជន ឬក្រុមហ៊ុនគឺគេយកកិច្ចសន្យាជាមូលដ្ឋាន។ក្នុងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនីមួយៗ គេច្រើនធ្វើក្នុងគ្រាវាងភាគី ចំណែកអង្គការវិញ តែងតែយកការបង្ខំតែម្តងប្រើព្រោះគេយល់ថា រដ្ឋជាអ្នកកាន់អំណាចដែលធ្វើដើម្បីបម្រើផលប្រយោជន៍ទូទៅ ប៉ុន្តែការបម្រើអំណាចនេះ មិនមែនចេះតែធ្វើតាមតែអំពើចិត្តនោះទេ។ រដ្ឋឬអង្គការសាធារណៈ ត្រូវគោរពច្បាប់បទបញ្ញត្តិជាធរមាន បើពុំនោះទេត្រូវប្រឈមមុខនៅមុខតុលាការ។

**លក្ខខ័ណ្ឌនៃការអនុវត្ត** ជាធម្មតារដ្ឋមានធនធានធំធេងជាងឯកជន។ ដើម្បីធ្វើការរដ្ឋតែងតែរៀបចំ គិតគូរចំណាយ ធំៗជាមុន ដូចជាចំណាយសម្រាប់វិស័យតុលាការ ការពារជាតិ សន្តិសុខជាដើម រួចហើយគិតគូរពីរឿងរកចំណូលជាក្រោយ។ រដ្ឋអាចមានលទ្ធភាពចំណាយលើសចំណូលរបស់ខ្លួនខុសពីវិស័យឯកជន ដែលពុំអាចចាយវាយលើសពីធនធានដែលខ្លួនមានឡើយ។

[3] សំ សុខ ហិរញ្ញវត្ថុសាធារណៈថវិកា ឆ្នាំ ២០០៦ ទំព័រ ១៥

[4] មាត្រា ៤ នៃច្បាប់ហិរញ្ញវត្ថុសាធារណៈអនុម័តនៅថ្ងៃទី៤ ខែ សីហា ឆ្នាំ ២០០៨

ក្នុងការអនុវត្តការងាររបស់ខ្លួនរដ្ឋត្រូវធ្វើការនៅក្នុងក្របខណ្ឌគតិយុត្តមួយច្បាស់លាស់ក្នុងវិស័យដែលត្រូវតែវចំណាយថែមទៀត ក៏ដូចជាវិស័យចំណូលផងដែរ។ រដ្ឋត្រូវគោរពវិធានខ្លះ ដូចជាគោលការណ៍អនុញ្ញាតជាមុនពីសភា ការបែងចែកការងាររវាងអាណាប័ក និងគណនេយ្យករ ការត្រួតពិនិត្យច្រើនជាន់ថ្នាក់ នៅពេលកំពុងពេលនុវត្ត និងក្រោយពេលអនុត្តថវិកា។ ជាពិសេសការទទួលខុសត្រូវរបស់រដ្ឋមានទំហំធំធេង ប៉ុន្តែស្មុំញ៉ាំពិបាកយល់បន្តិច ពីព្រោះមិនសូវ មានទណ្ឌកម្មប្រាកដ ក្នុងករណីដែលការគ្រប់គ្រងមានភាពមិនប្រក្រតី មិនត្រឹមត្រូវតាមគន្លងច្បាប់។ នៅវិស័យឯកជនគេមានច្បាប់ស្ដីពីករណីក្ស័យធន ដែលត្រូវអនុវត្តទៅលើសហគ្រាសដែលរកស៊ីខាត។ ចំណែងរដ្ឋវិញគេមិនអាចយកច្បាប់នេះមកប្រើ ហើយដាក់ឱ្យរដ្ឋ ក្នុងសភាពក្ស័យធននេះបានទេ ព្រោះជាអំណាចសាធារណៈ។

### ១.៣ ប្រវត្តិនៃការកកើត

ទោះបីជាមិនមានឯកសារបញ្ជាក់ថា ថវិកាជាតិកើតឡើងនៅពេលណាក៏ដោយ យើងអាចនិយាយបានថា ក្នុងជីវភាពរស់នៅរបស់មនុស្សគ្រប់រូប តែងតែរកគ្រោងទុកនូវចំណូលចំណាយ ហើយកំណត់ថាខ្លួនមាប្រាក់គ្រប់គ្រាន់ សម្រាប់ការចំណាយ។

#### ១.៣.១ ធាតុផ្សំធម្មនុញ្ញ

នៅគ.ស ១២១៥ ប្រទេសអង់គ្លេស មានការតស៊ូដណ្ដើមអំណាចហិរញ្ញវត្ថុរបស់សភា ទើបស្ដេច jean Sans Trer ព្រះអង្គបានសម្រេចអោយប្រើធម្មនុញ្ញឈ្មោះ La Grande Chart ដោយអនុញ្ញាតអោយសភាមានអំណាច សម្រេចលើពន្ធដា។ នៅប្រទេសអង់គ្លេស ការគៀងគោរ ប្រាក់ចំណូលទាំងឡាយណា ដែលជាពន្ធដាក្ដីជាវិភាគទានក្ដី បើមិនបានទទួលយល់ព្រមពីសភាទេត្រូវចាត់ទុកខុសច្បាប់។ បដិវត្តន៍នៅប្រទេសបារាំង បានប្រកាសថ្លែងការណ៍របស់ក្រុមប្រឹក្សបដិវត្តន៍ ប្រជាពលរដ្ឋត្រូវចូលរួមវិភាគទានក្នុងបន្ទុកចំណាយរបស់រដ្ឋ ការទទួលបន្ទុកនេះត្រូវតាមលទ្ធភាពរបស់ខ្លួន ហើយត្រូវមានសិទ្ធតាមដានការចំណាយរបស់រដ្ឋផងដែរ ដែលក្នុងនេះមានគោលការណ៍ប្រចាំឆ្នាំ ២៦.៥.១៨១៧ និងគោលការណ៍សកលភាព ១៥.៥.១៨១៨។

#### ១.៣.២ ធាតុផ្សំនយោបាយ

គ្មានឯកសារណាមួយដែលចង្អុលបញ្ជាក់នយោបាយរដ្ឋាបាល អោយបានច្បាស់ជាងថវិកាទេ។ នៅក្នុងថវិកានិងគម្រោង របស់រដ្ឋាភិបាលមិនអាចលាក់បាំងបានទេ។ ដូចជាការតម្លើងពន្ធ បន្ថយពន្ធ និងការចំណាយអាទិភាព អប់រំជាតិ សង្គមកិច្ច ការពារជាតិជាដើម។[5]

[5] សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ២

### ១.៣.៣ ធាតុផ្សំសេដ្ឋកិច្ច

ទិដ្ឋភាពនេះមានសារៈសំខាន់ណាស់ក្នុងរឿងថវិកា។ ឥទ្ធិពល នៃចំណាយសាធារណៈទៅផលទុនសរុបក្នុង ស្រុក (DGP) ។ ឥទ្ធិពលនៃតុល្យភាព ក្នុងឱនភាពថវិកា ទៅលើទេសៈសេដ្ឋកិច្ច។ ឥទ្ធិពលនៃពន្ធដារទៅសេដ្ឋកិច្ចជាតិទាំងមូល។ ទាំងនេះសុទ្ធសុឹងជាកត្តាធំៗដែលត្រូវយលមកគិត ដែលត្រូយកមកគិត ដើម្បីរៀបចំថវិការម្តងៗ។ គេមិនបាច់និយាយរ៉ាប់រងពន្យល់ពីទំនាក់ទំនងជិតស្និតរវាងសេដ្ឋកិច្ចហិរញ្ញវត្ថុសាធារណៈទេ ព្រោះរចនាសម្ព័ន្ធសេដ្ឋកិច្ចក្តី ទេសៈកិច្ចក្តី សុទ្ធសុឹងតែមានឥទ្ធិពលលើហិរញ្ញវត្ថុសាធារណៈទាំងអស់ ចំណែកឯហិរញ្ញវត្ថុវិញសាធារណៈវិញ ក៏ត្រូវដើរតួនាទីជាឧបករណ៍មួយយ៉ាងសំខាន់សម្រាប់រៀបចំគ្រប់គ្រងសេដ្ឋកិច្ចវិញដែរ។ ដូច្នេះហើយបានជាអ្នកសេដ្ឋកិច្ចវិទូខ្លះបានបង្កើតមុខវិជ្ជាថ្មីមួយទៀត ឈ្មោះសេដ្ឋកិច្ចហិរញ្ញវត្ថុ ដើម្បីសិក្សារៀនសូត្រពីបញ្ហានេះ។

### ១.៣.៤ ធាតុផ្សំសង្គម

យន្តការហិរញ្ញវត្ថុកើតចេញពី រចនាសម្ព័ន្ធសង្គម និងកម្លាំងឥទ្ធពលនៃស្រទាប់នានា ក្នុងសង្គមតែម្តង។ ដូចនេះ កក្តាចិត្តសាស្ត្រ ដើម្បីទាញឱ្យរាស្ត្រទុកចិត្តលើការប្រើប្រាស់ថវិកា ប្រកបដោយសុក្រិតភាបរបស់រដ្ឋាភិបាល និងការខ្មីប្រាក់ពីបរទេសគឺរដ្ឋាភិបាលខ្លួនឯងត្រូវលើកគម្រោងអោយបានច្បាស់លាស់ ដើម្បីឱ្យរាស្ត្រដែលជាអ្នកចូលរួមបង់ពន្ធមានកំណត់ក្តៅ។

## ផ្នែកទី២៖ ការបែងចែកចំណាត់ថ្នាក់មុខងាររចនាសម្ព័ន្ធនៃថវិកា

### ២.១ ការរៀបចំវិធានក្នុងថវិការបស់រដ្ឋ

ការសិក្សាលើរចនាសម្ព័ន្ធថវិកាគឺជាមធ្យោបាយមួយដើម្បីឈានទៅរកការយល់ដឹងពីក្របខ័ណ្ឌបច្ចេកទេសនៃការអនុញ្ញាត និង ការអនុវត្តថវិកា។[6] ថវិកាត្រូវរៀបចំទៅតាមចំណាត់ថ្នាក់រដ្ឋបាលដែលផ្អែកលើរចនាសម្ព័ន្ធលើការគ្រប់គ្រងរដ្ឋបាលចំណាត់សេដ្ឋកិច្ច ដែលផ្អែកទៅលើប្រភេទចំណាយចំណាត់ថ្នាក់មុខងារដែលដែលផ្អែកទៅលើគោលបំណង និងចំណាត់ថ្នាក់តាមកម្មវិធី។[7]

ថវិការបស់រដ្ឋមាន៤ភាគ ហើយក៏មានគណនី៤ដែរ ថវិកាទូទៅរបស់រដ្ឋ ថវិកាឧបសម្ព័ន្ធ ថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគណនីពិសេសរបស់រតនាគារ។ គណនីថវិកាផ្សេងៗទៀតអាចបង្កើតបានដោយច្បាប់ហិរញ្ញវត្ថុ។ ការបែងចែកនេះមានលក្ខណៈតែខាងក្រៅប៉ុណ្ណោះព្រោះវាត្រូវប្រមូលផ្តុំនៅក្នុងច្បាប់ហិរញ្ញវត្ថុតែមួយ។

[6] សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦

[7] មាត្រ ១២ នៃច្បាប់ស្តីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ ទំព័រ ៦

**២.១.១ ថវិកាទូទៅរបស់រដ្ឋ**

ថវិកាទូទៅ គឺជាថវិកាដែលកំណត់ចំណូល និងចំណាយទាំងអស់របស់រដ្ឋ។ គេប្រមូលទៅដាក់មួយកញ្ចប់ធំ ដើម្បីយកទៅចាយវាយធ្វើចំណាយទាំងអស់។ គ្មានចំណូលណាមួយដែលអាចយកទៅទូទាត់ចំណាយ ចំពោះមុខបានទេ ។ និយាយឱ្យខ្លីថវិកាមានពីរកញ្ចប់ធំៗ កញ្ចប់ចំណូល និង កញ្ចប់ចំណាយ។

**២.១.២ ថវិកាឧបសម្ព័ន្ធ**

ថវិកាឧបសម្ព័ន្ធ គឺជាថវិកាពិសេស ដែលមានចំពោះ សេវាសធារណៈ របស់រដ្ឋខ្លះ ដែលក្នុងនោះគេចង់អនុម័តនូវការគ្រប់គ្រងពាណិជ្ជកម្ម។

**លក្ខណៈវិនិច្ឆ័យនៃថវិកាឧបសម្ព័ន្ធ**

ត្រូវមានលក្ខខណ្ឌ២ ដើម្បីឱ្យសេវាមួយអាចប្រើប្រាស់ នូវថវិកាឧបសម្ព័ន្ធ[8]បាន ការគ្មាននីតិបុគ្គលភាពរបស់សេវា និងយុត្តកម្ម សេដ្ឋកិច្ច។[9]

ប្រសិនបើសេវាមានបុគ្គលភាព នោះច្បាស់ជាវាមានថវិកាហើយ ខុសពីថវិការបស់រដ្ឋ ហើយមិនមាន ចុះនៅក្នុងច្បាប់ហិរញ្ញវត្ថុទេ។ យុត្តិកម្មពាណិជ្ជ ឬឧស្សាហកម្មនៃសកម្មភាព អាចឱ្យគេបង្កើតបាននូវគណនេយ្យដោយឡែក ហើយប្រើប្រាស់នូវបច្ចេកទេសគណនេយ្យបដិវាទ ដោយប្រៀបធៀបទៅនឹង បទដ្ឋានគណនេយ្យរដ្ឋបាល។

**លក្ខណៈពិសេសនៃថវិកាឧបសម្ព័ន្ធ លក្ខណៈពិសេសនេះមាន៣៖**

១.ទុកឱ្យនៅមួយឡែកការព្យាករណ៍នៃបន្ទុក និងធនធាននៃសេវាមួយបើប្រៀបធៀប នឹងសកម្មភាពផ្សេងៗទៀតរបស់រដ្ឋ។ នៅក្នុងថវិកាទូទៅ គ្មានទេចំនាក់ទំនងគ្នារវាងទៅ និងថវិកា ឧបសម្ព័ន្ធ ហើយធនធាននៃសេវាមួយបានមកពីការយកពន្ធផ្ដាច់មុខ។

២.ថវិកាឧបសម្ព័ន្ធត្រូវបង្ហាញជាពីរផ្នែក ចំណូល និងចំណាយនៃការប្រព្រឹត្តិទៅនាំសេវា ខុសពីចំណាយសម្រាប់វិនិយោគ និងចំណូលចាត់ចែងសម្រាប់ហិរញ្ញប្បទាន។ ភាពខុសគ្នារវាង ចំណាយសម្រាប់ការប្រព្រឹត្តទៅ និងចំណាយវិនិយោគមិនមែនជាលក្ខណៈពិសេសនាំថវិកា ឧបសម្ព័ន្ធទេ។ ប៉ុន្តែភាពខុសគ្នានោះគឺថា ថវិកាឧបសម្ព័ន្ធចែងពីការចាត់ចែងចំណូលសម្រាប់ ប្រភេទចំណាយទាំងពីរ ចំណូលបានមកពីការធ្វើអាជីវកម្ម ជាគោលការណ៍ត្រូវចាត់សម្រាប់ចំណាយនៃការប្រព្រឹត្តទៅនៃសេវាសាធារណៈ តែថាធនធានពិសេសត្រូវទុកសម្រាប់ហិរញ្ញប្បទាននៃការវិនិយោគ។

[8] មាត្រា ២ ថវិកាឧបសម្ព័ន្ធ គឺជាកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គភាពរដ្ឋ ដែលមាន លក្ខណៈ ឧស្សាហកម្ម និង ពាណិជ្ជកម្ម តែពុំមែនជានីតិបុគ្គលទេ។

[9] មាត្រា ២ នៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃ ១១/១០/២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃថវិកាឧបសម្ព័ន្ធ

៣.ជាគោលការណ៍សេវាដែលមានថវិកាឧបសម្ព័ន្ធត្រូវគ្រប់គ្រងប្រកបដោយភាពទន់ភ្លន់ ដែលត្រូវហាមមិនឱ្យមានចំពោះសេវាធម្មតារបស់រដ្ឋ។ ដូចសហគ្រាសឯកជនអញ្ចឹងសេវានេះ ត្រូវចេះដាក់ផែនការលើសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់រយៈពេលច្រើនឆ្នាំ ហើយជាយថាហេតុ បង្កើតមូលនិធិបម្រុងដែលអាចឱ្យគេប្រឈមមុខនឹងបន្ទុកមួយចំនួនទៅថ្ងៃអនាគតបាន។ ប្រការនេះ សេវាធម្មតា របស់រដ្ឋមិនអាចធ្វើទៅបានទេ។ វិធានប្រចាំឆ្នាំហាមដល់សេវាធម្មតាមិនឱ្យបង្កើតមូលនិធិម្តង ហើយការលើកឥណទានអាចអនុញ្ញាតឱ្យបានតែក្នុងករណីពិសេស ប៉ុណ្ណោះ។

**២.១.៣ ថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល**

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត។ ប្រភពធនធានជាប្រចាំរបស់គ្រឹស្ថានសាធារណៈ រដ្ឋបាលរួមមានចំណូលផ្ទាល់ និង ជាយថាហេតុមានការឧបត្ថម្ភតុល្យភាពដោយថវិកាទូទៅរបស់រដ្ឋ។ រីឯ ចំណាយប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវគោតាមវិធាននៃចំណាត់ថ្នាក់និងការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់រដ្ឋដែរ។

ឧទាហរណ៍ៈសាលាភូមិន្ទថៅក្រមដែលត្រូវបង្កើតឡើងដោយអនុក្រឹត្យចុះថ្ងៃ ០៥ កុម្ភៈ ២០០២មានប្រភពធនធានរបស់ខ្លួនៈ

- ធនធានដំបូងដែលរដ្ឋផ្តល់ឱ្យនៅពេលចាប់ផ្តើមបង្កើតសាលា
- ឧបប្បត្ថម្ភធនធានសម្រាប់ដំណើរការ និងឧបត្ថម្ភធនាធានជាមូលធនដែលបានកំណត់ក្នុងថវិការដ្ឋ អំណោយជំនួយ និងអច្ច័យទានដែលសាលាបានទទួលផលនៃការខ្ចី
- ផលនៃការងារ តាវកាលិក និងសេវាដែលសាលាបានផ្តល់ឱ្យ
- ចំណូលដែលបានមកពីទ្រព្យសម្បត្តិដែលអនុញ្ញាតដោយរាជរដ្ឋាភិបាល។

**២.១.៤ គណនីពិសេសរបស់រតនាគារ**

**គណនីពិសេសរបស់រតនាគារ** គឺជាគណនីបណ្តោះអាសន្ន ហើយទទួលខុសត្រូវខាងប្រតិបត្តិការដែលគ្មានលក្ខណៈកំហិត។ ដំណើរប្រព្រឹត្តទៅនៃគណីពិសេសរបស់រតនាគារត្រូវស្ថិតនៅក្នុងកិច្ចធានាសំខាន់ៗមានៈ

- គណនីពិសេសអាចបើកបានតែដោយច្បាប់ហិរញ្ញវត្ថុប៉ុណ្ណោះ ។
- កិច្ចអនុញ្ញាតត្រូវកំណត់នៅក្នុងពេលវេលា ហើយត្រូវដាក់សុំការអនុញ្ញាតថ្មីរៀងរាល់ឆ្នាំ។
- រៀងរាល់ឆ្នាំច្បាប់ហិរញ្ញវត្ថុត្រូវមាន តារាងពេញលេញលើចំណាយទាំងអស់ដែលអាចជាបន្ទុករបស់គណនីពិសេស របស់រតនាគារ។
- សភាធ្វើការត្រួតពិនិត្យលើចំណាយ និងចំណូលរបស់គណនីពិសេសរបស់រតនាគារដូចគ្នានឹងការត្រួតពិនិត្យលើថវិកាទូទៅដែរ។

- ក្នុងច្បាប់ខ្មែរ គណនីពិសេសរតនាគា គឺជាគណនីដែលមានមុខងារៈ
- ទទួលចំណូលពិសេសសម្រាប់យកទៅចាយ លើកិច្ចការពិសេសអ្វីមួយច្បាស់លាស់ គឺគណនីបម្រុងសម្រាប់ពិសេស។
- កត់ចំណាយរដ្ឋដែលមានលក្ខណៈបណ្តោះអាសន្នគឺជាគណនីបុរេប្រទាន។

ចុះបញ្ជីនូវចំណាយណាដែលមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម គឺជាគណនីពាណិជ្ជកម្ម។ ការបង្កើត ឬ ពិសេសរតនាគារត្រូវមានចែងច្បាស់លាស់ក្នុងច្បាប់ថវិកា។ គណនីពិសេសរតនាគារគេបានយកគណនីពិសេសតរនាគារចេញពិថវិកាទូទៅ ព្រោះគណនីនេះមានប្រភពហិរញ្ញវត្ថុពិសេសប្លែកខុសពីធម្មតា មានក្ខណៈបណ្តោះអាសន្នឬមានការគ្រប់គ្រងដូចជាធនាគារ។ ដោយសារមានរំលោភខ្លះក្នុងការគ្រប់គ្រងគណនីនេះគេបានបង្រួមគណនីឱ្យនៅតិចតួចស្រួល នឹងត្រួតពិនិត្យ។ ក្នុងច្បាប់ខ្មែរគណនីពិសេសរតនាគារ គឺជាគណនីដែលមានមុខងារទទួលចំណូល ពិសេសសម្រាប់យកទៅចាយវាយលើកិច្ចការពិសេសអ្វីមួយច្បាស់លាស់ កត់ត្រារាល់ចំណាយរដ្ឋដែលមានលក្ខណៈបណ្តោះអាសន្ន គឺគណនីបុរេប្រទាន ចុះបញ្ជីនូវចំណាយដែលមានលក្ខណៈឧស្សាហកម្ម ឬ ពាណិជ្ជកម្ម(គណនីពាណិជ្ជកម្ម) ការបង្កើតឬលុបគណនីពិសេសរតនាគារ ត្រូវមានចែងក្នុងច្បាប់ថវិកា។ ភាពខុសៗគ្នានៃគណនីពិសេសៈ

**១.គណនីចាត់ចែងពិសេស**

គណនីនេះប្រើសម្រាប់សម្រេចអ្វី ដែលតាមធម្មតា ត្រូវហាមឃាត់ដូចជាការយកចំណូល ខ្លះទៅប្រើសម្រាប់ចំណាយមួយចំនួន។ គណនីចាត់ចែងពិសេសមានលក្ខណៈពិសេសពីរ :

- វាទាក់ទងជាពិសេស ទៅលើប្រតិបត្តិការដែលមានលក្ខណៈស្ថាពរហើយ រឿងនេះមិនខុសពីគណនីពិសេសដទៃទៀតទេ។
- វាអាចបើកបានតែទៅតាមសេចក្តីស្នើរបស់រដ្ឋាភិបាលប៉ុណ្ណោះ។

**២.គណនីបុរេប្រទាន**

គណនីបុរេប្រទាននេះ បង្ហាញពីបុរេប្រទានធ្វើឡើងដោយរដ្ឋចំពោះសមូហភាពដែនដី ឬចំពោះអង្គការរដ្ឋដោយយកការប្រាក់ ហើយការធ្វើនេះសម្រាប់តែរយៈពេលមួយកំណត់ ប៉ុណ្ណោះ។

**៣.គណនីពាណិជ្ជកម្ម**

កត់ត្រាប្រតិបត្តិការ ទាំងអស់ ដែលមានលក្ខណៈ ឧស្សាហកម្ម ឬពាណិជ្ជកម្មដែលបានធ្វើ ដោយរដ្ឋលក្ខណៈបន្ទាប់បន្សំ។ គណនីទាំងអស់របស់រតនាគារត្រូវបានបង្កើត ឬ លុបចោល ដោយច្បាប់ហិរញ្ញវត្ថុក្រោមល័ក្ខខ័ណ្ឌនៃ បទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ។

## ២.២ ឯករាជ្យភាពហិរញ្ញវត្ថុមិនគ្រប់គ្រាន់ខ្លែក

ទោះបីជាមានស្វ័យភាពគតិយុត្ត និងថវិកាក៏ដោយ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ទទួលរងនូវការបង្ខិតបង្ខំរបស់រដ្ឋ។ចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល ជាឧទាហរណ៍ ស្វ័យភាពថវិការបស់សាកលវិទ្យាល័យ មួយចំនួន នៅមានកម្រិតនៅឡើយ ដោយហេតុថាសាកលវិទ្យាល័យទាំងនេះមិនមានសិទ្ធិ គ្រប់គ្រងការងារ និងទីតាំង ដែលខ្លួនត្រូវការដើម្បីបំពេញបេសកកម្មអប់រំរបស់ខ្លួន ព្រោះសេចក្តី សម្រេចនៅក្នុងវិស័យ ទាំងនេះត្រូវចេញដោយអង្គការកណ្តាល។ ទាក់ទិនសហគ្រាសសាធារណៈ គេសំគាល់ឃើញថារដ្ឋចេញសេចក្តីសម្រេចសំខាន់ៗ ក្នុងការគ្រប់គ្រងសហគ្រាសសាធារណៈនៅក្នុងទស្សនៈវិស័យនៃការបម្រើផលប្រយោជន៍រួម ជាជំនួសអាជ្ញាធរផ្ទាល់របស់សហគ្រាសសាធារណៈក្នុងផលប្រយោជន៍ពាណិជ្ជកម្មនិងហិរញ្ញវត្ថុសុទ្ធសាធ។

ឧទាហរណ៍ ការកំណាត់តម្លៃរបស់អាជ្ញាធរសាធារណៈ។

ស្វ័យភាពថវិការបស់មូហភាពមូលដ្ឋាន (ថវិការបស់ឃុំ សង្កាត់) ស្វ័យភាពថវិការបស់សមូហភាពមូលដ្ឋានត្រូវបានទទួលស្គាល់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម នស/រកម/ ០៣០១/០៥ ចុះថ្ងៃទី១៩ មិនា ២០០១។

**ស្វ័យភាពថវិកា** ថវិការបស់សមូហភាពមូលដ្ឋាន ក៏ដូចជាថវិការបស់រដ្ឋដែរ គឺជាកិច្ចការដែលព្យាករណ៍ អនុញ្ញាត រៀងរាល់ឆ្នាំនូវចំណាយ និងចំណូល។ ថវិកានេះកើតឡើងដោយថវិកាដើមដំបូង និងថវិកាបន្ថែម។ ថវិកាបំពេញបន្ថែមត្រូវអនុម័តក្នុងពេលប្រតិបត្តិដើម្បីកែតម្រូវនូវការព្យាករណ៍ថវិកាដើមដំបូងហើយដើម្បីសម្របទៅនឹងកាលៈ ទេសៈ ក្នុងករណីចាំបាច់។ ថវិកា ឃុំសង្កាត់ រៀបចំឡើងដោយអង្គការប្រតិបត្តិ (មេឃុំ ចៅសង្កាត់ ដែលជា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ) ។ ថវិការបស់ឃុំ សង្កាត់ត្រូវអនុម័តដោយអង្គការបញ្ញត្តិ ពោលគឺ ដោយក្រុមប្រឹក្សា ឃុំ សង្កាត់។ ថវិកានេះត្រូវគោរពគោលការណ៍ថវិកាក្លាស៊ីក គោលការណ៍ប្រចាំឆ្នាំ គោលការណ៍ ឯកភាព និងគោលការណ៍សាកលភាព គោលការណ៍ ឯកទេស ក៏ដូចជាគោលការ តុល្យភាពដែរ។ នៅក្នុងទម្រង់របស់វា ថវិការបស់ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងជាពីរផ្នែក ។

### ២.២.១ ការបែងចែកចំណាយស្ថាពរ និង ចំណាយបណ្តោះអាសន្ន

**ចំណាយស្ថាពរ** ជាចំណាយធម្មតា ដែលរដ្ឋត្រូវធ្វើជារៀងរាល់ថ្ងៃ ដើម្បីគ្រប់គ្រងរដ្ឋ ដូចជាចំណាយលើបុគ្គលិកចំណាយសម្ភារៈចំណាយវិនិយោគចំណាយនេះគឺគេច្រើនយកពីពន្ធដារ។[10] ចំណែកឯចំណាយបណ្តោះអាសន្នមួយវិញទៀត គឺមានលក្ខណៈជាសាច់ប្រាក់ដែលរដ្ឋបានឱ្យអ្នកឯទៀត ឬឱ្យជាបុរេប្រទាន។ ដោយសារ

[10] ចំណាយស្ថាពរ ជាមុខងាររបស់រដ្ឋ ក្នុងឋានៈជាអ្នកគ្រប់គ្រងប្រហែល៩៨% រីឯចំណាយបណ្តោះអាសន្នមុខងាររបស់រដ្ឋ ក្នុងឋានៈជាធនាគារិប្រើក្នុងបេសកម្មពិសេស មានប្រហែល២%

ប្រាក់នេះចេញពីបេឡារដ្ឋ គេត្រូវទុកដូចចំណាយ។ ប្រាក់ទាំងនេះត្រូវ តែសងមករដ្ឋវិញក្នុងពេលណាមួយ ដោយមានការប្រាក់ផង ហើយត្រូវបញ្ចូលទៅក្នុងគណនីពិសេសនៃរតនាគារ ព្រោះមិនមែនជាចំណូលធម្មតាទេ។ ន័យមួយបែបទៀត ចំណាយស្ថាពរ ជាចំណាយដែលរដ្ឋទទួលយកចំណូលស្ថាពរដែលភាគច្រើនបានមកពីពន្ធដារ។ ចំណែកឯចំណាយបណ្តោះអាសន្នវិញ គឺមានលក្ខណៈសាច់ប្រាក់ដែលរដ្ឋបាលឱ្យអ្នកខ្ចីឯទៀតខ្ចី ឬឱ្យជាប្រាក់បុរេប្រទានជាដើម។ ដោយសារប្រាក់នេះចេញពីបុឡាប្រទាន គេត្រូវទុកដូចចំណាយ។ ប្រាក់ទាំងនេះត្រូវតែសងមករដ្ឋវិញក្នុងពេលណាមួយ ហើយត្រូវបញ្ចូលទៅក្នុងគណនីពិសេសនៃរតនគារព្រោះមិនមែនជាចំណុលធម្មតាទេ។[11]

គោលដៅនៃការបែងចែកចំណាយជាពីរផ្នែកដែលការបែងចែកអំណាចជាពីរប្រភេទនេះ មានបំណងចង់បញ្ជាក់សកម្មភាពពិតប្រាកដ របស់រដ្ឋ អ្វីដែលបញ្ជាក់ថារដ្ឋ មួយមានមុខងារជាធនាគារិក។[12]

### ២.២.២.ការបែងចែករវាងសេវាអនុម័ត និង វិធានការថ្មី

#### ២.២.២.១ សេវាអនុម័ត និងវិធានការថ្មី

**សេវាអនុម័ត** គឺជាឥណទានអប្បបរមាដែលក្រសួងនីមួយៗ ត្រូវការចាំបាច់ ដើម្បីនិងគ្រប់គ្រងការងារ ឱ្យបានល្អដូចឆ្នាំមុន។ មានន័យថាចំនួនទឹកប្រាក់ គឺស្មើនឹងឆ្នាំមុនហើយថែមមួយភាគទៀត ដែលបានមកពីការតម្លើង ប្រាក់ខែមន្ត្រី រាជការ និងសម្ភារៈឡើងថ្លៃ។ ជាទូទៅឥណទានបែបនេះ មាន ចំនួនស្មើនឹង៩០% នៃថវិកាទាំងមូល ។[13]

**វិធានការថ្មី**ឥណទានបែបនេះគ្មានក្នុងថវិកាឆ្នាំមុនទេ គឺជាសំណើរថ្មីចេស ដូចជាប្រាក់ខែមន្ត្រីថ្មី ឬ តម្លៃសំភារៈថ្មីដែលត្រូវទិញ។[14] ក្នុងករណីខ្លះវិធានការថ្មីមានលក្ខណៈជាចំណាយអវិជ្ជមាន ព្រោះគេត្រូវបន្ថយចំណាយ ទៅវិញដោយសារ មានការបន្ថយបុគ្គលិកខ្លះក្នុងឆ្នាំថ្មី។ ការបែងចែកឥណទានជាពីរផ្នែកខាងលើនេះ មានគោលបំណង គឺគេចង់បានឱ្យនិតិវិធីថវិកាមានភាពងាយស្រួលមិនសាំញ៉ាំមិនសូវខាតពេលច្រើន សភាមិនបាច់ ជជែកគ្នាច្រើនលើកញ្ចប់សេវាអនុម័តចាំបាច់ទាំងមូលទេ ព្រោះបានអនុម័តពីឆ្នាំមុន រួចមកហើយ។ ដូច្នេះសភាគ្រាន់តែអនុម័គ្រសរុបតែម្តងលើកញ្ចប់នេះជាការស្រេច។

[11] សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈ ស្តីពីថវិការរដ្ឋ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦ ទំព័រ ១៨

[12] សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈ ស្តីពីថវិការរដ្ឋ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦ ទំព័រ ១៩

[13] សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈ ស្តីពីថវិការរដ្ឋ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦ ទំព័រ ២១

[14] សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈ ស្តីពីថវិការរដ្ឋ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦ ទំព័រ ២១

#### ២.២.២.២ អត្ថប្រយោជន៍នៃការបែងចែកឥណទានជាពីរផ្នែក

ការបែងចែកឥណទានជាពីរផ្នែក គឺគេចង់បានឱ្យនីតិវិធីថវិកាមានភាពងាយស្រួលមិនសាំញ៉ាំមិនស្វ ខាត សភាមិនចាំបាច់ជជែកគ្នាច្រើនលើកញ្ចប់សេវាអនុម័តចាំបាច់ទាំងមូលទេ ព្រោះបានអនុម័តឆ្នាំមុនរួច ហើយ។ ដូចនេះសភាគ្រាន់តអនុម័តសរុបតែម្តងលើកញ្ចប់នេះជាការស្រេច។ ចំណែកវិធានការថ្មី ដែលជារឿង មួយថ្មីចេសសភាត្រូវពិភាក្សា និងអនុម័តតាមក្រសួងម្តងមួយៗ និងតាមប្រភេទឥណទាន។

មជ្ឈដ្ឋានខ្លះមានមតិថា នីតិវិធីបែបនេះ ឃើញថាងាយស្រួលដែរ ប៉ុន្តែមិនអាចឱ្យមានការ ពិនិត្យឱ្យបាន ហ្មត់ចត់លើខ្ទង់ចំណាយរបស់ក្រសួងនីមួយៗ ដើម្បីឱ្យដឹងថាតើការចាយវាយវាផ្តល់ លទ្ធផលឱ្យបែបណា ។

ម្យ៉ាងទៀតគេខ្លាចតែរដ្ឋាភិបាលឆ្លៀតឱកាសបន្លំបញ្ចូលទៅក្នុងបញ្ជីចំណាយចាស់នូវចំណាយថ្មីខ្លះ ព្រោះ មិនចង់ឱ្យសភាជីកកកាយសួរច្រើនពេក។

## ២.៣ មាតិកាថវិកា

ក្នុងវិស័យថវិកា គេចែកឥនទាននានាជាខ្ទង់ៗ ជាប្រភេទ ប្រភេទចែកជាភាគ ភាគចែកជាជំពូក ជំពូក ចែកជាប្រការ ប្រការចែកជាខណ្ឌ។

### ២.៣.១ ប្រភេទចំណាយនៃថវិការដ្ឋ

នៅក្នុងថវិកានីមួយៗ គេត្រូវកំណត់ចំណាយ និងចំណូលទាំងអស់ឱ្យបានច្បាស់លាស់ មិនត្រឹមតែ ប៉ុណ្ណោះគេត្រូវបញ្ជាក់ឱ្យដឹងថាថវិកាមានអតិរេកឬភាព។ ការសិក្សាចំណាយត្រូវធ្វើទៅតាមលក្ខណៈរដ្ឋបាលនៃ ចំណាយ ឬទៅតាមវិស័យសកម្មភាពក្រសួង។ ការសិក្សានេះត្រូវបំផុសនូវការវិវត្តន៍ចំណាយនេះផងទើបមាន ប្រយោជន៍។[15] ចំណាយ ក្នុងថវិកាខ្មែរ គេចែកចំណាយជា៥ប្រភេទ មធ្យោបាយសេវា ការប្រាក់អន្តរាគមន៍សា ធារណៈ ចំណាយផ្សេងៗ ឬចំណាយមិនបានគ្រោងទុក ចំណាយទាំង៤ នេះហៅថា ចំណាយចរន្តនិងចំណាយ មូលធន។[16] ចំណាយចរន្ត សម្រាប់ដំណើរការក្រសួងនានា មានទំហំលើសលុបច្រើនជាងចំណាយមូលធនទៅ ទៀត។ ចំណាយនេះច្រើនជាចំណាយទៅលើបុគ្គលិក ដូចជានៅក្រសួងអប់រំជាតិ ក្រសួងមហាផ្ទៃ ក្រសួងវប្បធម៌ ជាដើម។ ក្នុងករណីថវិកាស្រសួងហិរញ្ញវត្ថុ ចំណាយដែលធំជាងគេនេះ គឺចំណាយសម្រាប់បង់អោយសេវា ហិរញ្ញវត្ថុមានការប្រាក់ជាអាទិ៍។

[15] សំ សុខ នីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦

[16] ក្នុងច្បាប់ហិរញ្ញវត្ថុខ្មែរ ចំណាយមានពីគឺចំណាយចរន្ត និងចំណាយមូលធន។ ចំណាយចរន្ត គឺបានមកពីប្រមូលពន្ធ។ រីឯឱនភាពថវិកា មកពីចំណាយមូលធន ព្រោះរដ្ឋាភិបាលគ្មានថវិកាគ្រប់គ្រាន់ ត្រូវខ្ចីលុយគេយកមកចំណាយ។

**២.៣.១.១ មធ្យោបាយសេវាកម្ម**

ចំណាយមូលធន មាន២ ក្រុម : ចំណាយពិត និងចំណាយតាមដីកាជាឥណទានសម្រាប់ការចាយវាយគ្រប់គ្រងរាល់ថ្ងៃ។ បើប្រៀបធៀបទៅនឹងចំណាយឯទៀតៗ ចំណាយនេះមានកម្រិតខ្ពស់ជាងគេ។ ចំណាយប្រភេទនេះមាននៅគ្រប់ក្រសួង។

- **ការប្រាក់**

ការប្រាក់ ជាចំណាយដែលរដ្ឋត្រូវធ្វើ ព្រោះរដ្ឋជំពាក់គេដោយសារខ្ចីលុយ យកមកបំពេញឱនភាពថវិកា។ ចំណាយ នេះមានតែនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទេ ព្រោះក្រសួងនេះ ជាអ្នកខ្ចីលុយគេក្នុងនាមរដ្ឋាភិបាល។ ចំណាយនេះមានទំហំធំគ្រាន់បើដែរពោលគឺស្មើនឹងថវិកាក្រសួងបី (វប្បធម៌ បរិស្ថាន និងក្រសួងការងារ) ។

- **អន្តរាគមន៍សាធារណៈ**

អន្តរាគមន៍ មានន័យ ជាចំណាយផ្ទេរ ដែលក្រសួងខ្លះបានយកទៅឱ្យស្ថាប័នខ្លះ ដែលធ្វើការនៅក្រោមអាណាព្យាបាលរបស់ខ្លួន។ ក្រសួងដែលមានចំណាយបែបនេះគឺ ក្រសួងមហាផ្ទៃដែលយកថវិកាមួយចំណែកឱ្យឃុំ សង្កាត់ ក្រសួងអប់រំ យកថវិកាមួយចំណែកមកផ្ទេរឱ្យសាកលវិទ្យាល័យ ក្រសួងសុខាភិបាល ផ្ទេរថវិកាមួយចំណែកមកឱ្យមន្ទីរពេទ្យរដ្ឋធំៗ ក្រសួងវប្បធម៌ ផ្ទេរឱ្យសារមន្ទីរជាតិ។

- **ចំណាយផ្សេងៗ**

ចំណាយផ្សេងៗជាចំណាយតូចៗ ដែលគេមិនអាចយកមកបញ្ចូលក្នុងចំណាយ៣ខាងលើ ចំណែកចំណាយមិនបាន គ្រោងទុក ដែលយកមកចាយនៅពេលមានព្រឹត្តិការណ៍មិនបានគ្រោងទុក។

- **ចំណាយមូលធន**

ចំណាយមូលធន ត្រូវផ្អែកលើកម្មវិធី ឬគម្រោងដោយឡែកៗ ដែលមានការយល់ព្រមជាមុន និងដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបាននូវគោបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ កម្មវិធី ឬ គម្រោងទាំងអស់នោះ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយមូលធនសរុបរបស់កម្មវិធី និងគម្រោង សម្រាប់រយៈពេលនៃការសន្យា ការទូរទាត់សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ។[17] ចំណាយមូលធនជា ជាចំណាយសម្រាប់ធ្វើវិនិយោគធំៗ។ ចំណាយមូលធនត្រូវសង ដើមដើម្បីរំលោះបំណុល ហើយជាចំណាយដែលរដ្ឋាភិបាលយកទៅធ្វើវិនិយោគ

[17] មាត្រា៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ ទំព័រ ២២

សុទ្ធ (វិនិយោគធំៗ) ដូចជាការធ្វើផ្លូវ ស្ពាន ភូមិថ្នល់ អភិវឌ្ឍន៍ អគ្គិសនីផ្សេងៗជាដើម។ ចំណាយមូលធន មានពីរក្រុមៈ[18]

**ក្រុមទី១** : ចំណាយពិតមានពីរប្រភេទ : ការទូទាត់ ប្រាក់កម្ចី (ការរំលោះប្រាក់ កម្ចី) និង អចលនកម្ម (ការសាងសង់ សម្ភារៈ..)

**ក្រុមទី២** : ចំណាយតាមដីកា[19] គឺចំណាយអន្តរាគមន៍សាធារណៈ។ ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនេយ្យ អនុគណនេយ្យ និងជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២.៣.២. ប្រភេទចំណូលនៃថវិការដ្ឋ

ក្នុងចំណូលក៏ត្រូវបានចាត់ថ្នាក់យ៉ាងច្បាស់លាស់ ដូចចំណាយដែរគឺ ប្រភេទចែកជាជំពូក ជំពូកចែកចេញជាប្រការ ប្រការចែកចេញជាកថាខ័ណ្ឌ កថាខ័ណ្ឌចែកជាវាក្យខ័ណ្ឌ។ ការសិក្សាលើចំណូលថវិកា មិនអាចបំបែកបានចេញការសិក្សាលើសេដ្ឋកិច្ចបានទេ ព្រោះចំណូល ពន្ធអាករ ដែលជាចំណូលមួយយ៉ាងធំ ត្រូវពឹងផ្អែកលើសេដ្ឋកិច្ចទាំងស្រុង។ ដូចនេះបើចង់ឱ្យការប្រមាណ ចំណូលថវិកា កុំឱ្យខុសខ្លាំងពេក គប្បីធ្វើព្យាករណ៍លើកំណើនសេដ្ឋកិច្ចឱ្យបានហ្មត់ចត់បន្តិច។

#### ២.៣.២.១ ប្រភេទចំណូល

ចំណូលរបស់រដ្ឋមានពីរប្រភេទគឺៈ ចំណូលថវិកាសុទ្ធសាធ ដើម្បីធ្វើការចំណាយរបស់ខ្លួន រដ្ឋត្រូវរកចំណូលដែលភាគច្រើនបានមកពន្ធដារ (ប្រហែល៩០%នៃចំណូលសរុប) ។ ក្រៅពីពន្ធដាមានចំណូលឯទៀតមាន គឺមានប្រាក់ចំណេញពីក្រុមហ៊ុននានា ចំណូលបានមកពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (Domaine) ចំណូលមកពីអាករពន្ធដារផ្សេងៗ[20] ដូចជាចំណូលបានពីការប្រណាំងសេះ ឆ្នោតជាតិ ការប្រាក់ដែលរដ្ឋបានទទួលលើលុយកាក់ដែលរដ្ឋឱ្យគេខ្ចី ចំណូលបានមកពីជំនួយឥតសំណងពីបរទេស ភាគទានសម្រាប់សោធននិវត្តន៍យោធា និងស៊ីវិល ចំណាយបានមកពីសមាគមន៍អឺរ៉ុប និងចំណូលឯទៀត។ ឯមួយទៀតចំណូលក្រៅថវិកា[21] ចំណូលនេះបានមកពីការខ្ចីបុលគេ និបានមកពីកិច្ចប្រតិបត្តិការរតនាគារ។ ចំណូលទាំងនេះត្រូវមានការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ ព្រោះជាចំណូលដែលរដ្ឋដោះស្រាយឱនភាពថវិកា។ គេសង្កេតឃើញថា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជាត្រូវទទួលការអនុញ្ញាតអោយបោះ

[18] មាត្រា ២៣ ដកស្រង់ពីកម្រងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ទំព័រ ១១

[19] ចំណាយតាមដីកា គឺជាចំណាយតាមការបញ្ជារបស់ក្រសួងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ដើម្បីអនុវត្តគម្រោង

[20] សំ សុខ ដកស្រង់ពីនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ៤០

[21] សំ សុខ ដកស្រង់ពីនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ៤១

ផ្សាយប័ណ្ណរតនាគារ ក្នុងកម្រិតទឹកប្រាក់ដែលស្តុកចំនួន ១០០.០០០.០០០.០០០ (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយជាបន្ទាន់ជាសាច់ប្រាក់។ ក្នុងមាត្រាដដែលនោះ សភាបានយល់ព្រមអនុម័តឱ្យរដ្ឋាភិបាល ខ្ចីប្រាក់ពីគេដែលមានកម្រិតរហូតដល់ ២០០.០០០.០០០S.D.R.(ពីរយលានអេសដេអែរ) សម្រាប់គ្រប់គ្រងឆ្នាំ ២០០៥។[22]

ធនធានអចិន្ត្រៃយ៍របស់រដ្ឋរួមមានចំណូលចរន្ត និងចំណូលមូលធន។[23] ការអនុវត្តចំណូល ឆមាសទី១ ចំណូលចរន្តៈ[24] អនុវត្តបានចំនួន ១២ ៦៩៣ ៥៨៥ លានរៀល ស្មើនឹង ៥៧,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ៣,៨% ពិន្ទុភាគរយធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៥៣,៥% នៃច្បាប់ហិរញ្ញវត្ថុ បើគិតជាសាច់ប្រាក់ គឺកើនឡើង ២០,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដោយសារការ កំណត់ចំណូលសម្រាប់ឆ្នាំ ២០២២ គឺទាបជាងចំណូលសម្រាប់ឆ្នាំ ២០២១។ ជារួម ចំណូលសារពើពន្ធនៅអនុវត្តបានល្អប្រសើរពោលគឺខ្ពស់ជាងឆ្នាំ ២០២១ ធៀបនឹងរយៈពេល ៦ ខែដើមឆ្នាំដូចគ្នា ប៉ុន្តែ ចំណូលមិនមែនសារពើពន្ធអនុវត្តបានទាប ដោយសារប្រភពចំណូលសារពើពន្ធសំខាន់ៗ នៅទទួលរងនូវផលប៉ះពាល់ខ្លាំងពីជំងឺកូវីដ-១៩។ ទោះជាយ៉ាងនេះក្តី, តាមការប៉ាន់ប្រមាណរហូតដល់ដំណាច់ឆ្នាំ ២០២២ ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធអាចនឹងសម្រេចបាន ១០៣,៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន ៣,៥%។ តាមការវាយតម្លៃនេះ ចំណូលចរន្ត នឹងសម្រេចបានខ្ពស់ជាងផែនការ ១៩០ លានដុល្លារអាម៉េរិក ដោយសារចំណូលមិនមែនសារពើពន្ធនឹងសម្រេច ខ្ពស់ជាងផែនការប្រមាណ ៥ លានដុល្លារអាម៉េរិកចំណូលពន្ធដារអាចសម្រេចបានខ្ពស់ជាងផែនការ ២២៩ លានដុល្លារអាម៉េរិក តែចំណូលគយអាចទាបជាងផែនការ ៤៤ លានដុល្លារអាម៉េរិក។

➢ **ចំណូលចរន្ត ត្រូវបែងចែកជា២ក្រុម និង៣ប្រភេទៈ**[25]

- **ក្រុមទី១ : ចំណូលពិត**

**ប្រភេទទី១ : ចំណូលសារពើពន្ធមានពន្ធ និងអាករ**

ចំណូលសារពើពន្ធរួមមានចំណូលបានមកពីពន្ធ និងអាករក្នុងប្រទេស និងពន្ធអាករលើពាណិជ្ជកម្មក្រៅប្រទេ ពន្ធលើផលទុលើប្រាក់ចំណេញ និងកម្រៃទុន(រូបវន្តបុគ្គល) ពន្ធលើប្រាក់បៀវត្ស ពន្ធលើដីធ្លី ផ្ទះសម្បែង ពន្ធលើផលទុនប្រាក់បំណេញ និងកម្រៃទុនប្រាក់ចំណេញ(នីតិបុគ្គល) ពន្ធលើប្រាក់ចំណេញ

[22] មាត្រា៩ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០០៥

[23] មាត្រា១៣ នៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រះរាជក្រម នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨

[24] របាយការស្តីអំពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងលទ្ធផលប៉ាន់ស្មាននៃការអនុវត្តថវិកាឆ្នាំ២០២២

[25] មាត្រា ១៣ ដកស្រង់ពីកម្រងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ទំព័រ ៧

របស់សហគ្រាសសាធារណៈ ពន្ធលើប្រាក់ចំណេញវិស័យឯកជន ពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ និងសេវាអាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសឯកជន) អាករលើតម្លៃបន្ថែម-របបផ្ទៃក្នុង(សហគ្រាសសាធារណៈ) អាករលើតម្លៃបន្ថែម-របបផ្ទៃក្នុង (នសហគ្រាសឯកជន) កម្រៃនៃការថែទាំ ការជួល និងមធ្យោបាយដឹកសំភារៈ អាករលើតម្លៃបន្ថែម-របបផ្ទៃក្នុង(សហគ្រាសសាធារណៈ) អាករលើតម្លៃបន្ថែម-របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) ពន្ធអាករលើតម្លៃបន្ថែម-របបនាំចូល(សហគ្រាសផ្សេងៗទៀត) អាករពិសេសលើទំនិញមួយចំនួន-របបផ្ទៃក្នុងចំណូលពីប្រដាប់ក្ដី អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល(សហគ្រាសប្រេងឥន្ធនៈ) អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល (សហគ្រាសផ្សេងៗទៀត) អាករលើសេវាដែលបានកំណត់ អាករលើកាស៊ីណូ អាករពិសេសលើសេវាមួយចំនួនទៀត អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ និងការអនុវត្តសកម្មភាព ចំណូលលើអាជ្ញាប័ណ្ណក្នុងស្រុក ពន្ធដាកពិន័យពនិងទោសបញ្ញត្តិសារពើរពន្ធ ពន្ធលើតែមប្រ៊ី (កាលណាធ្វើសំបុត្រស្នាមអ្វីមួយជាមួយរដ្ឋ គេច្រើនតែទិញតែមប្រ៊ីមកបិទលើសំបុត្រ តែមប្រ៊ីទុកជាដូចពន្ធតូច ដែលត្រូវបង់ជូនរដ្ឋ។ គួរកត់សម្គាល់តែមប្រ៊ីនេះជាតែមពន្ធដា (Timber ពន្ធនេះគេបញ្ចូលទៅក្នុងតម្លៃទំនិញនីមួយៗ ដែលអ្នកទិញបានបង់ហើយគឺអ្នកលក់ទំនិញជាអ្នកបង់បន្តទៅជូនរដ្ឋ)។

ពន្ធនិងអាករលើការនាំចូល ពន្ធអាករនិងការនាំចេញ ពន្ធគយពីការនាំចូល កម្រៃយកមុនពីការងារនាំចូល ពន្ធលើផលិតផលតេលសិលា អាករលើផលិតផលតេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ ផលនៃការលក់ផ្នែកគយ ពិន័យផ្សេងៗពីការនាំចូល អាករលើការនាំចេញឈើ កៅស៊ូ កម្រៃនាំចូលនិងទិដ្ឋាការនាំចេញ និងចំណូលសាពើពន្ធដដៃទៀត។ ជាក់ស្តែងចំណូលសារពើពន្ធៈ[26] សរុបសម្រាប់ឆមាសទី១ ឆ្នាំ ២០២២ អនុវត្តបាន ៥៩,៤% នៃច្បាប់ហិរញ្ញវត្ថុ ដែលក្នុងនោះ៖ ចំណូលគយនិងរដ្ឋាករ អនុវត្តបានចំនួន ៥ ១៧៨ ៦៤៩ លានរៀល ស្មើនឹង ៤៩,៨% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ៣,៥ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៤៦,៣% នៃច្បាប់ហិរញ្ញវត្ថុ បើគិតជាសាច់ប្រាក់ ចំណូលគយនិងរដ្ឋាករកើនឡើង ១៧,៨% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២១។ ក្នុងនោះ ចំណូលបានមកពីយុទ្ធនាការប្រមូលពន្ធនិងអាករលើយានយន្តមានស្រាប់ក្នុង ប្រទេសមានចំនួន ១៣៤ ២៩៧ លានរៀល ត្រូវជា ២,៦% នៃចំណូលប្រមូលដោយគយនិងរដ្ឋាករក្នុងឆមាសទី ១ ឆ្នាំ ២០២២ ដែលយុទ្ធនាការនេះបានបិទបញ្ចប់នៅដំណាច់ខែ មិថុនា ឆ្នាំ ២០២២។ គួរកត់សម្គាល់ផងដែរថា ចំណូលគយនិងរដ្ឋាករតាមបណ្ដាខែក្នុងឆមាសទី១ ឆ្នាំ ២០២២ មាននិន្នាការងើបឡើងវិញបណ្ដើរៗ បន្ទាប់ពីរាជរដ្ឋាភិបាលបានបើកប្រទេស

[26] បាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការវាយតម្លៃការអនុវត្តស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង២០២២

ឡើងវិញ។ ប៉ុន្តែ ទន្ទឹមគ្នានេះចំណូលបាត់បង់ដោយសារការអនុវត្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងក្របខ័ណ្ឌអាស៊ាន និងរវាងអាស៊ានជាមួយដៃគូអាស៊ានផ្សេងទៀតសរុប ក្នុង ឆមាសទី១ ឆ្នាំ ២០២២ មានរហូតដល់ប្រមាណ ៧៣៨ ៥៧៦ លានរៀល និងពន្ធអាករជាបន្ទុករបស់រដ្ឋ មានរហូតដល់ប្រមាណ ៧ ៤០៧ ៤១០ លានរៀល។

បើពិនិត្យលើរចនាសម្ព័ន្ធពន្ធអាករគយដែលត្រូវបានកត់ត្រាដោយអគ្គនាយកដ្ឋានរតនាគារជាតិ នោះឃើញថា (១)-ពន្ធលើការនាំចូលអនុវត្តបាន ៥០,១% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺកើនឡើង ៦,០ ពិន្ទុភាគរយ (២)-អាករលើការនាំចេញអនុវត្តបាន ៦០,៦% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺថយចុះ ១១០,៣ ពិន្ទុភាគរយ ដោយសារការនាំចេញទំនិញផ្សេងៗ មានដំណើរការល្អប្រសើរឡើងវិញ (៣)-អាករពិសេសលើការនាំចូលអនុវត្តបាន ៤៩,៤% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺកើនឡើង ២,៤ ពិន្ទុភាគរយ និង (៤)-អាករលើតម្លៃបន្ថែមលើ ការនាំចូលអនុវត្តបាន ៤៩,៧% នៃច្បាប់ហិរញ្ញវត្ថុ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺកើនឡើង៣,៣ %។ ទន្ទឹមនេះ បើពិនិត្យលើប្រភពចំណូលសំខាន់ៗ នោះឃើញថា៖ ចំណូលពីមុខទំនិញចម្រុះ ដែលគ្របដណ្តប់ប្រមាណ ២៨,១% នៃចំណូលសរុបបានកើនឡើង ១០,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១។ ចំណូលពីមុខទំនិញយានយន្តនិងគ្រឿងចក្រដែលគ្របដណ្តប់ប្រមាណ ៤៤,១% នៃចំណូលសរុប បានកើនឡើង ១៤,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ។ ចំណូលពីមុខទំនិញផលិតផលតេលសិលា ដែលគ្របដណ្តប់ប្រមាណ២១,៦%នៃចំណូលសរុបបានកើនឡើង ១,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ បរិមាណនៃការនាំចូលប្រេងសាំងកើនឡើង ១៩,៥%ប្រេងម៉ាស៊ូតថយចុះ ១៨,១% និងប្រេងយន្តហោះកើនឡើង ៥,៤%។

**ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ៖**[27] រួមមានចំណូលបានមកពីការចាត់ចែងការជួលដីទំនេរផលទុនពីសហគ្រាសសាធារណៈ ការធ្វើអាជីវកម្ម និងការលក់ការលក់ទ្រព្យសម្បត្តិសេវារបស់រដ្ឋ ផលបានមកពីសម្បទាន កម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យ និការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំអោយ ផលហិរញ្ញវត្ថុផលផ្សេងៗ និងផលពិសេស និងចំណូលមិនមែនសារពើពន្ធដដៃទៀត។ ពីប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ ការបង់ប្រាក់រំលស់ ចំនួនលើសនៃទុនចល័ត និងការជួលដីធ្លី សម្បទានរ៉ែ សម្បទានព្រៃឈើ ផលទុនរបស់អាកាសចរស៊ីវិល ផលទុនពីសកម្មភាពទេសចរណ៍ ផលទុនពីប្រៃសណីយ៍ និទូរគមនាគមន៍ ផលទុននៃសកម្មភាពវប្បធម៌ ផលទុនពីវិទ្យុ និងទូរទស្សន៍ផលទុននៃសេវាផ្គត់ផ្គង់ទឹក និងផលទុនផ្សេងៗទៀត។ ចំណូលមិនមែនសារពើពន្ធ អនុវត្តបានចំនួន ៦៧៦.០៧៣ លានរៀល ស្មើនឹង ៣៥,០%នៃច្បាប់ហិរញ្ញវត្ថុ គឺទាប

[27] បាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការវាយតម្លៃការអនុវត្តស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង២០២២

ជាង ៣,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ចំនួន ៣៨,៩% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណូលជាសាច់មានការថយចុះ ២០,៥% ធៀបនឹងរយៈពេលដូចគ្ន ក្នុងឆ្នាំ ២០២១ ក្នុងនោះ៖

ចំណូលពីទ្រព្យសម្បត្តិរដ្ឋ អនុវត្តបានចំនួន ៣៥៧ ១២៣ លានរៀល ស្មើនឹង ១៦២,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ៣,៨ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ១៥៩,២% នៃច្បាប់ហិរញ្ញវត្ថុ ប៉ុន្តែបើគិតចំណូលជាសាច់ប្រាក់ថយចុះ ៩,២% ធៀបនឹងរយៈពេលដូចគ្ន ក្នុងឆ្នាំ ២០២១។

ចំណូលមិនមែនសារពើពន្ធផ្សេងទៀត ក្រៅពីទ្រព្យសម្បត្តិរដ្ឋ អនុវត្តបាន ១៩,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺទាបជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ២៦,១% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណូលជាសាច់ប្រាក់មានការថយចុះ ៣២,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ដោយឡែក ចំណូលកាតព្វកិច្ចពីកាស៊ីណូ និងចំណូលកាតព្វកិច្ចពីឆ្នោត អនុវត្តបានចំនួន ១១ ៣៦៥ លានរៀល ស្មើនឹង ៧,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ១,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ចំណូលនេះមានការកើនឡើង ២២៧,១% ធៀបនឹងរយៈពេល ដូចគ្នាក្នុងឆ្នាំ ២០២១។ ដូចនេះ តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ ២០២២ ចំណូលកាតព្វកិច្ចពីកាស៊ីណូ និងពីឆ្នោត អាចសម្រេចបានតាមច្បាប់ហិរញ្ញវត្ថុប្រមាណ ១០០,០%។

ជារួមចំណូលមិនមែនសារពើពន្ធ ដែលមានបីផ្នែកសំខាន់ៗ រួមមាន៖ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត ក្រៅពីទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងចំណូលកាតព្វកិច្ចពីកាស៊ីណូ និងចំណូលកាតព្វកិច្ចពីឆ្នោតក្នុងឆមាសទី១ នៅក្នុងឆ្នាំ២០២២ អនុវត្តពុំសូវបានល្អ ដោយសារការបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ហើយមុខចំណូលខ្លះទៀតកំពុងបំពេញនូវនីតិវិធីកត់ត្រាចូល ដូចជាចំណូលពីផលទុនរបស់ប្រៃសណីយ៍ និងទូរគមនាគមន៍។ ក៏ប៉ុន្តែតាមការប៉ាន់ស្មាន រហូតដល់ដំណាច់ឆ្នាំ ២០២២ ចំណូលមិនមែនសារពើពន្ធ អាចនឹងសម្រេចបានប្រមាណដល់ ១០១,១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២។

- **ក្រុមទី២:ចំណូលតាមដីកា** ( គឺចំណូលតាមមធ្យោបាយសេវា )
  ជាចំណុចដែលអត់មានសាច់ប្រាក់ពោលជាចំណូលដែលឆ្លងកាត់តាមគណនីមួយទៅគណនីមួយទៀត។

**ប្រភេទទី៣៖ ចំណូលមូលធន** រួមមានបានមកពីអចលកម្មហិរញ្ញវត្ថុ ហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគការខ្ចី និងចំណូលមូលធនផ្សេងទៀត។ ចំណូលមូលធនថវិការដ្ឋ អនុវត្តបានចំនួន ១.៤០៨ ២៦៥ លានរៀល គឺស្មើនឹង ៥៤,៧% នៃច្បាប់ហិរញ្ញវត្ថុ។ ក្នុងនោះ ចំណូលមូលធនក្នុងប្រទេស អនុវត្តបានចំនួន ១៨ ៨៩៦ លានរៀល ស្មើនឹង ១,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺទាបជាង ១២,០ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុង

ឆ្នាំ ២០២១ ដែលអនុវត្តបាន ១៣,៤% នៃច្បាប់ហិរញ្ញវត្ថុ។ ចំពោះចំណូលមូលនិធិទ្រទ្រង់ថវិកា អនុវត្តបានចំនួន ១ ៣៨៩ ៣៦៩ លានរៀល ស្មើនឹង ១០៩,៥% នៃច្បាប់ហិរញ្ញវត្ថុ។

ចំណូលមូលធន ត្រូវបានបែងចែកជា២ក្រុម និងបីប្រភេទគឺៈ[28]

- **ក្រុមទី ១ : ចំណូលពិត**

-ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់ : បានមកពីការលក់ទ្រព្យសម្បត្តិរដ្ឋ

-ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ : ប្រាក់កម្ចី ជំនួយ ការនាំចូល ទំនិញឬសម្ភារៈ

- **ក្រុមទី ២ : ចំណូលតាមដីកា**

ចំណូលនេះគេមិនសូវឃើញមានទេ គេគ្រាន់តែកត់ត្រាទុក ប្រភេទចំណូលនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ ជាជំពូក គណនី អនុគណនី និងជាយថាហេតុអាច លម្អិតជាងនេះទៅទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

និយាយរួមគេចែកប្រភពចំណូលមានបីប្រភេទគឺ : ពន្ធ-អាករ ចំណូលក្រៅពន្ធ និងចំណូលមូលធន។ ដែលពន្ធ គឺជាទឹកប្រាក់ដែលរដ្ឋបង្ខំឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល បង់ជូនជាតិជាស្ថាពរដោយគ្មានទទួលថ្នូរអ្វីទាំងអស់ដើម្បីយកមកបំរើសេវាបំរើសេវាសាធារណៈ។

ក្នុងសកលលោកនេះ រដ្ឋណាក៏ដោយត្រូវតែធ្វើចំណាយជាច្រើនដើម្បីគ្រប់គ្រងប្រទេស ហើយចំណាយទាំងនេះត្រូវបិតក្នុងបន្ទុកប្រជាពលរដ្ឋទាំងមូលដែលត្រូវធ្វើវិភាគទានតាមលទ្ធភាពរៀងៗខ្លួន។ គោលការណ៍នេះជាគោលការណ៍សំខាន់ដែលបានចែងក្នុងសេចក្ដីថ្លែងការស្ដីពីសិទ្ធមនុស្ស និងសិទ្ធពលរដ្ឋកាលពីសម័យបដិវត្តន៍បារាំងក្នុងឆ្នាំ១៩៨៩។ ដោយសារតែពលរដ្ឋត្រូវបង់គ្រប់ៗគ្នា ទំហំពន្ធដារក្នុងផ្ទៃចំណូលរដ្ឋទាំងមូលមានកំរិតខ្ពស់ជាអតិបរមា ពោលគឺប្រហែល៩០%ឯណោះ។

**អាករ**[29] ជាទឹកប្រាក់ដែលអ្នកប្រើប្រាស់បង់លើសេវាណាមួយ ដូចជាលើបំរាមជាដើម។ គេច្រើនច្រឡំពាក្យពន្ធនិងអាករ។ តាមទ្រឹស្ដីពន្ធគឺគេយកពីយើងគ្រប់គ្នាទៅចំណាយលើសេវាសាធារណៈទាំងអស់មិនចំពោះមុខ តាំងពីបៀវត្សមន្ត្រីរាជការរហូតដល់ការទិញសំភារៈ និងវិនិយោគផ្សេងៗ។ ចំណែកអាករវិញយកពីយើងតែចំពោះសេវាណាមួយទេមិនអាចយកទៅប្រើសម្រាប់ចំណាយរបស់រដ្ឋទូទៅបានឡើយ។ អាករលើការប្រមូលសំរាមត្រូវតែយកទៅប្រើតែលើសេវាមួយមុខនេះ។ ពន្ធនិងអាករខុសគ្នាត្រង់អង្គការដែលត្រូវប្រមូលប្រាក់ចូល។

[28] មាត្រា១៣ កម្រងច្បាប់ស្ដីពី ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨

[29] សំ សុខ នីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ៤៤-៤៥

ពន្ធគឺនាយកពន្ធដារជាអ្នកប្រមូលចំណែកអាករវិញគឺអង្គភាពផ្តល់សេវាជាអ្នកប្រមូល។ នេះជាទ្រឹស្តីប៉ុន្តែតាមជាក់ស្តែងវិញ គេមិនសូវគិតគូរពាក្យពេចន៍ទេ។ ឧទាហរណ៍ អាករដីធ្លី អាករលើផ្ទះសំបែងពិតមែនតែមានឈ្មោះជាអាករមែនពិត ប៉ុន្តែមែនទែន គឺជាពន្ធផ្ទាល់ ដូចពន្ធជាលើផលទុន ឬពន្ធលើប្រាក់ចំណេញដែរ។ ដូចគ្នានេះដែរអាករលើតម្លៃបន្ថែម ជាពន្ធពិតប្រាកដគឺជាពន្ធប្រយោល ដែលនាយកដ្ឋានពន្ធដារត្រូវប្រមូលចូលថវិការដ្ឋ។

ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានអនុម័ត ថ្ងៃទី ០៤ មេសា ២០០៨ មាត្រា១៥។ ចំណូលសារពើពន្ធរួមមានចំណូលបានមកពីពន្ធនិងអាករ ក្នុងប្រទេស និងអាករលើពាណិជ្ជកម្ម ក្រៅនិងចំណូលសារពើពន្ធដទៃទៀត។[30] គេអាចដកស្រង់ជាឧទាហរណ៍នូវចំណូលមួយចំនួន ប្រភេទ១ ពន្ធនិងអាករ ដែលស្ថិតនៅ

ជំពូក១០ : ពន្ធលើផលទុន ប្រាក់ចំណេញ និងកម្រៃទុន

ប្រការ ០១ : ពន្ធលើប្រាក់បៀវត្សរ៍

ប្រការ ០២ : ពន្ធលើប្រាក់ចំណេញរបស់រោងចក្រ និងពាណិជ្ជកម្មកថាខ័ណ្ឌ ០១ សហគ្រាសសាធារណៈ

វាក្យខ័ណ្ឌ ០១ សហគ្រាសមជ្ឈឹម

វាក្យខ័ណ្ឌ ០២ សហគ្រាសខេត្តនានា

កថាខ័ណ្ឌ ០២ សហគ្រាសឯកជន ជំពូក១១ : ពន្ធលើបេតិកភ័ណ្ឌ... ។ល។

ប្រភេទ២ : ចំណូលមិនមែនសារពើភ័ណ

ជំពូក២០ : ផលទុននៃទ្រព្យសម្បត្តិរដ្ឋ ជំពូក២១ : ចំណូលផ្សេងៗដែលពុំមែនសារពើភ័ណ្ឌ។

**២.៣.២.២ ធាតុផ្សំនៃចំណូល**

ចំណូលរួមមានធាតុផ្សំចំនួន៥៖

- ការអនុញ្ញាតិឱ្យប្រមូលចំណូល រដ្ឋសភាអនុញ្ញាតិឱ្យរដ្ឋាភិបាល និងរដ្ឋបាលទារប្រាក់ ពន្ធ និងចំណូលផ្សេងទៀត។
- ការប៉ាន់ស្មានចំណូលអាចប្រមូលបាន។ ចំនួនទឹកប្រាក់នេះ វាអាស្រ័យដោយស្ថានភាព សេដ្ឋកិច្ច និង នយោបាយពន្ធដារ ដែលរដ្ឋសភាចង់តម្រង់ផ្លូវសម្រាប់ឆ្នាំបន្ទាប់ ។
- ចំនួនទឹកប្រាក់សរុបនៃការចំណាយ ត្រូវសម្រេចសម្រាប់ឆ្នាំដែលនឹងមកដល់។
- លក្ខខ័ណ្ឌទូទៅនៃតុល្យភាពថវិកា សរុបចំណូល សរុបចំណាយ និងសំណល់ថវិកា។
- គម្រោង និងការអនុញ្ញាតិនៃការខ្ចីបុល។

[30] ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានអនុម័ត ថ្ងៃទី ០៤ មេសា ២០០៨ មាត្រា១៥

- ចំណែកនីមួយៗនេះ ត្រូវពិក្សា និងអនុម័តមុនដោយរដ្ឋសភា ព្រោះគេត្រូវដឹងចំនួនទឹក ប្រាក់ចំណូល ដើម្បីគេអាចកំណត់ថា គេត្រូវចំណាយប៉ុន្មាន។

# ជំពូកទី២
# នីតិវិធីនៃការរៀបចំ ការអនុវត្តន៍
# ការអនុម័តថវិកា និង មុខងារ
# ទទួលខុសត្រូវ

# ជំពូកទី២
# នីតិវិធីការរៀបចំ ការអនុម័តថ និងការអនុវត្តន៍ថវិកា
## ផ្នែកទី១៖ ដំណើរការនៃនីតិវិធីនៃការរៀបចំ ការអនុម័តថវិកា
### ១.១ នីតិវិធីនៃការរៀបចំថវិកា

ដោយគោរពទៅតាមគោលការណ៍ ដែលយើងបានឃើញមកហើយ ថវិកាត្រូវបានអនុម័តដោយសភា រាជរដ្ឋាភិបាល ត្រូវមានភារៈកិច្ច រៀបចំគម្រោងថវិកា ទៅតាមបែបបទ ដែលក្នុង នីតិវិធីជាធរមាន ។

### ១.១.១ អង្គការមានសមត្ថកិច្ច

ការរៀបចំថវិកា គឺជាការងារដែលត្រូវប្រើពេលវេលាយ៉ាងវែងហើយធ្វើឡើងយ៉ាងប្រាកដកប្រជាទៀតផង ដូចនេះគេត្រូវមានមន្ត្រីជាច្រើនហើយមានឯកទេសទៀតផង។ ថវិកាត្រូវរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយជាពិសេសគឺនាយកដ្ឋានថវិកាដែលជា អ្នកទទួលបន្ទុកដោយផ្ទាល់។ ការរៀបចំគម្រោងថវិកា ជាភារកិច្ចរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ដែលធ្វើការក្រោមការណែនាំនៃរដ្ឋមន្ត្រីទីមួយ រួចហើយគម្រោងនេះ ត្រូវយកទៅឱ្យគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេចមុននិងបញ្ជូនទៅសភា។[31]

➢ **មុខងាររដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**

ស្ថិតនៅក្នុងអំណាចរបស់ក្រសួងរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុដាក់ជូនរដ្ឋាភិបាលពិនិត្យក្នុងលក្ខខណ្ឌដែលបានកំណត់។ ក្នុងក្របខណ្ឌចង្អុលទិសដែលកំណត់ដោយរដ្ឋាភិបាល ការរៀបចំថវិកា ត្រូវប្រមូលផ្តុំជាសារវន្តនៅលើមន្ត្រីក្រសួងហិរញ្ញវត្ថុ។ ពិតមែនតែក្រសួងហិរញ្ញវត្ថុតាមផ្លូវច្បាប់ពុំបានគ្រប់គ្រងក្រសួងទាំងឡាយក៏ដោយ ក៏ក្រសួងហិរញ្ញវត្ថុបានដាក់ចេញនូវការងារមួយចំនួនដល់ក្រសួងស្ថាប័នទាំងនេះអនុវត្តតាម ដែលមានកត្តាមួយចំនួនគឺ៖

-ក្រសួងលោកជាអ្នកប្រមូលពត៌មាន និងស្ថិតិសេដ្ឋកិច្ចទាំងអស់(វិទ្យាស្ថានស្ថិតិនាយកដ្ឋានព្យាករណ៍)។

-ក្រសួងនេះជាអ្នកកំណត់ចំណូលថវិកាទាំងមូលហើយធ្វើការសិក្សាលើឥទ្ធិពលដែលជះលើសេដ្ឋកិច្ច។

-ក្រសួងហិរញ្ញវត្ថុ ជាអ្នកប្រមូលគម្រោងថវិកានានា ដើម្បីយកមកពិនិត្យ និងអារកាត់។

-ជាពិសេសក្រសួងនេះពឹងផ្អែកលើនាយកដ្ឋានថវិកា ដែលជាអង្គការកណ្តាលមួយ មានភារកិច្ចធ្វើការសិក្សា និងរៀបចំវិកាទាំងមូល។

-ប៉ានស្មានចំនួនទឹកប្រាក់ ចំណុលដោយចាប់ផ្តើមសិក្សាលើអានុភាពនៃវិធានទាំងឡាយដែលទាក់ទងចំនាយ (ប៉ាន់ស្មាន) ជាអាទិ៍ ផ្នែកតាក់តែងផ្នែកច្បាប់ ពន្ធ នាយកដ្ឋានពន្ធដារទីចាត់ការគយជាដើម។

---

[31] មាត្រា ៣៧ នៃច្បាប់រៀបចំអង្គការស្តីពីច្បាប់ហិរញ្ញវត្ថុ

➢ **មុខងាររបស់រដ្ឋមន្ត្រីឯទៀតៗក្នុងរដ្ឋាភិបាល**

រដ្ឋមន្ត្រីក្រសួងនានា ( ក្រសួងចំណាយ ) ចូលរួមមកសាងនយោបាយស្តីពីថវិកា ក្នុងកិច្ចប្រជុំក្នុងគណៈរដ្ឋមន្ត្រី ដែលរៀបចំថវិកាផ្ទាល់របស់ក្រសួងខ្លួន សម្រាប់នាយកដ្ឋាននានា និងផ្នែកខាងក្រៅដែលបោះទីតាំងតាមខេត្តក្រុង។ គាត់ក៏ត្រូវចូលរួមផងដែរ ក្នុងឱកាសសម្រេចគម្រោង ថវិកាចុងក្រោមមុនដាក់ជូនរដ្ឋសភាអនុម័ត នៅក្នុងកិច្ចប្រជុំគណរដ្ឋមន្ត្រី។ ការរៀបចំថវិកាផ្ទាល់របស់ក្រសួងនីមួយៗ អ្នករៀបចំត្រូវតែពឹងផ្អែក ឬសមស្របតាមសារាចរ ណែនាំរបស់ក្រសួងហិរញ្ញវត្ថុប្រមូលផ្តុំពិនិត្យឡើងវិញ គ្រប់សំណូមពរឥណទាន ទាំងឡាយរបស់ផ្នែកដែលនៅក្រោមចំណុះ។ ក្រោយពេលរៀបចំស្រេចបាច់ហើយ គម្រោងចំណាយ ត្រូវដាក់ជូនមន្ត្រីអភិបាលហិញ្ញវត្ថុ ដើម្បីផ្តល់មតិរួចផ្ញើជូននាយកដ្ឋានថវិកា ក្រសួងហិរញ្ញវត្ថុ ដើម្បីកែសម្រួល និងបូកសរុប។ មុខងារនេះគឺនៅត្រឹមតែចូលរួមគណរដ្ឋមន្ត្រី ដើម្បីកំណត់នយោបាយព្រមទាំងរៀបចំថវិកាក្រសួងរៀងៗខ្លួនផង។ មុនបញ្ជូនគម្រោងថវិកាទៅឱ្យសភាពិនិត្យ និងអនុម័ត គណៈរដ្ឋមន្ត្រីត្រូវប្រជុំគ្នាដើម្បីសម្រេចជាចុងក្រោយ។ ក្នុងនោះសមាជិករដ្ឋាភិបាលអាចបញ្ចេញយោបល់បាន

➢ **ភារកិច្ចរបស់នាយករដ្ឋមន្ត្រី**

ភារកិចច្ចរបស់នាយករដ្ឋមន្ត្រីលោកជាអ្នកណែនាំតម្រង់ទិសដល់ករដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ ឱ្យរៀបចំគម្រោងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំដែលមកដល់។ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុដាក់សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុជូនសភាក្នុងនាមនាយករដ្ឋមន្ត្រី។ ក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីហិរញ្ញវត្ថុជាអ្នកអធិប្បាយអំពីមូលហេតុ និងការពារការជជែកពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនោះ។

➢ **មុខងារគណៈរដ្ឋមន្ត្រី**

គណៈរដ្ឋមន្ត្រីដែលត្រូវប្រជុំក្រោមអធិបតីភាព នាយករដ្ឋមន្ត្រី មានភារកិច្ចកំណត់ទិសដៅពីនយោបាយថវិកា និងអនុម័តសម្រេចលើគម្រោថវិកាមុនបញ្ជូនទៅសភា។

**១.១.២ ការប៉ាន់ស្មានចំណូល**

ជារួមផ្អែកលើលទ្ធផលសម្រេចក្នុងឆមាសទី១ និងនិន្នាការប្រមូលចំណូលឆមាសទី២ ខាងមុខនេះអាចសន្និដ្ឋានបានថា ការអនុវត្តចំណូលក្នុងប្រទេសទាំងថ្នាក់ជាតិ និងក្រោមជាតិឆ្នាំ២០២២ អាចនឹងសម្រេចបានខ្ពស់ជាង ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ចំនួនប្រមាណ ៦,៦% ដោយក្នុងនោះ៖[32]

- ចំណូលចរន្ត អាចនឹងអនុវត្តសម្រេចខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៤,៧% ដោយសារចំណូលសារពើពន្ធអាចនឹងសម្រេចខ្ពស់ជាង ច្បាប់ហិរញ្ញវត្ថុប្រមាណ ៥,០% ចំណែកឯចំណូលមិនមែនសារពើពន្ធអាចនឹងសម្រេចខ្ពស់ជាងច្បាប់ហិញ្ញវត្ថុប្រមាណ ១,៩%

[32] របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងលទ្ធផលប៉ាន់ស្មាននៃការអនុវត្តថវិកា ឆ្នាំ២០២២

- ចំណូលមូលធនថវិកា ត្រូវបានប៉ាន់ស្មានថា នឹងអាចអនុវត្តបានចំនួន ៣ ២១៣ ៧០៦ លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ២៤,៩% ដោយសារការកើនឡើងនៃការទទួលបានមូនិធិថវិកា។

ជាមួយនឹងការវាយតម្លៃលើការអនុវត្តចំណូលឆ្នាំ ២០២២ ខាងលើ ផ្នែកចំណូលនេះ នឹងជួបប្រទះ បញ្ហាប្រឈម និងហានិភ័យមួយចំនួន ដូចខាងក្រោម៖[33]

- ការបន្ថយអត្រាពន្ធអាករនាំចូលលើមុខទំនិញមួយចំនួនដើម្បីជួយជំរុញសហគ្រាសធុនតូច និងមធ្យម (SMEs) ព្រមទាំងវិស័យអាទិភាពផ្សេងទៀត
- ការលើកទឹកចិត្តពន្ធនិងអាករក្នុងគោលដៅទាក់ទាញការវិនិយោគ
- ការអនុវត្តអត្រាពន្ធគយអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា
- កំណើនផលិតផលក្នុងស្រុកមួយចំនួនជំនួសការនាំចូលជាពិសេសការកើនឡើងនៃវិនិយោគផ្គុំដំឡើងរថយន្តក្នុងប្រទេស
- កំណើនការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេង
- ការថយចុះនៃចំណូលពីរថយន្តគ្មានពន្ធមានស្រាប់ក្នុងប្រទេស
- វប្បធម៌សារពើពន្ធនៅមានកម្រិតនៅឡើយ
- និន្នាការកើនឡើងនៃការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក (E-Commerce) ដែលអាចបង្កជាហានិភ័យលើការគ្រប់គ្រងការងារប្រមូលចំណូល និងសុវត្ថិភាពសង្គម
- ឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ជាសកល នៅតែបន្តមានផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជា
- សង្គ្រាមនៅប្រទេសអ៊ុយក្រែន និងភាពតានតឹងខាងភូមិសាស្ត្រនយោបាយបានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចជាសកល
- ការកើនឡើងនូវតម្លៃប្រេង និងម្ហូបអាហារនាំឱ្យកើនឡើងនូវអត្រាអតិផរណាចំណូលរបស់ប្រជាជនធ្លាក់ចុះ និងកម្លាំងទិញធ្លាក់ចុះ
- ការថមថយកំណើនសេដ្ឋកិច្ចសកល
- ការបន្តប្រកាន់យកគោលនយោបាយគាំពារនិយម និង សង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាចសេដ្ឋកិច្ច
- កំណើននៃការធ្វើអាជីវកម្មតាមអនឡាញ ពិសេសក្នុងបរិការណ៍កូវីដ-១៩ ដែលក្នុងនោះមួយចំនួនធំមិនមានចុះបញ្ជីត្រឹមត្រូវនោះទេ ហើយចំនេះដឹងនៃកាប្រកាសពន្ធរបស់ប្រជាពលរដ្ឋក៏នៅមាន

[33] របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងលទ្ធផលប៉ាន់ស្មាននៃការអនុវត្តថវិកា ឆ្នាំ២០២២

កម្រិតដែរ ព្រមទាំងពុំទាន់មានលទ្ធភាពដំណើរការច្រកទ្វារអ៊ីនធឺណិតជាតិ (National Internet Gateway) និងច្រកចេញ-ចូល ប្រព័ន្ធទូទាត់សងប្រាក់ជាតិ (National Payment Gateway)

- សេដ្ឋកិច្ចស្រមោល (Shadow Economy) ដែលកើតមានក្នុងវិស័យសំខាន់ជាច្រើនរួមមាន វិស័យសាងសង់ វិស័យសហគ្រាសធុនតូច និងមធ្យម (SMEs) វិស័យធនធានធម្មជាតិ
- ការធ្វើបច្ចុប្បន្នភាពច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារមួយចំនួននៅមិនទាន់ឆ្លើយតបនឹងការវិវត្តទៅមុខនៃបរិបទសេដ្ឋកិច្ចកម្ពុជា
- ការកើនឡើងថ្លៃវត្ថុធាតុដើមដោយសារចរន្តទីផ្សារតំបន់ និងសាកល ដែលជះឥទ្ធិពលជារួមដល់ផលិតភាពនិងជារួមអាចធ្វើឱ្យមានការថមថយចំណូល
- អ្នកជាប់ពន្ធមួយចំនួននៅតែមិនទាន់អនុវត្តកាតព្វកិច្ចក្នុងការចុះបញ្ជីពន្ធដាររបស់ខ្លួនឱ្យបាន ត្រឹមត្រូវនៅឡើយ និងមានការក្លែងបន្លំឈរឈ្មោះជំនួសឱ្យក្រុមហ៊ុន ឬការប្រើប្រាស់ព័ត៌មានមិនពិតក្នុងការចុះបញ្ជី ការបង្កើតសហគ្រាសសិប្បនិម្មិតដើម្បីគេចវេះពន្ធ និងការមិនសហការផ្តល់ឯកសារចុះបញ្ជីឱ្យបាន គ្រប់គ្រាន់ ឬមិនមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស
- ការរួញរាក្នុងការចូលរួមអនុវត្តកាតព្វកិច្ចពន្ធលើចំណេញមូលធន (CGT) ពីសំណាក់វិស័យឯកជន បើទោះជាពន្ធនេះត្រូវបានច្បាប់អនុញ្ញាតឱ្យប្រមូលជាយូរណាស់មកហើយ និងមានការផ្សព្វផ្សាយទូលំទូលាយយ៉ាងណាក្តី
- ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើការក្នុងវិស័យទូរគមនាគមន៍ (Telecommunication) និងការផ្តល់សេវាអ៊ីនធឺណិតនៅមានកម្រិតនៅឡើយពុំទាន់ឆ្លើយតបតាមតម្រូវការកើនឡើងសម្រាប់ការប្រើប្រាស់ប្រព័ន្ធ និង កម្មវិធីផ្សេងៗជូនអ្នកជាប់ពន្ធ និង ការគ្រប់គ្រងរដ្ឋបាលសារពើពន្ធឱ្យបានល្អប្រសើរ
- មុខសញ្ញាចំណូលសំខាន់ៗធ្លាក់ចុះដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ប្រមូលមិនទាន់អស់លទ្ធភាព
- កង្វះការសិក្សាអំពីលទ្ធភាពក្នុងការស្វែងរកប្រភពចំណូលថ្មី
- សមត្ថភាពមន្ត្រី និងប្រសិទ្ធភាពស្ថាប័ន នៅមានកម្រិត
- ត្រូវការពេលវេលាមួយសមស្របដើម្បីធ្វើការកែទម្រង់ការប្រមូលចំណូលលើវិស័យទូរគមនាគមន៍ ធនធានរ៉ែ និងសម្បទានដីសេដ្ឋកិច្ច
- កង្វះយន្តការផ្ទៀងផ្ទាត់ ក្នុងការប្រមូលចំណូល ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- ភាពខ្វះចន្លោះនៃបទប្បញ្ញត្តិគាំទ្រ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលមិនមែនសារពើពន្ធ

- ភាពមិនទាន់បានយកចិត្តទុកដាក់ខ្ពស់ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកែលម្អតាមវិធានការរបស់អធិការកិច្ច និងអនុសាសន៍របស់សវនកម្មលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- អាជីវកម្មកាស៊ីណូនៅតាមព្រំដែនមានស្ថានភាពបើក-បិទមិនទៀងទាត់។

ការប៉ាន់ស្មានចំណូលពន្ធគយត្រូវគិតគូរវាយតម្លៃពីប្រាក់ចំណូល គិតគូរពីឥទ្ធិពលដែលជះអតិផរណាទៅលើមូលដ្ឋានគិតពន្ធប៉ាន់ស្មានលើការវិវត្តន៍សេដ្ឋកិច្ចនាពេលខាងមុខ ការប្រែប្រួលដែលកើតមានហើយ ឬ ត្រូវពិចារណាពីអត្រាមូលដ្ឋានប្រមូលពន្ធ និង ផលចំណូលដែលបានមកពីការបង្កើតអាករថ្មី។ ការប៉ាន់ស្មានចំណូលបានមកពីសមិទ្ធិផលនៃបេតិកភ័ណ្ឌជាតិ មានចលនៈកម្ម ឬអចលនៈកម្មរបស់រដ្ឋ គឺជាកម្មវត្ថុនៃការប៉ាន់ស្មានពីសំណាក់គ្រប់ក្រសួង ឬ អង្គការសាធារណៈ ប្រហាក់ប្រហែលដែលជាអ្នកអនុវត្ត កិច្ចប្រតិបត្តិការនោះ។ ចំណូលផលទាំងនេះ ត្រូវចុះចំណូលជាមូលធនក្នុងថវិកាទូរទាត់របស់រដ្ឋ។ សរុបចំណូលបានមកពីការខ្ចីបុល ដែលអនុញ្ញាតពីរដ្ឋាភិបាលដែលជំនួយអំណោយគឺគិតគូរតាមលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង។

### ១.១.៣ ការប៉ាន់ស្មានចំណាយ

បើគេគិតទៅដល់ការរៀបចំថវិកា សម្រាប់អនុវត្តន៍នាឆ្នាំខាងមុខ រដ្ឋាភិបាលនឹងធ្វើនូវគម្រោង ថវិកាមួយជិតមកដល់កម្ពស់ ដែលគេចង់បាន ក្នុងគោលបំណងមានមធ្យោបាយ ហិរញ្ញវត្ថុគ្រប់គ្រាន់ណាដើម្បីដឹកនាំនយោបាយរបស់ខ្លួនឱ្យបានល្អប្រសើរ។ ប៉ុន្តែប្រការនេះ មិនអាចធ្វើបានតាមចិត្តបានទេ ព្រោះថាសេរីភាពរបស់រដ្ឋាភិបាល មានកម្រិតជាទីបំផុត សម្រាប់គេគិតគូរពីចំណាយទាំងបីដូចខាងក្រោម៖

➢ **សារៈសំខាន់ចំណាយដែលមិនអាចផាត់ចេញបាន**

មានចំណាយមួយចំនួនដែលចាំបាច់ត្រូវគ្រោង ហើយគេមិនអាចសន្សំសំចៃបានឡើយចំពោះចំណាយទាំងនេះ បៀវត្សរ៍របស់មន្ត្រីរាជការ រំលស់បំណុល សោហ៊ុយចំណាយ ដំណើរការសម្រាប់រដ្ឋបាល...។ គេមិនអាចនិយាយបានថាចំណូលមានកម្រិត ឬកម្រិតតិចតួចនៅឆ្នាំនេះត្រូវផ្អាករងចាំចំណូលគ្រប់គ្រាន់ទើបអាចផ្តល់ការចំណាយទាំងអស់បាន។ ឧទាហរណ៍ ចំណាយដែលជាបន្ទុកបំណុល ចំនួនទឹកប្រាក់ដែលត្រូវរំលោះបំណុល និងការប្រាក់ដែលត្រូវសង នៅឆ្នាំខាងមុខមានប្រមាណ១០% ទៅ ២០% ប្រៀបធៀបសរុបទឹកប្រាក់ចំណាយប្រចាំឆ្នាំ។ ប្រសិនបើរដ្ឋមិនសង ( រំលោះបំណុលនិងការប្រាក់ ) ទេវានឹងអាចមាការលំបាកដល់ធនាគារ ហើយជាពិសេសអ្នកឱ្យខ្ចីអន្តរជាតិ។

➢ **ការរឹតត្បិតចំណាយវិនិយោគ**

គម្រោងសេចក្តីត្រូវការអំពីសម្ភារៈ ( សង់សាលារៀន មន្ទីពេទ្យ ផ្លូវថ្នល់...) ជាទូទៅអនុវត្តជាច្រើនឆ្នាំភាគច្រើន ៣ឬ៤ឆ្នាំ។ កាលណាផ្លូវថ្នល់ ឬសាលារៀនចាប់ផ្តើមធ្វើគេមិនអាចបញ្ឈប់ការងារ មុនពេលបញ្ចប់ឬការព្យួរការងារទុកបានឡើយ។

### ➢ លក្ខណៈអទិភាព នៃបេសកម្មព្រះរាជសិទ្ធិរបស់រដ្ឋ

ដែលហៅថា បេសកម្មព្រះរាជសិទ្ធិ គឺគ្រប់ចំណាយទាំងឡាយ ដែលរដ្ឋត្រូវបំពេញ លើបេសកម្មធំៗ ជាអធិបតេយ្យជាតិ ហើយមានតែរដ្ឋទេដែលជាអ្នកទទួលបន្ទុក សន្តិសុខជាតិ សុខាភិបាល អប់រំ តុលាការ ការពារប្រទេសជាដើមដែលសម្រាប់ចំណាយ រដ្ឋាភិបាលត្រូវតែបំពេញ ឱ្យបានគ្រប់គ្រាន់។ ឧទាហរណ៍ៈ មានចំនួនសិស្សកើនឡើងគេត្រូវជ្រើសរើសគ្រូឱ្យបានគ្រប់គ្រាន់ ឬ ក៏ត្រូវឱ្យមានអាគារគ្រប់គ្រាន់។ ជារួមការប៉ាន់ស្មានចំណាយត្រូវតែ ញែកឱ្យបាន ពីទឹកប្រាក់ដែលបានអនុម័ត និង វិធានការថ្មីធ្វើយ៉ាងនេះ ទើបការប៉ាន់ស្មានមានលក្ខណៈងាយស្រួល ចំណាយថ្មី ត្រូវសមស្របជាមួយអ្វីដែលបង្កើតថ្មី ។ ទន្ទឹមនឹងនេះការប៉ាន់ស្មានក៏ត្រូវផ្អែកលើ សេចក្តីត្រូវការទាំងឡាយ ដែលទាក់ទងដល់កម្មវិធីសកម្មភាពពីទិសដៅ លក្ខខ័ណ្ឌទទួលបានដោយកំណត់យ៉ាងច្បាស់លាស់ និងរក្សារាល់ខ្ទង់ចំណាយ ដែលមាននៅក្នុងកម្មវិធី។ ការចំណាយជាមូលធន ត្រូវផ្អែកលើការអនុញ្ញាតិនៃកម្មវិធី ឬទាក់ទងដល់គម្រោងដោយឡែក ដែលមានការយល់ព្រមពីមុនមក ។

បើការប៉ាន់ស្មាន និងការវាយតម្លៃលើការអនុវត្តចំណាយឆ្នាំ ២០២២ ជាមួយនឹងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រីរាជការ ចំណាយបន្ទុកបុគ្គលិក ពិសេសបៀវត្ស របស់មន្ត្រីរាជការឆ្នាំ ២០២២ ត្រូវបានរក្សាកម្រិតប្រាក់បៀវត្សអប្បបរមា និងប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និង កម្លាំងប្រដាប់អាវុធ ស្មើនឹងកម្រិតឆ្នាំ ២០២១ ដើម្បីសន្សំថវិកាសម្រាប់ទប់ទល់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបានបង្កនូវផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ចសង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសកម្មករនិយោជិកក្នុងវិស័យកាត់ដេរ និងវាយនភណ្ឌ កម្មករក្រៅប្រព័ន្ធ ព្រមទាំង ប្រជាជនក្រីក្រ និងជនងាយ រងគ្រោះ។ តាមរយៈវិធានការខាងលើ នៅក្នុងឆ្នាំ ២០២២, បៀវត្សអប្បបរមាមន្ត្រីរាជការស៊ីវិល ត្រូវបានរក្សា ស្មើនឹងប្រមាណ ១១៧២ ៥០០ រៀល បៀវត្សអប្បបរមាគ្រូបង្រៀន និងគ្រូពេទ្យ ត្រូវបានរក្សាស្មើនឹង ប្រមាណ ១ ២៧២ ៥០០រៀល បៀវត្សអប្បបរមានគរបាលជាតិ (ពលបាលត្រី) ត្រូវបានរក្សាស្មើនឹងប្រមាណ ១ ២៥៦ ៩៧៧ រៀល (គិតបញ្ចូលរបបអង្គរ) បៀវត្សអប្បបរមាយោធិន (ពលទោ) រក្សាស្មើនឹង ប្រមាណ ១ ១២៣ ៥០០ រៀល (មិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលរបបអង្គរត្រូវជាប្រមាណ១ ១៨១ ៩៧៧ រៀល។ ចំពោះប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យា ក៏ត្រូវបានរក្សាស្មើនឹងចំនួន ៦៧ ម៉ឺនរៀល ផងដែរ។ ទន្ទឹមនេះមន្ត្រីរាជការទូទៅ ក៏ដូចជានិវត្តជនជាអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ក៏ត្រូវបានផ្តល់ ប្រាក់ឧបត្ថម្ភ ៥ ម៉ឺនរៀល សម្រាប់ការចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាល ក៏បានផ្តល់ថវិកាសម្រាប់ការអនុវត្តមូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីរ៉ាប់រងលើការទ្រទ្រង់ថែទាំសុខភាពមន្ត្រីសាធារណៈ បន្ថែមពីលើប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គម ចំនួនពីរ គឺ ប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រីនិងប្រាក់ ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការដែលទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬ គ្រោះ

ថ្នាក់ការងារ ដើម្បីរៀបចំពិធីបុណ្យសពតាមប្រពៃណី ដែលត្រូវបានដាក់ឱ្យអនុវត្តរួចមកហើយ និងសម្រាប់កញ្ចប់ថវិកាទ្រទ្រង់ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ។

នៅក្នុងឆ្នាំ ២០២២ នេះដែរ រាជរដ្ឋាភិបាលបានសម្រេច និងកំពុងរៀបចំនីតិវិធីដើម្បីដំឡើងរបបសោធនអប្បបរមារបស់និវត្តជនជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ព្រមទាំងដើម្បីកាត់បន្ថយគម្លាតរវាង អ្នកចូលនិវត្តន៍ចាស់ និងអ្នកចូលនិវត្តន៍ថ្មី ដែលត្រូវចំណាយថវិកាប្រមាណ ៧០ ប៊ីលានរៀល សម្រាប់អនុវត្ត ១២ ខែ (ខែ មករា ដល់ខែ ធ្នូ)។

ចំណែកឯចំណាយមិនមែនបន្ទុកបុគ្គលិក របស់ក្រសួង-ស្ថាប័ន ក្នុងឆមាសទី ២ ខាងមុខ អាចនឹងមានសន្ទុះលឿនជាងនៅក្នុងឆមាសទី ១ ហើយនឹងត្រូវបានតម្រង់ការអនុវត្តចំណាយឱ្យចំទិសដៅ ព្រោះមានការដាក់ចេញវិធានការចាំបាច់មួយចំនួនដើម្បីជំរុញការអនុវត្តចំណាយនៅឆមាសទី២ នេះផង និងពង្រឹងប្រសិទ្ធភាពប្រតិបត្តិចំណាយផងដែរ។ លើសពីនេះ កញ្ចប់ឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ដែល មានចំនួន ១ ៦១៨ ២៦៤ លានរៀល គិតត្រឹមឆមាសទី ១ ឆ្នាំ ២០២២ បានផ្ទេរចេញទៅក្រសួង-ស្ថាប័ន ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់នានា ក៏ដូចជាការអនុវត្តអាទិភាពគោលនយោបាយបន្ទាន់របស់រាជរដ្ឋាភិបាល ចំនួន ១៣៥ ១៨៧ លានរៀល រួចហើយ។ ឥណទាននៅសល់ក៏មានមុខសញ្ញាចំណាយហើយដែរ ពិសេសគឺ ការត្រៀមសម្រាប់ចំណាយចាំបាច់មួយចំនួនផ្សេងទៀតរបស់រាជរដ្ឋាភិបាល នាពេលខាងមុខនេះ។ ជារួមផ្អែកលើលទ្ធផលអនុវត្តក្នុងឆមាសទី ១ និងនិន្នាការចំណាយឆមាសទី ២ អាចសន្និដ្ឋានបានថា ការអនុវត្តចំណាយឆ្នាំ ២០២២ នឹងទាបជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ បន្តិចបន្តួច ក្នុងរង្វង់ប្រមាណ 0,២% ដោយសាររាជរដ្ឋាភិបាល បាននិងកំពុងកាត់បន្ថយចំណាយលើចំណាយអន្តរាគមន៍ ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ព្រោះស្ថានភាពវិបត្តិនៃជំងឺកូវីដ-១៩ បាននិងកំពុងមានភាពធូរស្បើយច្រើន។ ដូចនេះ ផ្អែកលើលទ្ធផលនៃការអនុវត្តចំណាយតាមផែនការដែលបានគ្រោងទុក និងប្រកបដោយប្រសិទ្ធភាពខ្ពស់នេះរាជរដ្ឋាភិបាលនឹងសម្រេចបានគោលដៅ និងសមិទ្ធកម្មដែលកើតចេញពីការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលរួមមាន៖ ការបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជនរក្សាលំនឹង សង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងការស្តារជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ទន្ទឹមនឹងការបន្តនិរន្តរភាពប្រតិបត្តិការរបស់រដ្ឋក្នុងបរិការណ៍កូវីដ-១៩ ការអភិវឌ្ឍធនធានមនុស្សកាន់តែមានគុណភាពខ្ពស់ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តការលើកកម្ពស់គុណភាពសេវាសុខាភិបាលឱ្យកាន់តែល្អប្រសើរការអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្មការកែលម្អប្រព័ន្ធអប់រំឱ្យកាន់តែមានគុណភាព ខ្ពស់ ការពង្រឹងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសការជំរុញអនុវត្តកម្មវិធីថ្មីៗនៃគោលនយោបាយ ក្នុងវិស័យសង្គមកិច្ចពាក់ព័ន្ធនឹងការគាំពារសង្គម ដោយឈរលើគោលការណ៍ប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជន៍ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។

ជាមួយនឹងការវាយតម្លៃអំពីទិដ្ឋភាពនៃការអនុវត្តចំណាយថវិកាកន្លងមកនិងរហូតដល់ដំណាច់ឆ្នាំ ផ្នែកចំណាយអាចជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការធានាប្រសិទ្ធភាពផ្នែកប្រតិបត្តិការចំណាយ (ចាយឱ្យចំមុខសញ្ញា និងចាយតែចំណាយ ចាំបាច់មិនចាយលើមុខសញ្ញាមិនចាំបាច់ ឬមិនទាន់ចាំបាច់ និងការធានា "តម្លៃនៃលុយ) នៅជាបញ្ហាប្រឈម នៅឡើយ នៅក្នុងការអនុវត្តចំណាយរបស់ក្រសួង-ស្ថាប័នមួយចំនួន សមត្ថភាពរបស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ រដ្ឋទេយ្យករបុរេប្រទាន និងក្រុមលទ្ធកម្ម នៅមិនទាន់ យល់ច្បាស់អំពីនីតិវិធីហិរញ្ញវត្ថុដែលមានជាធរមាននៅឡើយ។ ប្រការនេះ នាំឱ្យការអនុវត្តចំណាយមិនមែនបន្ទុក បុគ្គលិករបស់ក្រសួង-ស្ថាប័នខ្លះនៅមានសន្ទុះយឺតបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១
- ការអនុវត្តចំណាយមិនមែនបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័នខ្លះ នៅក្នុងឆមាសទី ១ នៃឆ្នាំ ២០២២ នេះ មានសន្ទុះយឺតបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ គឺដោយសារការផ្តល់ធានាចំណាយ នៃចំណាយចរន្តត្រូវបានចែកជាពីរជំហាន លើមុខសញ្ញាចំណាយកិច្ចលទ្ធកម្មដែលមានទំហំឥណទានធំជាង ១ ០០០ លានរៀល។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់ធានាចំណាយត្រឹម ៥០% សិន នៅឆមាសទី ១ ដើម្បីត្រៀមទប់ទល់នឹងការធ្លាក់ចុះចំណូលជាយថាហេតុ ពីការបន្តទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និង ផលប៉ះពាល់ពីសង្គ្រាមនៅអ៊ុយក្រែន
- ការស្នើសុំធានាចំណាយកិច្ចលទ្ធកម្ម ដោយគ្មានផែនការលទ្ធកម្ម ដោយសារមិនបានដាក់បញ្ចូលមុខសញ្ញាចំណាយដែលត្រូវធ្វើលទ្ធកម្មទៅក្នុងផែនការលទ្ធកម្ម ក្រោយមានការកែសម្រួលតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន
- ទន្ទឹមបញ្ហាប្រឈមកើតមានឡើងលើការអនុវត្តផ្នែកចំណាយចរន្តរបស់ក្រសួង-ស្ថាប័នមួយចំនួន ដែលទទួលបាននូវឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុក ក៏មានការយឺតយ៉ាវនៅក្នុងការអនុវត្ត ចំណាយនេះផងដែរ គឺដោយសារការកើនឡើងនៃតម្លៃប្រេង និងតម្លៃសម្ភារៈ ក្រសួងស្ថាប័នមួយចំនួន បានស្នើសុំដកសំណើសុំធានាចំណាយទៅវិញ ដើម្បីកែសម្រួលទឹកប្រាក់គម្រោងឱ្យស្របតាមតម្លៃប្រេង និង សម្ភារជាក់ស្តែង និង ម្យ៉ាងទៀត ក្រសួង-ស្ថាប័នខ្លះបានស្នើសុំកែប្រែទឹកប្រាក់គម្រោង និងយថាប្រភេទ បន្ទាប់ពីទទួលបានគោលការណ៍ធានាចំណាយរួចហើយ និងក្រសួង-ស្ថាប័នខ្លះទៀតស្នើសុំធានាចំណាយ យឺតយ៉ាវ ទោះបីមានគោលការណ៍រួចហើយក៏ដោយ។ ទន្ទឹមនេះ ភ្លៀងធ្លាក់ច្រើននាដើមរដូវវស្សា ធ្វើឱ្យប៉ះពាល់ ដល់វឌ្ឍនភាពជារូបវន្តនៃការងារសាងសង់ ជួសជុល ហេដ្ឋារចនាសម្ព័ន្ធ

សាធារណៈ ដែលនាំឱ្យប៉ះពាល់ដល់ ការទូទាត់ថវិកា ជាពិសេសក្រសួងធំៗ ដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូនក្រសួងអភិវឌ្ឍន៍ជនបទ។[34]

## ១.២ បរិបទ និង ប្រតិទិននៃការរៀបចំថវិកានៅកម្ពុជា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រតិទិន ដូចខាងក្រោម :

### ១.២.១ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែមីនាដល់ឧសភា) ៖[35]

នៅសប្តាហ៍ទី១ នៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលមានសង្គត់ភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍដើម្បីដាក់ជូន រាជរដ្ឋាភិបាលពិនិត្យ។

នៅសប្តាហ៍ទី១ នៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញណែនាំស្តីអំពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយសេដ្ឋកិច្ច និងត្រូវចេញសារាចរណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រ ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលបានកំណត់ដោយរាជរដ្ឋាភិបាល។ ក្រសួងប្រធានគ្រប់ស្ថាប័ន ប្រធាន អង្គភាព សាធារណៈប្រហាក់ប្រហែលអភិបាល នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ថវិការបស់ខ្លួន។ ដែលផែនការយុទ្ធសាស្ត្រថវិកា ទាំងនេះត្រូវផ្ញើមក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែឧសភា។

### ១.២.២ ការរៀបចំកញ្ចប់ថវិកា (ពីខែមិថុនា ដល់ខែកញ្ញា) ៖[36]

នៅសប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេស នៃការរៀបចំ កម្រោងថវិកាដោយបញ្ជាក់ជូននូវទម្រង់បែបបទ និង នីតិវិធី នៃការរៀបចំគម្រោងថវិកាព្រមទាំងធ្វើកំណត់បង្ហាញ និងឯកសារពាក់ព័ន្ធ ដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចហើយផ្ញើជូននូវក្រសួងស្ថាប័ននានា ដើម្បីរៀបចំគម្រោងចំណូលចំណាយថវិកាលម្អិតរបស់ខ្លួន។ ក្រសួងស្ថាប័ននានាត្រូវផ្ញើគម្រោងថវិកាមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុត ត្រឹមថ្ងៃទី ១៥ ខែកក្កដា។ នៅក្នុងកំឡុង ខែសីហា ទាំងមូលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អញ្ជើញរដ្ឋមន្ត្រីក្រសួងនានាមកពិភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូលចំណាយ ដោយមានការកាត់បន្ថយនូវចំណាយណាខ្លះដែលមិនចាំបាច់ និងបង្កើនចំណូលខ្លះបើអាចធ្វើបាន។ ក្នុងកំឡុងខែកញ្ញាទាំងមូល

[34] របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងលទ្ធផលប៉ាន់ស្មាននៃការអនុវត្តថវិកា ឆ្នាំ២០២២

[35] មាត្រា ១៩ កម្រងច្បាប់ស្តីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ទំព័រ ១៨

[36] ចំណុចទី២ នៃមាត្រា ៣៩ កម្រងច្បាប់ស្តីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ទំព័រ ១៩

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញ រួចរៀបចំ សេចក្តីព្រៀងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ។

**១.២.៣ ការអនុម័តថវិកា ( ពីខែ តុលាដល់ខែធ្នូ )**

សប្តាហ៍ទីមួយនៃខែតុលាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេចរួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃ ខែ វិច្ឆិកា ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទី១ នៃខែធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុខថ្ងៃ២៥ ខែធ្នូ។[37]

## ១.៣ នីតិវិធីនៃការអនុម័តថវិកាប្រចាំឆ្នាំ

ការពិនិត្យ និងអនុម័តថវិកាប្រចាំឆ្នាំ ត្រូវយោលទៅតាមនីតិវិធីធម្មតា ដូចច្បាប់ឯទៀតផងទៅតាមនីតិវិធីពិសេសផង។

**១.៣.១ នីតិវិធីធម្មតា**

នីតិវិធីធម្មតា មានចំណុចបីដែលត្រូវកត់សំគាល់៖[38]

មុននឹងយកទៅដាក់ឱ្យសភាពិនិត្យ ក្នុងសម័យប្រជុំពេញអង្គ ថវិកាត្រូវតែដាក់ឱ្យគណៈកម្មការថវិកាពិនិត្យជំនាញនៅរដ្ឋសភាពិនិត្យជាមុនសិន ព្រោះវាជារឿងបច្ចេកទេសស៊ាំញ៉ាំបន្តិច ដល់ពិនិត្យរួចហើយគណៈកម្មការនេះត្រូវធ្វើរបាយការណ៍ (របាយការណ៍មួយ ស្តីពីទិដ្ឋភាពទូទៅនៃថវិកា របាយការណ៍ផ្សេងៗទៀតស្តីពីទិដ្ឋភាពគ្រប់គ្រងផ្នែកថវិកា) ដាក់ជូនសភាពេល ប្រជុំពេញអង្គ។ ឯកសារដែលសភាត្រូតពិនិត្យនោះ គឺជាឯកសារដែលរដ្ឋាភិបាលបានរៀបចំជូនមក។ គណៈកម្មការមានសិទ្ធិតែកែច្នៃធ្វើវិសោធនកម្មបន្តិចបន្តួច ឬសំណើរសុំទាត់ចោល។ រដ្ឋាភិបាលមានសិទ្ធិដាក់សម្ពាធលើសភា ដោយអាចប្រើមាត្រាខ្លះនៃច្បាប់រដ្ឋធម្មនុញ្ញដូចជាមាត្រា ៤៤ ដែលអនុញ្ញាតិឱ្យមានការអនុម័តទាំងដុំៗ សរុបទាំងអស់មិនឱ្យនិយាយពីភាគតូចៗនានាបានទេ ។

**១.៣.២ នីតិវិធីពិសេសក្នុងការអនុម័តថវិកា**

ភាពពិសេសនេះមាន៦យ៉ាងមានដូចជា៖[39]

១. កាលណាអំណាចនីតិប្បញ្ញតិមានសភាពីរ គេតែងតែផ្តល់តួនាទីចម្បងដល់រដ្ឋសភា ដែលមានភារៈកិច្ចអនុម័តច្បាប់ថវិកាមុនព្រឹទ្ធសភា។ បើសិនជាព្រឹទ្ធសភាពុំព្រមអនុម័តថវិកានោះទេរដ្ឋសភាមានសិទ្ធិអនុម័តតែម្នាក់ឯង។

---

[37] ចំណុចទី៣ មាត្រា ៣៩ កម្រងច្បាប់ស្តីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ទំព័រ ១៩

[38] សំ សុខ នីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១០៨

[39] សំ សុខ នីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១០៨-១០៩

២. ដើម្បីជម្រុញឱ្យការពិនិត្យថវិកាធ្វើទៅបានឆាប់រហ័ស គម្រោងថវិកាត្រូវតែបញ្ជូនទៅដល់រដ្ឋសភា ឱ្យបានមុនថ្ងៃអង្គារ ដំបូងនៃខែតុលា ជាកំហិត។ រដ្ឋសភាត្រូវពិនិត្យនិងអនុម័តលើក ទី១ ឱ្យបានមុន៤០ថ្ងៃ ចាប់តាំងពីថ្ងៃទទួល។ ក្នុងករណីដែលរដ្ឋសភាមិនបានអនុម័តថវិកាក្នុង រយៈពេល៤០ថ្ងៃ រដ្ឋាភិបាលត្រូវអញ្ជើញព្រឹទ្ធសភាឱ្យអនុម័តថវិកាភ្លាម។ ព្រឹទ្ធសភាត្រូវអនុម័តថវិកាក្នុងរយៈ ពេល១៥ថ្ងៃ។

៣. បើសិនជាមានការយឺតយ៉ាវក្នុងការរៀបចំថវិកា ជាហេតុបណ្តាលឱ្យសភាមិនអាច អនុម័តថវិកានេះ មុនដើមឆ្នាំនីមួយៗ គេអនុញ្ញាតឱ្យមានច្បាប់មួយ ដែលប្រគល់សិទ្ធិឱ្យរដ្ឋាភិបាលត្រូវរៀបចំជាក្រឹត្យ ដើម្បីចែកចាយចំណាយជាបណ្តោះអាសន្នដែលក្រសួងនានា។

៤. ក្នុងករណីដែលសភាទាំងពីមិនអាចអនុម័តថវិកា ក្នុងរយៈពេល៧០ថ្ងៃ ចាប់តាំងពីថ្ងៃទទួលនៅរដ្ឋសភា រដ្ឋាភិបាលមានសិទ្ធិដាក់ថវិកាអនុវត្តដោយខ្លួនមិនចាំបាច់មានការសម្រេចរបស់សភា។

៥. មាជិកាសភាមិនអាចមានសិទ្ធិទូលំទូលាយ ដើម្បីដើម្បីធ្វើវិសោធនកម្មលើគម្រោង ជាពិសេសមិនអាចមានលទ្ធភាព បញ្ចូលសំណើណាដែលគ្មានទំនាក់ទំនងជាមួយថវិកា ឬក៏មានបំណងចង់បន្ថយឥណទានខ្លះ។

៦. ការបោះឆ្នោតអនុម័ត ត្រូវគោរពទៅតាមបទបញ្ជាច្បាស់លាស់។ គេបានកម្រិតចំនួនដូចខាងក្រោម ៖

- ចំណូល៖ បោះឆ្នោត ១ ដង ចំពោះថវិកាទូទៅ
  : បោះឆ្នោត ១ ដង ចំពោះថវិកាឧបសម្ព័ន្ធ
  : បោះឆ្នោត ១ ដង ចំពោះគណនីពិសេសរតនាគារ។
- ចំណាយ បោះឆ្នោតសរុប ១ដង សម្រាប់សេវាដូចឆ្នាំចាស់ បោះឆ្នោត ១ដង ចំពោះប្រភេទចំណាយមួយៗនៃក្រសួងនីមួយៗសម្រាប់ឥណទានវិធានការថ្មី។
- ចំពោះចំណាយនៃថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារគេត្រូវបោះឆ្នោតអនុម័តថវិកាមួយម្តងៗ ឬគណនីមួយម្តងៗ រហូតដល់អស់។

ជាសរុបសភាត្រូវបោះឆ្នោតអនុម័តប្រហែល ២០០ដង គួររំលឹកថានៅជំនាន់មុនកាលសម័យសាធារណរដ្ឋទី៤ សភាត្រូវបោះឆ្នោតប្រហែល ២០០ដង ពោលគឺលើសគុណនឹង១០ដងឯណោះ។

### ១.៣.៣ ករណីច្បាប់ខ្មែរក្នុងការអនុម័តថវិកា

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ពុំបានកំណត់ឱ្យច្បាស់នូវរយៈពេលដែលរដ្ឋសភា និងព្រឹទ្ធសភាត្រូវអនុម័តពីរឿងថវិកាទេ។ ប៉ុន្តែ ចាប់ផ្តើមនៅថ្ងៃ១ មករា ហើយបញ្ចប់នៅថ្ងៃ៣១ ខែធ្នូ។[40] បានសេចក្តីថាសភាទាំង២ ត្រូវអនុម័ត

[40] មាត្រា ៤ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ១៩៩៣

ថវិកាឱ្យបានមុនដាច់ឆ្នាំជាកំហិត ដើម្បីឱ្យថវិកាអាចយកទៅអនុវត្តបាននៅថ្ងៃ ទី១មករា។ ម្យ៉ាងទៀតមាត្រា ១១៣ថ្មី បានចែងជាទូទៅថា ក្នុងករណីដែលមានការខ្វែងយោបល់គ្នារវាងរវាងសភាទាំងពីរ ការបង្វិលទៅបង្វិលមក ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។[41] បើជាករណីច្បាប់ថវិកាហិរញ្ញវត្ថុត្រូវបន្ថយមកនៅត្រឹមដប់ថ្ងៃ ហើយមកត្រឹមតែពីរថ្ងៃបើជាការប្រញាប់ ។

## ផ្នែកទី២៖ ដំណាក់កាលនៃការអនុវត្តថវិកា

### ២.១ មុខងារអាណាប័ក

អាណាប័ក គឺជាភ្នាក់ងាររដ្ឋបាលដែលត្រូវតែងតាំង ហើយស្ថិតនៅលើគេបង្អស់នៃក្រសួង រាជធានី ខេត្ត នៃគ្រឹះស្ថានសាធារណៈ និង នៃសេវាមួយ។ អាណាប័ក ក្នុងពេលប្រតិបត្តិមុខងាររដ្ឋបា លដ៏សំខាន់ មានតួនាទីផ្នែកហិរញ្ញវត្ថុទាំងខាងចំណូល និង ចំណាយ។ គឺក្នុងឋានៈជាអ្នកសម្រេច ឬ ជាប្រធានស្ថាប័ននេះ ហើយដែលខ្លួនមានមុខងារជាអាណាប័ក។

អាណាប័កបញ្ជាប្រតិបត្តិចំណូល និង បញ្ជាចំណាយ ...។ ចំពោះបញ្ហានេះ អាណាប័កពិនិត្យ អនុវត្តសិទ្ធិទាំងឡាយរបស់រដ្ឋជម្រះចំណូលសន្យា និងជម្រះចំណាយ។[42] ការអនុវត្តន៍កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ និង គណនេយ្យពិសេសរបស់រត នាគារ ជាភារកិច្ចរបស់អាណាប័ក និង គណនេយ្យករ។[43]

អាណាប័កចេញដីកាចំណូលសម្រាប់ការធានាការប្រមូលតណទេយ្យរបស់រដ្ឋ។ អាណាប័ក បញ្ជូនដីកាចំណូលទៅគណនេយ្យករសាធារណៈ ដែលទទួលបន្ទុកទារប្រមូល។[44] មានមុខងារសម្រេចលើចំណាយ (ទិញសម្ភារៈរដ្ឋបាលធ្វើលទ្ធកម្មសាធារណៈ ទូទាត់បៀវត្សរ៍បុគ្គលិក ធ្វើវិនិយោគ) ។[45] អាណាប័កមានពីរប្រភេទ អាណាប័កដើមខ្សែ (តាមទ្រឹស្តីគឺរដ្ឋមន្ត្រី ដែលជាប្រធានស្ថាប័ន) តាមការជាក់ស្តែង រដ្ឋមន្ត្រីដោយសារមានការងារច្រើន បានធ្វើប្រតិភូកម្ម ទៅឱ្យមន្ត្រីនៅក្រោមបង្គាប់ (នៅខ្មែរឱ្យរដ្ឋលេខាធិការ នៅបារាំងឱ្យប្រធាននាយកដ្ឋាន ឬនាយកខុទ្ទកាល័យ )។ អាណាប័កផ្ទេរសិទ្ធិ ជាអាណាប័ក ដែលនៅតាមខេត្ត ក្រុងពោលគឺ អភិបាលខេត្ត ក្រុង។ អាណាប័កមានមុខងារបញ្ជាទៅលើប្រតិបត្តិការចំណាយចំណូលទាំងអស់របស់រដ្ឋ ហើយមុខងារនេះមានវិសមិតភាព[46]ជាមួយ និងមុខងាររបស់គណនេយ្យករ រដ្ឋមន្ត្រីនីមួយៗ ជាអាណាប័កដើមខ្សែក្នុងក្រសួងរបស់

[41] មាត្រា ១១៣ថ្មី ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ១៩៩៣

[42] មាត្រា ៣ នៃបទបញ្ជា ទូទៅនៃគណនេយ្យ សាធារណៈអនុក្រឹត្យលេខ ៨២ ចុះថ្ងៃ ១៦ វិច្ឆិកា ១៩៩៥។

[43] មាត្រា ៤៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញ វត្ថុ ២៨-១២-៩៣

[44] មាត្រា៧ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៥ ទំព័រ ៥២៣

[45] មាត្រា៣ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៥ ស្តីពីបទបញ្ជាទូរនៃគណនេយ្យករសាធារណៈ

[46] មាត្រា១៧ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៥ ស្តីពីបទបញ្ជាទូរនៃគណនេយ្យករសាធារណៈ

ខ្លួន ប៉ុន្តែរដ្ឋមន្ត្រីអាចផ្ទេរសិទ្ធិធ្វើ ប្រតិភូកម្មឱ្យមន្ត្រីខ្លះ ដែលធ្វើការក្រោមការបង្គាប់។ អភិបាលខេត្តក្រុង ជាអាណាប័កផ្ទេរសិទ្ធិក្នុងក្របខណ្ឌប្រតិភូកម្មឥណទាន ដែលអាប័កដើមខ្សែនានាបានប្រគល់ឱ្យ។ អាណាប័កត្រូវទទួលខុសត្រូវចំពោះកិច្ចការរបស់ខ្លួន ដែលមានចែងក្នុងច្បាប់ជាធរមាន ការទទួលខុសត្រវនេះអាចមានលក្ខណៈខាងវិន័យព្រហ្មទណ្ឌ ឬក៏ខាងរដ្ឋប្បវេណី។[47]អាណាប័កដើមខ្សែ ឬអាណាប័កប្រទានសិទ្ធ ហើយអាចប្រគល់សិទ្ធអំណាចរបស់ខ្លួន ឬកអ្នកជំនួសក្នុងករណីអាណាប័កអវត្តមាន ឬមានធុរៈ។[48]

## ២.២ មុខងារគណនេយ្យករ

គណនេយ្យករសាធារណៈ[49] (Complatables) ជាមន្ត្រីហិរញ្ញវត្ថុម្នាក់ ដែលមានភារកិច្ចគ្រប់គ្រងលុយកាក់(បានសេចក្តីថាប្រមូលចំណូលទូទាត់ចំណាយ)។ គណនីសាធារណៈ មានភារៈកិច្ចប្រមូលចំណូលទាំងអស់ចូលក្នុងថវិកា ហើយទូទាត់ចំណាយ ដែលបានសម្រេច ដោយអាណាប័កនានា។ ភារកិច្ចមួយទៀតដែលសំខាន់ខ្លាំងណាស់ដែរ គឺការគ្រប់គ្រងលុយកាក់ដែលមាននៅក្នុងបេឡាឱ្យបានត្រឹមត្រូវហើយមានប្រសិទ្ធភាពទៀត មុខងារគណនេយ្យករមានវិសមិតភាពជាមួយមុខងារអាណាបើក។ ជាវិសេសវិធាននេះ ត្រូវអនុវត្តទៅលើប្តីប្រពន្ធដែលធ្វើការជាមួយគ្នា ក្នុងកន្លែងតែមួយម្នាក់ជាអាណាប័កម្នាក់ទៀតជាគណនេយ្យករ។ គណនេយ្យករចែកចេញជាពីរក្រុម[50]គឺ គណនេយ្យករផ្ទាល់របស់រតនាគារ គណនេយ្យករនៃរដ្ឋបាលហិរញ្ញវត្ថុ គណនេយ្យករនៅរតនាគារភ្នំពេញ ជាគណនេយ្យករដើមខ្សែចំណែកគណនេយ្យករនៅតាមខេត្ត ក្រុងជាគណនេយ្យកររង។

## ២.៣ មុខងារមន្ត្រីអភិបាលហិរញ្ញវត្ថុ

### ២.៣.១ អភិបាលហិរញ្ញវត្ថុមានមុខងារបីធំៗ៖[51]

- ជាទីប្រឹក្សាហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រីក្រសួងនីមួយៗ ដែលខ្លួនចូលទៅត្រួតពិនិត្យ (ពិសេសក្នុងរឿងថវិកា) ។
- ជាអ្នកត្រួតពិនិត្យតាមដានចំណាយ ឬចំណូលរបស់ក្រសួងដោយមើលតែពិនិត្យនីតិវិធី ថវិកាតែប៉ុណ្ណោះ ។ បើគ្មានទិដ្ឋាការនៃអភិបាលហិរញ្ញវត្ថុទេ ក្រសួងដោយមើលតែ ពិនិត្យនីតិវិធីថវិកាប៉ុណ្ណោះ។ បើគ្មានទិដ្ឋការ នៃអភិបាលហិរញ្ញវត្ថុទេ ក្រសួងពុំអាចធ្វើចំណាយបានជាដាច់ខាត។
- រាយការណ៍ទៅក្រសួងហិរញ្ញវត្ថុ នៅដំណើរការនៃការអនុវត្តន៍ថវិកានៅក្រសួងដែលខ្លួនត្រួតពិនិត្យ។

[47] មាត្រា១១ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៥ ស្តីពីបទបញ្ញាទូវនៃគណនេយ្យករសាធារណៈ

[48] មាត្រា៤ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៥ ទំព័រ៥២៥

[49] មាត្រា១២ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៥ ស្តីពីបទបញ្ញាទូវនៃគណនេយ្យករសាធារណៈ

[50] មាត្រា១៨ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៥ ស្តីពីបទបញ្ញាទូវនៃគណនេយ្យករសាធារណៈ

[51] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២១-២០២២ ទំព័រ ៤៧

# ជំពូកទី៣
# ការត្រួតពិនិត្យលើការអនុវត្ត
# ថវិកា និង ទណ្ឌកម្ម
# ចំពោះបទល្មើសផ្សេងៗ

# ជំពូកទី៣

# ការត្រួតពិនិត្យលើការអនុវត្តថវិកា និង ទណ្ឌកម្មចំពោះបទល្មើសផ្សេងៗ

## ផ្នែកទី១៖ ការត្រួតពិនិត្យលើការអនុវត្តថវិកា

ថវិកាជាឯកសារដែលសភាបានអនុម័ត ដើម្បីឱ្យរដ្ឋាភិបាលយកមកអនុវត្ត។ ដូចនេះច្បាប់បានតម្រូវឱ្យមានយន្តការមួយក្នុងការត្រួតពិនិត្យ ដើម្បីតាមដានឱ្យដឹងថាចំណូលចំណាយមានដំណើរការដូចគ្រោងទុកទេ ការត្រួតពិនិត្យនេះត្រូវធ្វើឡើងច្រើនសណ្ឋាន ខ្លះជាសមត្ថកិច្ចនៃអង្គការរដ្ឋបាល ខ្លះត្រូវធ្វើដោយរដ្ឋសភា។ ការត្រួតពិនិត្យនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុ មានគោលដៅត្រួតពិនិត្យឡើងវិញនូវភាពស្របន ការ អនុវត្តច្បាប់ហិរញ្ញវត្ថុ ទៅនឹងកិច្ចអនុញ្ញាតថវិការធ្វើឡើងដោយ។ នៅក្នុងនេះ មានត្រួត ពិនិត្យផ្សេងៗត្រូវបានបង្កើតឡើង។ ការត្រូតពិនិត្យនៃការអនុវត្ត ច្បាប់ហិរញ្ញវត្ថុ ក៏មានគោល ដៅក្នុងការ ដាក់ទណ្ឌកម្មទៅអនិយ័តភាពផងដែរ។[52]

### ១.១ ការត្រួតពិនិត្យតាមបែបរដ្ឋបាល

ការត្រួតពិនត្យនេះជាបន្ទុករបស់អំណាចឋានានុក្រម នៅក្រសួងនីមួយ ឬជាបន្ទុកពិសេសរបស់ក្រសួងហិរញ្ញវត្ថុ។[53]

#### ១.១.១ ការត្រួតពិនិត្យដោយឋានានុក្រម៖[54]

ការត្រួតពិនិត្យនេះត្រូវធ្វើដោយថ្នាក់ដឹកនាំក្រសួងតាមឋានានុក្រមពីលើដល់ក្រោម។ ករណីមានពីរ :

១.រដ្ឋមន្ត្រីក្រសួងនីមួយៗដែលជាអណាប័កដើមខ្សែក្នុងក្រសួងត្រូវត្រួតពិនិត្យមើល អានាប័កផ្ទេរសិទ្ធិដែលនៅតាមខេត្តក្រុង។ ការត្រួតពិនិត្យមើលនេះត្រូវធ្វើលើរបាយការណ៍ និងឯកសារនានា ដែលផ្ញើមកក្រសួងរាល់ខែ ឬដោយអង្គភាពអធិការកិច្ចរបស់ក្រសួង។

២.ការត្រួតពិនិត្យទៅលើគណនេយ្យករនានា ត្រូវធ្វើឡើងដោយអគ្គហិរញ្ញិកដែលជាគណនេយ្យករធំក្នុងខេត្ត ក្រុងនីមួយៗ និងដោយក្រុមអធិការហិរញ្ញវត្ថុ ដែលមានអំណាចចុះតែ ឆែកឆេរផ្ទាល់លើគណនេយ្យទាំងអស់។

[52] ឡឿន ពិដោ នីតិថវិកានិងពន្ធដា

[53]សំ សុខ ពីនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៤៥

[54]សំ សុខ ផ្នែកទី២ នៃនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៤៥

**១.១.២ ការត្រួតពិនិត្យលើអាណាប័ក ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**[55]

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុតាមរយៈអភិបាលហិរញ្ញវត្ថុ អាចធ្វើការត្រួតពិនិត្យ លើការចាយវាយក្នុងក្រសួងនីមួយៗ។ បើគ្មានទិដ្ឋការរបស់អភិបាលហិរញ្ញវត្ថុទេ ក្រសួងមិនអាចចាយវាយ បានជាដាច់ខាត។ ដូចនេះមុននឹងសម្រេចចំណាយអ្វីមួយ ក្រសួងត្រូវបញ្ជូនឯកសារទាំងអស់ ទៅឱ្យអភិបាលហិរញ្ញវត្ថុពិនិត្យ និងផ្តល់ទិដ្ឋាការជាចាំបាច់។ អភិបាលហិរញ្ញវត្ថុនេះ ជាតំណាងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៅក្នុងក្រសួងនីមួយៗ។ ចំណែកគណនេយ្យករវិញ មុខងាររបស់ខ្លួនគឺ ត្រូវពិនិត្យមើលឱ្យបានហ្មត់ចត់លើឯកសារចំណាយថាតើត្រឹមត្រូវតាមបែបបទច្បាប់ថវិកាឬទេមុននឹងបើកលុយឱ្យអ្នកផ្គត់ផ្គង់។ រីឯក្រុមអធិការហិរញ្ញវត្ថុមានភារកិច្ចសំខាន់គឺត្រូវត្រួតពិនិត្យជាទូទៅលើអាណាប័កតូចៗដើម្បីឱ្យរដ្ឋមន្ត្រីហិរញ្ញវត្ថុយល់លើសកម្មភាពរដ្ឋបាលទាំងមូល។

**១.១.៣ ការត្រួតពិនិត្យរបស់អភិបាលហិរញ្ញវត្ថុ**

ការត្រួតពិនិត្យរបស់អភិបាលហិរញ្ញវត្ថុលើការចំណាយមាន ២ដង គឺលើកទី១ នៅពេល ដែលចំណាយទើបនឹងចេញភ្លាម ក្រោយពីអាណាប័កបានសម្រេច។ លើកទី២ ពេលដែល គេធ្វើអាណត្តិបើកលុយ។ ការត្រួតពិនិត្យនេះ គឺធ្វើឡើងនៅថ្នាក់លើ ពោលគឺនៅរដ្ឋធានី។ រីឯការត្រួតពិនិត្យនៅថ្នាក់ ក្រោមពោលគឺ នៅតាមខេត្ត ក្រុង ខ័ណ្ឌ ត្រូវប្រគល់ឱ្យអធិការកិច្ចហិរញ្ញវត្ថុ និងគណនេយ្យករនានា ដែលធ្វើការនៅទីកន្លែងស្រាប់។ ចាប់តាំងពីឆ្នាំ១៩៩៦ មកការត្រួតពិនិត្យហិរញ្ញត្ថុត្រូវប្រគល់ឱ្យអគ្គរតនាគារភូមិភាគវិញ ដែលមានភារកិច្ចផ្តល់ទិដ្ឋាការ លើចំណាយរបស់អាណាប័កតូចៗ។ ប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុនៅគ្រប់ក្រសួងមន្ទីរស្ថាប័នរដ្ឋនៅរដ្ឋបាលកណ្តាលក៏ដូចជានៅតាម ខេត្ត ក្រុងទាំងអស់។ ការត្រួតពិនិត្យហិរញ្ញវត្ថុនេះ សំដៅយកកិច្ចការទាំងឡាយដែលត្រូវធ្វើមុនពេលអនុវត្តក៏ដូចជាក្រោយពេលអនុវត្តដែរ។ ការត្រួតពិនិត្យនេះ គឺធ្វើតែលើចំណាយថវិកា ឬគណនីពិសេសរតនាគារទេ។

ក្រោយពីពិន្យលើឯកសារចំណាយហើយ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុគឺអភិបាលហិរញ្ញវត្ថុ ត្រូវសម្រេចឱ្យទិដ្ឋាការឬមិនឱ្យក្នុងរយៈពេលបីថ្ងៃចាប់តាំងពីថ្ងៃទទួលឯកសារចំណាយមក។[56] បើហួសពីនេះ គេត្រូវចាត់ទុកជាបានការ ហើយគេអាចមានសិទ្ធិធ្វើចំណាយបានតាមផ្លូវច្បាប់។ មានចំណាយបីប្រភេទដែលគេមិនចាំបាច់សុំទិដ្ឋាការជាមុនពីអភិបាលហិរញ្ញវត្ថុ។ ចំណាយទាំងនោះមានដូចខាងក្រោម៖

- ចំណាយមួយដងមួយកាលតូចៗដែលគេមិនអាចបូកបញ្ចូលទាំងអស់បាន ដើម្បីដាក់ដេញថ្លៃតាមនីតិវិធីលទ្ធកម្មសាធារណៈ។ ចំនួនទឹកប្រាក់នៃចំណាយទាំងនេះត្រូវកំណត់ឡើងតាមប្រកាសរដ្ឋមន្ត្រីក្រសួង ហិរញ្ញវត្ថុ។

[55] សំ សុខ ដកស្រង់ពីផ្នែកទី២ នៃនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៤៥-១៤៦

[56] យោងតាមមាត្រា ៤ នៃអនុក្រិត្យនេះ ការត្រួតពិនិត្យនេះ

- ចំណាយដែលគេធ្វើទៅតាមផ្លូវរដ្ឋាករបុរេប្រទាន។លុះដល់ចាយរួចហើយបានគេសុំទិដ្ឋាការពី អភិបាលហិរញ្ញវត្ថុជាក្រោយ។
- ចំណាយចំណាយខ្លះដែលមានលក្ខណៈសំងាត់ដូចជា ចំណាយខាងកងទ័ព ឬសម្រាប់សន្តិសុខជាតិ។ នេះត្រូវធ្វើឡើង ទៅតាមបែបបទពិសេសមួយ ដែលកំណត់ដោយអនុក្រឹត្យគណៈរដ្ឋមន្ត្រី។

## ១.២ ការត្រួតពិនិត្យរបស់សភា

សភាមានសិទ្ធិលើច្រតពិនិត្យលើការអនុវត្តថវិកា ហើយកិច្ចការនេះអាច ពេលថវិកា កំពុងអនុវត្តក៏ដូចជាក្រោយពេលអនុវត្តដែរ ។[57]

### ១.២.១ ការត្រួតពិនិត្យថវិកាពេលកំពុងអនុវត្តៈ[58]

កិច្ចការនេះ ត្រូវរាប់បញ្ចូលទៅក្នុងភារកិច្ចរបស់សភាក្នុងការតាមដាន និងសកម្មភាពនៃរដ្ឋាភិបាល។ តាមធម្មតារដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ជូនសភានូវរបាយការណ៍នានា ស្តីអំពីការអនុវត្តន៍ថវិកា។ រដ្ឋាភិបាលត្រូវរៀបចំចំលើយបំភ្លឺចំពោះសំណួរ ជាលាយលក្ខណ៍អក្សរ ឬដោយវាចាររបស់សមាជិកសភាដែលចង់ដឹងពីបញ្ហាអ្វីមួយយ។ ក្នុងករណីខ្លះសភាមានសិទ្ធិបង្កើតគណៈកម្មាការពិសេស ដើម្បីត្រួតពិនិត្យឆែកឆេរលើរឿងអ្វីមួយដែលគេយល់ថាសំខាន់។ ជាពិសេសក្នុងពេលពិភាក្សាជជែកគ្នាលើថវិកាប្រមូលម្តងៗរដ្ឋាភិបាលត្រូវពន្យល់និងជូនដំណឹង ឱ្យបានច្បាស់លាស់ដល់សភានូវស្ថានភាពទូទៅនៃសេដ្ឋកិច្ច និងថវិកា។ សភាអាចសួរដេញដោលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុលើការអនុវត្តន៍ថវិកាមុន នឹងអនុម័តលើថវិកាប្រធាន (ច្បាប់ហិរញ្ញវត្ថុកែតម្រូវ)។

ដើម្បីញ៉ាំងឱ្យកិច្ចការត្រួតពិនិត្យកាន់តែមានភាពប្រសិទ្ធភាពខ្លាំងទៀត រដ្ឋសភាបារាំងបានសម្រេចបង្កើតកាលពីខែកុម្ភៈ ១៩៩៩ គណៈកម្មការពិសេសមួយហៅថា គណកម្មការវាយ តម្លៃនិងត្រួតពិនិត្យ។ ដូចនេះគណកម្មការ មានភារកិច្ចតាមដានពិនិត្យមើលលើប្រសិទ្ធភាពនៃចំណាយសាធារណៈ។ តាមការពិត រដ្ឋសភាបង្កើតគណកម្មការនេះគឺគ្រាន់តែមានគោលបំណងពង្រឹងភារកិច្ចតាមដានពិនិត្យមើលលើរដ្ឋាភិបាលតែប៉ុណ្ណោះ ហើយបើកិច្ចការនេះធ្វើទៅបានលទ្ធផលខ្លះ គេអាចឈានចូទៅធ្វើវិសោធកម្មលើបញ្ញត្តិ បញ្ញាឆ្នាំ១៩៥៩ បានខ្លះព្រោះច្បាប់ចុងក្រោយ នេះបានផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាចច្រើនជាងសភា។

[57] សំ សុខ ផ្នែកទី២ នៃនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៤៦

[58] សំ សុខ ផ្នែកទី២ នៃនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៤៦-១៤៧

### ១.២.២ ការត្រួតពិនិត្យថវិកាក្រោយពេលអនុវត្តៈ[59]

កាលណាថវិកាបានត្រូវអនុវត្តរួចហើយ គេត្រូវរៀបចំធ្វើច្បាប់ទូទាត់ ដែលត្រូវអនុម័តដោយសភា។ ក្នុងច្បាប់ទូទាត់គេត្រូវបញ្ជាក់ឱ្យបានច្បាស់នូវចំណូលចំណាយពិតប្រាកដ។ អាចដឹងបានថា តើឱនភាពថវិកាមានកម្រិតដល់ណា? ហើយបើគេធ្វើការប្រៀបធៀបទៅនឹងគម្រោងមុន តើមានគម្លាតទំហំប៉ុនណា?

ពិតមែនតែការអនុម័តថវិកាទូទាត់នេះ គ្រាន់តែធ្វើដើម្បីបង្គ្រប់កិច្ចការតែប៉ុណ្ណោះ ។ ប៉ុន្តែកិច្ចការនេះមានសារៈសំខាន់សម្រាប់ធ្វើការប្រៀបធៀបលទ្ធផលពិតប្រាកដនៃថវិកាទៅនឹងការវិនិច្ឆ័យ របស់អង្គតុលាការគណនី។

## ១.៣ ការត្រួតពិនិត្យរបស់អាជ្ញាធរសវនកម្មជាតិ

អាជ្ញធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈមួយមានភាពឯករជ្យ ហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាលដើម្បីជ្រាបជាពណ៌មាន។[60] អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជនទៅរដ្ឋាភិបាលជ្រាបជាព័ត៌មាន។ បណ្តាស្ថាប័នដែលគ្រប់គ្រងដោយច្បាប់សវនកម្ម រួមមានបណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ ស្ថាប័នហិរញ្ញវត្ថុរដ្ឋចំណុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ ឬសេវាកម្មចំពោះរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គភាពផ្សេងទៀត ដែលរាជរដ្ឋាភិបាល បានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ នៃឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀត ទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគ ឯកជន។

### ១.៣.១ កម្មវត្ថុនៃការត្រួតពិនិត្យ

កម្មវត្ថុនៃសាវនកម្មមានដូចខាងក្រោមៈ[61]

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួងស្ថាប័ន ដែលជាមូលដ្ឋានសម្រាប់ធ្វើ របាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលនៅបំណាច់ឆ្នាំនៃកាលបរិច្ឆេទដែលរៀបចំដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមុនពេលដាក់ជូនអង្គការនីតិបញ្ញត្តិ។ ការត្រួតពិនិត្យលើភាពត្រឹមត្រូវ ភាពពិតប្រាកដ ការយល់ព្រម ការធ្វើឲ្យមានសុពលភាព និងស្របតាមទិន្នន័យហិរញ្ញវត្ថុ ដូចមានបង្ហាញពីរបាយការណ៍របស់បណ្តាក្រសួង ស្ថាប័ន និងរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលសំណូមពរដោយបណ្តាភ្នាក់ងារ

---

[59] សំ សុខ ផ្នែកទី២ នៃនីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៤៧

[60] មាត្រា១៤ សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ថ្ងៃទី៣ ខែមីនាឆ្នាំ២០០ ទំព័រ ១០

[61] មាត្រា ៥ ដល់មាត្រា ១២ នៃច្បាប់ស្តីពីសវនកម្មនាំព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០

ផ្តល់ជំនួយអន្តរជាតិ និងបណ្តាឥណទានយកនៅក្នុងគម្រោងផ្តល់មូលនីធិក្រៅប្រទេស។ ការត្រួតពិនិត្យនេះត្រូវ បញ្ជាក់អំពីភាពសមស្រប និងភាពត្រឹមត្រូវនៃឯកសារយុត្តិការណ៍ក្នុងការដកប្រាក់ និងការចំណាយលើគម្រោងនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុបង្ហាញនូវការសមស្រប ទៅនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាន និងកិច្ចព្រមព្រៀងគម្រោង និងសវនកម្មលើការវាយតម្លៃចំពោះការសម្រេចគោលដៅនៅពេលចប់គម្រោងទាំងនេះ។ សវនកម្មលើការគ្រប់គ្រងនិងការប្រព្រឹត្តិទៅលើបណ្តាស្ថាប័ន លើសកម្មភាព និងកិច្ចប្រតិបត្តិការទាំងឡាយ។ សវនកម្មរាប់បញ្ចូលទាំងលទ្ធកម្មសាធារណៈបៀវត្សរ៍បុគ្គលិក សន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបេសកកម្ម។ សវនកម្មលើការវាយតម្លៃអំពីការសន្សំសំចៃ ការផ្តល់លទ្ធផលល្អ និងប្រសិទ្ធភាពកងអនុវត្តទៅលើកម្មវិធីរបស់រដ្ឋាភិបាល។

សវនកម្មលើអង្គការដែលមិនរកប្រាក់ចំណេញ សមាគម គណបក្សនយោបាយ និងសវនកម្មលើសហគ្រាសវិនិយោគឯកជន ដែលទទួលជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលក្នុងទ្រង់ទ្រាយលែងពន្ធគយ ពន្ធលើប្រាក់បៀវត្សរ៍ និងពន្ធអាករផ្សេងទៀតព្រមទាំងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធដែលពុំមានការអនុញ្ញាតិដោយច្បាប់។ គោលដៅនៃសវនកម្មនេះគឺដើម្បីកុំឲ្យរាជរដ្ឋាភិបាល ត្រូវបានបាត់បង់ប្រាក់ចំណូលដែលបណ្តាលមកពីការលើកលែងពន្ធ និងដើម្បីធានាថាស្ថាប័នគ្រប់គ្រងបានដំណើរការទៅតាមក្របខណ្ឌនៃគោលបំណងរបស់ខ្លួន។ សវនកម្មលើការអនុវត្តស្របតាមបទបញ្ញត្តិជាធរមានរបស់សហគ្រាសវិនិយោគឯកជន ដែលទទួលការលើកលែងពន្ធ និងសម្បទានពីរាជរដ្ឋាភិបាល ដើម្បីធ្វើអាជីវកម្មលើធនធានធម្មជាតិ។ សវនកម្មទាំងនេះសង្កត់ធ្ងន់ទៅលើការអនុវត្តតាមកិច្ចព្រមព្រៀង និងបណ្តាលក្ខខណ្ឌនៃការអនុញ្ញាតិពីរដ្ឋាភិបាល។ សវនកម្មតាមសំណើពិសេស របស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភា ឬព្រឹទ្ធសភា ឬក្រសួង ឬស្ថាប័ន ឬអាជ្ញាធរ សម្រាប់ធ្វើការត្រួតពិនិត្យ ពិសេសឡើងវិញលើវិស័យ មួយផ្នែក ឬទាំងអស់នៃកិច្ចប្រតិបត្តិការណ៍របស់ម្ចាស់សំណើ។

### ១.៣.២ ការត្រួតពិនិត្យថវិកាលើរដ្ឋាភិបាលនៃអាជ្ញាធរសវនកម្មជាតិ

**អាជ្ញាធរសវនកម្មជាតិ**[62] ជានិច្ចជាកាលរដ្ឋាភិបាលត្រូវបញ្ជូនឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗទៅរដ្ឋសភា ព្រឹទ្ធសភា ដើម្បីពិនិត្យ និងអនុម័ត។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលក៏ត្រូវបញ្ជូនឯកសារនេះទៅអាជ្ញាធរសវនកម្មជាតិដើម្បីធ្វើការត្រួតពិនិត្យដែរ។ អាជ្ញាធរសវនកម្មជាតិត្រូវធ្វើរបាយការណ៍ សវនកម្មបញ្ជាក់លើឯកសារនេះទៅរដ្ឋសភា និងព្រឹទ្ធសភា។ បើក្នុងរយៈពេល៩ខែ បន្ទាប់ពីបំណាច់ឆ្នាំ នៃកាលបរិច្ឆេទ រាជរដ្ឋាភិបាលមិនបានផ្តល់ឯកសារស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំរបស់សវនកម្មជាតិទេ អគ្គសវនករ ត្រូវធ្វើរបាយការណ៍

[62] មាត្រា១៤ ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរសវនកម្មជាតិ ជាស្ថាន៍សាធារណៈមួយមានភាពឯករាជ ហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មទៅសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាពត៌មាន។ អាជ្ញាធរសវនកម្មជាតិដឹកនាំដោយអគ្គសវនករមួយរូបនិងមានអគ្គសវនករ២(ពីររូប)។

ទៅរដ្ឋសភា និងព្រឹទ្ធសភាស្តីពីការខកខាននេះ ។អគ្គសវនករត្រូវធ្វើការត្រួតពិនិត្យទៅលើរបាយការណ៍របស់ស្ថាប័ននានានៃរដ្ឋាភិបាល លើកិច្ចការផ្សេងៗដូចជា៖

អគ្គសវនករត្រូវរាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងដែលពាក់ព័ន្ធក្នុងករណីដែលអង្គភាពណាមួយ មានភាពមិនប្រក្រតីនៅក្នុងកិច្ចបញ្ជីការគណនេយ្យ ការគ្រប់គ្រងរូបិវត្ថុ និងទ្រព្យសកម្ម។ អគ្គសវនករត្រូវរាយការណ៍ និងធ្វើកំណត់សំគាល់ជាទូទៅលើបណ្តាបញ្ហាដែលទាក់ទងបញ្ជីការ គណនេយ្យ រូបិយវត្ថុ ទ្រព្យសកម្ម និងបំណុលអកម្មផ្សេងៗទៀត ដោយនិងអនុទ្យោមតាមបទបញ្ញត្តិនៃច្បាប់ជាធរមាន។ ទោះជាមានបទបញ្ញត្តិណាផ្សេងក៏ដោយ ដែលស្តីពីសវនកម្ម អគ្គសវនករធ្វើសវនកម្ម លើកិច្ចបញ្ជីគណនេយ្យ របស់អាជ្ញាធរ ឬស្ថាប័ននោះត្រូវផ្តល់លិខិតបញ្ជាក់និងរបាយការណ៍ផ្សេងៗទៀត ដែលយល់ថាជាការចាំបាច់ចំពោះកិច្ចបញ្ជីការគណនេយ្យនោះ ទៅឲ្យអ្នកដឹកនាំអាជ្ញាធរ ឬស្ថាប័ននោះ និងទៅរដ្ឋសភា ព្រឹទ្ធសភា និងក្រសួងពាក់ព័ន្ធ។ អគ្គសវនករត្រូវរាយការណ៍ជូនរដ្ឋសភា ព្រឹទ្ធសភាជាប្រចាំនូវបញ្ហាទាំងឡាយណា ដែលកើតចេញពីការបំពេញភារកិច្ច ឬប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដូចមានចែងក្នុងច្បាប់។ ក្រោយពីមានការរៀបចំ របាយការណ៍ស្តីពីសវនកម្មនៃកិច្ចប្រតិបត្តិការរបស់អង្គភាពណាមួយ អគ្គសវនករត្រូវជូនច្បាប់ ចម្លងរបាយការណ៍នេះទៅប្រធានស្ថាប័នគ្រប់គ្រង។ ប្រសិនបើប្រធានស្ថាប័នគ្រប់គ្រងនោះត្រូវបានជូនយោបល់ជាលាយលក្ខណ៍អក្សរទៅអគ្គសវនករ ក្នុងកំឡុងពេល ២៨ថ្ងៃ អគ្គសវនករ ត្រូវពិចារណា លើយោបល់ទាំងនោះ មុននឹងរៀបចំរបាយការណ៍ចុងក្រោយ។ ផ្ទុយទៅវិញ បើប្រធានស្ថាប័ននោះមិនឆ្លើយតបតាមការកំណត់ខាងលើរបាយការណ៍នោះត្រូវបានចាត់ទុកជាបានការ។

### ១.៣.៣ សមត្ថកិច្ចក្នុងការធ្វើសវនកម្មលើអាជ្ញាធរសវនកម្មជាតិ

ក្នុងករណីចាំបាច់ តាមសំណើររបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃសភា គណៈកម្មាធិការអចិន្ត្រៃក្នុងនាមជារដ្ឋសភាមានសិទ្ធជ្រើសរើសសាវនករជាពិសេស ដើម្បីពិនិត្យមើលឡើងវិញ នូវសកម្មភាពនូវកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសាវនកម្មជាតិ។[63]

## ផ្នែកទី២៖ បទល្មើសក្នុងច្បាប់ថវិកា និង ទណ្ឌកម្ម

### ២.១ បទល្មើសក្នុងច្បាប់ថវិកា

ក្នុងច្បាប់ថវិកាបទល្មើសអាចប្រព្រឹត្តឡើងដោយគណនេយ្យករ ឬដោយអាណាប័ក។ តុលាការវិន័យខាងថវិកា និងហិរញ្ញវត្ថុជាស្ថាប័នដែលមានសមត្ថកិច្ចដាក់ទណ្ឌកម្មដល់មន្ត្រីមានកំហុស។[64]

[63] មាត្រ ៣៤ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាណាចក្រកម្ពុជា ឆ្នាំ ២០០០

[64] សំ សុខ នីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៥៥

### ២.១.១ ការទទួលខុសត្រូវរបស់គណនេយ្យករៈ

១. គណនេយ្យករសាធារណៈ ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនខាងលុយកាក់ ជាស្វ័យប្រវត្តិ។ បើមានភាពមិនត្រឹមត្រូវក្នុងការកាន់លុយកាក់ សាមីខ្លួនត្រូវយកទ្រព្យសម្បត្តិរបស់ខ្លួនមកប៉ះប៉ូវដើម្បីឱ្យរួចខ្លួន។

២ .ការទទួលខុសត្រូវបែបនេះ តម្រូវឱ្យមានការធានាត្រឹមត្រូវ ដែលតម្រូវឱ្យមានការស្បថ មុនពេលចូលកាន់តំណែង។ ម្យ៉ាងទៀតទ្រព្យសម្បត្តិរបស់គណនេយ្យករ ដូចជាផ្ទះសម្បែង យកទៅដាក់បញ្ចាំឱ្យរដ្ឋដើម្បីធានាលើកិច្ចការរបស់ខ្លួន។

៣. ត្រូវបង់ប្រាក់កាក់ដែលរដ្ឋរឹបអូសយកក្នុងពេលដែលខ្លួនធ្វើឱ្យបាត់ក្នុងកំឡុងពេលបំពេញភារកិច្ច។

➢ **ការត្រួតពិនិត្យលើគណនេយ្យករៈ**[65]

ការត្រួតពិនិត្យលើគណនេយ្យកសាធារណៈ ជាភារកិច្ចរបស់ឋានានុក្រម និងអគ្គាធិការដ្ឋានហិរញ្ញវត្ថុ ភារៈកិច្ចរបស់សវនករ។ បានចែងថា អគ្គសវនករ មានភារកិច្ចធ្វើសវនកម្មលើគណនី លើប្រព័ន្ធត្រួតពិនិត្យកិច្ចប្រតិបត្តិការ គម្រោងដែលស្ថាប័នរដ្ឋនានាបានអនុវត្ត។ ស្ថាប័នរដ្ឋនោះ មានក្រសួងនានា ទាំងអស់ ព្រមទាំងអង្គភាពដែលនៅពីក្រោមធនាគារជាតិកម្ពុជា ជាស្ថាប័នហិរញ្ញវត្ថុរបស់រដ្ឋសហគ្រាសរដ្ឋគ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត ក្រុងឃុំ សង្កាត់។ ការធ្វើសវនកម្មនេះ បានលាតទៅដល់អង្គការណាដែលរដ្ឋបានឧបត្ថម្ភប្រាក់ទុន ឬឥណទានផ្សេងៗ ។

សវនកម្មត្រូវធ្វើមានជាអាទិ៍ របាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងគម្រោងដែលបានលុយមកពីក្រៅស្រុក ការគ្រប់គ្រងស្ថាប័នរដ្ឋនានា អង្គការឯកជនដែលរដ្ឋបានឧបត្ថម្ភលុយកាក់ខ្លះ។ល។

ចំពោះទាក់ទុករឿងថវិកាសុទ្ធសាធ សវនកម្មពិនិត្យជាពិសេសលើ របាយការណ៍ហិរញ្ញវត្ថុ ដែលក្រសួង និងស្ថាប័ននានាបានរៀបចំ ឱ្យក្រសួងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានដល់របាយការណ៍ទូទៅរបស់រដ្ឋាភិបាលដែលត្រូវដាក់ជូនទៅសភាមួយឆ្នាំម្តង។ របាយការណ៍ហិរញ្ញវត្ថុដែលសហគ្រាសរដ្ឋនានាបានធ្វើ ដែលនៅក្នុងមានតារាងតុល្យការ តារាងចំណេញខាត បូកជាមួយការវិភាគទៅលើគណនីខ្លះ។ ការត្រួតពិនិត្យការគ្រប់គ្រងគណនេយ្យករ ត្រូវបានធានាក្រោមអំណាចរបស់រដ្ឋមន្ត្រី ក្រសួងសេដកិច្ចហិរញ្ញវត្ថុដោយឋានានុក្រមថ្នាក់លើរបស់គណនេយ្យករ និងដោយអធិការកិច្ចហិរញ្ញវត្ថុ។[66]

ក. គណនេយ្យករ[67] នីមួយៗត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនខាងលុយកាក់ជា ស្វ័យប្រវត្តិ។ បានសេចក្តីថា បើមានភាពមិនត្រឹមត្រូវក្នុងការកាន់លុយកាក់ សាមីខ្លួន ត្រូវយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនមកប៉ះប៉ូវដើម្បីឱ្យរួចខ្លួន។

---

[65] អនុក្រឹត្យលេស ៨២ ចុះថ្ងៃ១៦វិច្ឆកា ១៩៩៥

[66] មាត្រា១១៧ អនុក្រឹត្យលេស ៨២ ចុះថ្ងៃ១៦វិច្ឆកា ១៩៩៥ ទំព័រ៥៣៥

[67] សំ សុខ នីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៥៥

ខ. ការទទួលខុសត្រូវបែបនេះ តម្រូវឱ្យមានការធានាត្រឹមត្រូវខ្លះ ដូចជា លក្ខន្តិកៈដោយឡែកនៃគណយ្យករ (ដែលតម្រូវឱ្យមានការស្បថស្បែមុនពេល ចូលកាន់តំណែងមានរបបវិន័យតឹងរឹង) ដូចជាប្រាក់កក់ដែលត្រូវបង់នៅពេល ចូលកាន់តំណែង។ ម៉្យាងទៀតទ្រព្យសម្បត្តិរបស់គណនេយ្យករ ដូចជាផ្ទះសម្បែង ត្រូវយកទៅដាក់បញ្ចាំ) ឱ្យរដ្ឋដើម្បីធានាលើកិច្ចការរបស់ខ្លួន។

គ.ប៉ុន្តែតាមការជាក់ស្តែង ការទទួលខុសត្រូវមិនសូវមានភាពធ្ងន់ធ្ងរខ្លាំងពេកទេ ដោយសារមានរបបធានារ៉ាប់រង (Assurance) មកជួយ។ ក្នុងករណី ដែលគណនេយ្យករមិនបានធ្វើកំហុសរដ្ឋមន្ត្រីហិរញ្ញវត្ថុមានសិទ្ធិធ្វើការវិនិច្ឆ័យទោស ក្រោមការត្រួតពិនិត្យនៃតុលាការរដ្ឋបាល។ បើសាម៉ីជនមិនសុខចិត្តចំពោះសេចក្តីសំរេចរបស់រដ្ឋមន្ត្រីរបស់ខ្លួន ការប្តឹងតវ៉ាត្រូវធ្វើឡើងនៅមុខតុលាការរដ្ឋបាល។

**២.១.២ ការទទួលខុសត្រូវរបស់អាណាប័ក**

ក. ការទទួលខុសត្រូវរបស់មន្ត្រីគ្រប់គ្រងរដ្ឋបាល បានចោទជាបញ្ហាពិបាកដោះស្រាយបន្តិចព្រោះវាពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋ ។ ជាទូទៅបទល្មើសនានាច្រើនតែប្រព្រឹត្តទៅក្រោមសម្ពាធនៃការចាំបាច់ជាក់ស្តែង ដើម្បីបំរើប្រយោជន៍ក្រសួង។

ខ. ត្រឹមថ្នាក់រដ្ឋមន្ត្រី ការដាក់ទណ្ឌកម្មបានចោទជាបញ្ហាពិបាក ព្រោះបើគិតជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌថាធ្ងន់ធ្ងរពេក។ បើគិតជាការ ទទួលខុសត្រូវផ្នែកនយោបាយវិញ គេមិនសូវយកមកអនុវត្តទេ។

គ. ចំពោះមន្ត្រីគ្រប់គ្រងរដ្ឋបាលឯទៀតៗ ការទទួលខុសត្រូវក៏ពិបាកយក មកវិនិច្ឆ័យដែរ។ បើគិតជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមុខតុលាការ គេមិនសូវអនុវត្តទេ។ ចំណែកការទទួលខុសត្រូវផ្នែកវិន័យ គឺស្រេចតែរដ្ឋមន្ត្រី ផ្ទាល់ជាអ្នកសំរេច រីឯការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺគ្មានប្រសិទ្ធភាពទាល់ តែសោះ។ ដោយសារគេមិនអាចមានលទ្ធភាព ដាក់ទោសលើមន្ត្រីគ្រប់គ្រងរដ្ឋបាល បានជាគេបង្កើតស្ថាប័ន ពិសេសមួយក្នុងឆ្នាំ១៩៤៨ គឺតុលាការវិន័យថវិកា និង ហិរញ្ញវត្ថុ។[68] ការទទួលខុសត្រូវនេះ មានលក្ខណៈមិនដូចគ្នានិងការទទួលខុសត្រូវរបស់គណៈនេយ្យករទេ។ តាមធម្មតាមន្ត្រីគ្រប់គ្រងរដ្ឋបាល ឬអាណាប័កអាចប្រឈមការទទួលខុសត្រូវ ២យ៉ាង ៖

- ការទទួលខុសត្រូវផ្ទាល់ខ្លួនបានធ្វើឱ្យមានកំហុស ចំពោះករណីដែលខ្លួនបានធ្វើឱ្យមានកំហុសផ្ទាល់ខ្លួនដោយ គ្មានការទាក់ទងជាមួយក្រសួង។
- ការទទួលខុសត្រូវមួយទៀតគឺមានទំនាក់ទំនងជាមួយក្រសួង។ចំពោះមន្ត្រីរដ្ឋបាលគេអាចមានទណ្ឌកម្ម៣ ទណ្ឌកម្មព្រហ្មទណ្ឌវិន័យ និងរដ្ឋប្បវេណី ។

[68] សំ សុខ នីតិវិធីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៦ ទំព័រ ១៥៦

- ទណ្ឌកម្មព្រហ្មទណ្ឌ នៅមុខតុលាការ ដោយសារមានលក្ខណៈធ្ងន់ធ្ងរពេក គេមិនសូវ យកមកអនុវត្តទេ។
- ទណ្ឌកម្មវិន័យគឺស្រេចតែលើរដ្ឋមន្ត្រីផ្ទាល់ជាអ្នកសម្រេច ប៉ុន្តែតាមការជាក់ស្តែងរដ្ឋមន្ត្រីម្នាក់ៗមិនដែលធ្វើទោសកូនចៅឯងនោះទេ។
- ទណ្ឌកម្មរដ្ឋប្បវេណី គ្មានប្រសិទ្ធភាពទាល់តែសោះ។

**ការត្រួតពិនិត្យលើអាណាប័ក** អង្គការមានសមត្ថកិច្ច ត្រួតពិនិត្យលើអាណាប័កក្នុងរឿងថវិកាគឺ រដ្ឋសភា ក្រុមអធិការកិច្ចនានា និងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីនេះធ្វើកិច្ចការត្រួតពិនិត្យតាមរយៈអគ្គាធិការដ្ឋានហិរញ្ញវត្ថុនិងក្រុម អភិបាលហិរញ្ញវត្ថុដែលប្រចាំការនៅក្រសួងនីមួយៗ ។ ដោយឡែកគណនេយ្យករសាធារណៈដែលជាមន្ត្រីក្រសួងហិរញ្ញវត្ថុ ក៏មានសត្ថកិច្ចត្រួតពិនិត្យ អាណាប័កក្នុងវិស័យថវិកាដែរ។[69] ការត្រួតពិនិត្តលើការគ្រប់គ្រងរបស់អាណាប័ក ត្រូវបានធានាដោយសភា អង្គការ និងគណៈកម្មការត្រួតពិនិត្យដែលមានសមត្ថកិច្ច និងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ។[70]

## ២.២ ទណ្ឌកម្មក្នុងច្បាប់ថវិកា

### ២.២.១ ទោសបញ្ញត្តិ

ដោយពុំគិតពីការផ្តន្ទាទោសផ្សេងទៀត ជនណាដែលប្រព្រឹត្តបទល្មើស មិនផ្តល់ពត៌មានត្រឹមត្រូវ និងមិនបានបញ្ជាក់ពីពត៌មានជាលាយលក្ខណ៍អក្សរក្តី ឬដោយផ្ទាល់មាត់ក្តី និងមិនមានភស្តុតាងជាក់ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ចំនួនពី ១០០០០០០ (មួយលានរៀល) ទៅ ៥០០០០០០ (ប្រាំលានរៀល) ឬដាក់ពន្ធធនាគារពី ១ ខែទៅ ៣ ខែ និងពិន័យជាប្រាក់ផង និងដាក់ពន្ធធនាគារផង។

ដោយពុំគិតពីការផ្តន្ទាទោសផ្សេងទៀត ជនណាដែលផ្តល់ពត៌មានក្លែងបន្លំ របាយការណ៍ ទៅជារបាយការណ៍ផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ៥០០០០០០រៀល (ប្រាំលាន) រៀល ទៅ ឬដាក់ពន្ធធនាគារ ១ (មួយ) ឆ្នាំដល់ ៥ (ប្រាំ) ឆ្នាំ ឬពិន័យជាប្រាក់ផង និងពន័យជាប្រាក់ថែមទៀតផង។

[69] អនុក្រឹត្យលេស ៨២ ចុះថ្ងៃ១៦វិច្ឆកា ១៩៩៥

[70] មាត្រា១១៧ អនុក្រឹត្យលេស ៨២ ចុះថ្ងៃ១៦វិច្ឆកា ១៩៩៥ ទំព័រ ៥៣៩

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមរយៈប្រធានបទខាងលើស្តីអំពី " ការបង្កើត ការអនុវត្ត ការត្រួតពិនិត្យថវិការរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា " រួចមកឃើញថាមានចំណុចជាច្រើនដែរបង្ហាញចេញឲ្យឃើញពីសារៈប្រយោជន៍នៃថវិការជាតិមានច្រើនបែបសឹងតែជាស្នូលមួយដែលមិនអាចខ្វះបាននៃប្រព័ន្ធគ្រប់គ្រង រចនាសម័ន្ធ ការប្រើប្រាស់ថវិកាជាតិទាំងមូលមានការចំណាយ ចំណូល ត្រឹមត្រូវ និងចំគោលដៅច្បាស់លាស់ព្រមទាំងគោលរពតាមច្បាប់ជាធរមានដែរបានចែង រួមទាំងការអនុវត្តនូវកិច្ចត្រួតពិនិត្យ ការអនុវត្តថវិករជាតិ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាតិ អោយមានភាពច្បាស់លាស់ និងមានភាពប្រសើរឡើងផងដែរដើម្បីអភិវឌ្ឍប្រទេសជាតិឲ្យមានភាពរីកចម្រើនទៅមុខជាបន្តបន្ទាប់។

ភាពជាជាក់ស្តែងនៃការសិក្សាស្រាវជ្រាវសារណានេះក្រុមរបស់យើងខ្ញុំផ្តោតសំខាន់ដូចជានៅក្នុងជំពូក ១សញ្ញាណទូទៅនៃថវិកាជាតិ ធ្វើការបកស្រាយនៅ៖ (១) លក្ខណៈពិសេសនៃថវិការដ្ឋបើធៀប និង ឯកជនជាធម្មតាអង្គការសាធារណៈដូចជា (រដ្ឋ) មានធនធានធំជាងឯកជនដើម្បីបម្រើប្រយោជន៍រួមទូទៅមិនមែនបម្រើប្រយោជន៍ ឯកជន ឬក្រុមណាមួយឡើយ ដោយថវិការដ្ឋតែងតែរៀបចំគិតគូរចំណាយទុកជាមុនរួចហើយគិតគូរពីការរកចំណូលវិញតាមក្រោយ។ (២) រចនាសម្ព័ន្ធនៃថវិការដ្ឋ មានចំនួន៤ភាគ ហើយមាន៤គណនី ថវិកាទូទៅរដ្ឋ ថវិកាឧបសម្ព័ន្ធ ថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគណនីពិសេសរបស់រតនាគារ។ (៣) ចំណូលចំណាយថវិការដ្ឋមានដូចជា៖ ចំណាយលើ មធ្យោបាយសេវាកម្ម ការប្រាក់ អន្តរាគមន៍សាធារណៈ ចំណាយផ្សេង និង ចំណាយមូលធន រីឯចំណូលមាន ១ ចំណូលចរន្ត ចំណូលសារពើពន្ធ (ចំណូលគយ ពន្ធ និងអាករគ្រប់ប្រភេទ) និង ចំណូលមិនមែនសាពើពន្ធ ២ ចំណូលមូលធន ជំនួយ ( កម្ចី) និង ជំនួយឥតសំណងដែលកម្ពុជាទទួលបានពីបណ្តាប្រទេសនានារួមមាន៖ ប្រទេស ជប៉ុន ចិន សហគមន៍ អឺរ៉ុប អូស្ត្រាលី អាមេរិក កាណាដា។ល។ ជំនួយ ( ក ម្ចី) ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានារួមមាន៖ ធនាគារ អភិវឌ្ឍន៍អាស៊ី ( A D B) មូលនិធិរូបិយវត្ថុអន្តរជាតិ ( I M F )ធនាគារពិភពលោក ( W B) ។ ល ។ និងការវិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្នុងនិងក្រៅប្រទេសក្នុងលក្ខខណ្ឌអភិវឌ្ឍប្រទេស ។ យោងតាមការសិក្សាចំណូលថវិកា ឆមាសទី១ នៅក្នុងឆ្នាំ២០២២ នេះចំណូលចរន្ត អនុវត្តបានចំនួន ១២ ៦៩៣ ៥៨៥ លានរៀលស្មើនឹង ៥៧.៣% នៃច្បាប់ហិរញ្ញវត្ថុ បើគិតទៅខ្ពស់ជាង ៣.៨% ពិន្ទុភាគរយធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលអនុវត្តបាន ៥៣,៥% នៃច្បាប់ហិរញ្ញវត្ថុ បើគិតជាសាច់ប្រាក់ គឺកើនឡើង ២០,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១។ ថវិកាជាតិ គឺគ្រប់គ្រងជាចម្បងដោយច្បាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ ដែលមានមាត្រាទី ១ ចែងថា "ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ មានគោលដៅកំណត់គោលការណ៍ជាមូលដ្ឋានសម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល និងសម្រាប់រៀបចំច្បាប់ហិរញ្ញវត្ថុ (ច្បាប់ថវិកាប្រចាំឆ្នាំ) ជាពិសេសសម្រាប់ជំហាន

នីមួយៗនៃដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិកា ការត្រួតពិនិត្យលទ្ធផលថវិកាដែលស្ថិតនៅក្នុងជំពូកទី២ និង ជំពូកទី៣។ ច្បាប់នេះ ក៏ត្រួសត្រាយផ្លូវផងដែរសម្រាប់ការធ្វើឲ្យកាន់តែប្រសើរឡើងបន្ថែមទៀត នូវតម្លាភាពថវិកាជាតិ នាពេលអនាគតដ៏ខ្លីខាងមុខ ដូចមានចែងនៅក្នុងមាត្រា ៨៤ ថា " រាល់ការកត់ត្រាចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវគោរពទៅតាមប្លង់គណនេយ្យ និងមាតិកាថវិកា ហើយរាល់របាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុត្រូវមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ " ។

ជាមួយគ្នានេះ ថវិការដ្ឋឆ្នាំ ២០២២ ត្រូវបានគិតគូររៀបចំដែលតម្រូវឱ្យរាជរដ្ឋាភិបាលតម្រង់ការប្រើប្រាស់ធនធានដើម្បី ទ្រទ្រង់ ម្ខាងដល់ កិច្ចខិតខំប្រយុទ្ធនឹងជំងឺកូវីដ-១៩ ម្ខាងទៀត ស្តារ និងជំរុញសេដ្ឋកិច្ចជាតិក៏ពិតមែនប៉ុន្តែសង្កេតឃើញថាចំណូលគយ និង រដ្ឋករតាមបណ្តាខែតាមឆមាសទី១ឆ្នាំ ២០២២ មាននិន្នាការឡើងវិញបណ្តើរៗ បន្ទាប់ពីរាជរដ្ឋាភិបាលបានបើកប្រទេសឡើងវិញចំនួន ៥ ១៧៨ ៦៤៩ស្មើ នឹង ៤៩,៨% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ៣,៥ នៃឆ្នាំចាស់២០២១ ។ ថវិកាជាតិ ត្រូវបានរៀងចំជារាល់ឆ្នាំសម្រាប់ការអនុវត្តនៅ ក្នុងឆ្នាំប្រតិទិនបន្ទាប់ដែលស្របពេលគ្នាជាមួយនឹងឆ្នាំសារពើពន្ធ ។ ថវិកាជាតិត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល និងចាំបាច់ត្រូវមានការអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភាមុនពេលអនុវត្ត។

ដូចន្នេះថវិការដ្ឋ គឺជាឧបករណ៍ដ៏សំខាន់បំផុតមួយរបស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយស្ថិតនៅលើគន្លងនៃកំណើនខ្ពស់ ព្រមទាំងស្តារជីវភាព របស់ប្រជាជនទូទៅក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗនៃកម្មវិធី នយោបាយ យុទ្ធសាស្ត្រចតុកោណ ដើម្បីកាត់បន្ថយភាពក្រីក្រ និងមានឥទ្ធិពលលើជីវិតប្រចាំថ្ងៃ និងអនាគតរបស់សង្គមទាំងមូល។ សេចក្តីសម្រេចលើការធ្វើថវិកាមានផលប៉ះពាល់លើគ្រប់សកម្មភាព សេដ្ឋកិច្ច និងសង្គមកិច្ច រាប់តាំងពីកន្លែងដែលយើងរស់នៅ កន្លែងដែលយើងធ្វើការ មធ្យោបាយធ្វើដំណើរដែលយើងប្រើប្រាស់ ការថែទាំសុខភាព និងការអប់រំដែលយើងអាចទទួលបាន និងសុវត្ថិភាព អនាម័យ និងសេវាចាំបាច់នានាដែលយើងអាចទទួលពីរដ្ឋ សុខសន្តិភាព និង ធានាបាននៅការអភិវឌ្ឍសេដ្ឋកិច្ចព្រមទាំងបន្តរក្សាការពារសមិទ្ធផលសង្គមជាតិ

# អនុសាសន៍

# អនុសាសន៍

តាមរយៈការធ្វើសារណាលើប្រធានបទនៃការរៀបចំដំណើរការនៃការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យថវិការដ្ឋ។ ក្រុមយើងខ្ញុំយល់ឃើញថាច្បាប់ហិរញ្ញវត្ថុដែលរាជរដ្ឋាភិបាលបានរៀបចំជារៀងរាល់ឆ្នាំពិតជាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការគ្រប់គ្រងរាល់ចំណូលចំណាយដែលកើតមាននៅក្នុងដំណើរការសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ ផ្អែកតាមការវាយតម្លៃពាក់កណ្តាលឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានកំណើន ៥,៤% គឺខ្ពស់ជាងការព្យាករក្នុងអត្រា៤,៨% នៅពេលរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២២ ក៏ប៉ុន្តែនៅទាបជាងការព្យាករណ៍ពីដើមឆ្នាំដែលត្រូវបានប៉ាន់ស្មានថាមានកំណើនក្នុងអត្រា ៥,៦% ដោយសារផលប៉ះពាល់នៃជម្ងឺកូវីដ១៩។ ដែលហានិភ័យទាំងនេះហើយដែលទាមទារអោយរដ្ឋាភិបាលត្រូវត្រៀមលក្ខណៈរួចជាស្រេចក្នុងការបញ្ចៀស និងបន្ធូរបន្ថយសម្ពាធហានិភ័យ ព្រមទាំងបញ្ហាប្រឈមនានា។

ហេតុនេះហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តតាមដាន ត្រូវធ្វើការវាយតម្លៃជា ប្រចាំដោយយកចិត្តទុកដាក់ដើម្បីត្រៀមលក្ខណៈជាស្រេចអោយបានគ្រប់ជ្រុងជ្រោយ និងដាក់ចេញនូវវិធានការអន្តរាគមន៍អោយទាន់ពេលវេលា។ ជាពិសេសការគ្រប់គ្រងការប្រមូលចំណូល និងរៀបចំការចំណាយអោយបានល្អិតល្អន់ដោយគួរកាត់បន្ថយចំណាយមួយចំនួនដែលពុំចាំបាច់ និងខ្វះខ្វាយថវិការដ្ឋជាចាំបាច់។ បន្តពង្រឹងអង្គភាពថវិកានៃក្រសួងស្ថាប័នលើទំនួលខុសត្រូវ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អោយបានត្រឹមត្រូវ ទាន់ពេលវេលាតាមការនែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី និងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ។

គួរបន្តពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ លើកកម្ពស់ការចាត់វិធានការរដ្ឋបាល និងវិន័យហិរញ្ញវត្ថុតាមច្បាប់ជាធរមាន។ ព្រមទាំងបន្ថែមចំនុចហានិភ័យមួយចំនួននៅក្នុងការធ្វើសេចក្តីព្រៀងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកាប្រចាំឆ្នាំ ដើម្បីរាជរដ្ឋាភិបាលអាចព្យាករណ៍ទុកមុនបានគ្រប់ជ្រុងជ្រោយដោយកាត់បន្ថយ អត្រាមានហានិភ័យបានកាន់តែប្រសើរឡើង។ មិនតែប៉ុណ្ណោះការគិតគូពីចំណូល អោយបានច្រើន និងរកស្វែងរកប្រភពចំណូលបន្ថែមទៀត ដូចជាបង្កើនការលើកទឹកចិត្តដល់ពាណិជ្ជករ ក្នុងការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជារួមទាំងអ្នកវិនិយោគក្នុង និងក្រៅប្រទេសនានា អោយចូលមកវិនិយោគក្នុងប្រទេសកម្ពុជាដើម្បីអោយសេដ្ឋកិច្ចរបស់ប្រទេសមានស្ថិរភាព និងរីកចម្រើនប្រកបដោយសក្តានុពល។

ដូចនេះការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យថវិការដ្ឋ ពិតជាសំខាន់ខ្លាំងណាស់ និងបានចូលរួមធានាអោយកំណើនសេដ្ឋកិច្ចជាតិខ្ពស់ឡើងប្រកបដោយប្រសិទ្ធភាព ជួយរក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពប្រជាជនទប់ទល់នឹងផលប៉ះពាល់នានាផងដែរ។

# ឯកសារយោង

# ឯកសារយោង

**បទបញ្ញត្តិច្បាប់**

- កម្រងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨
- ច្បាប់ហិរញ្ញវត្ថុសាធារណៈកម្ពុជា លេខ៣/មិថុនា២០០០
- សារាចរណែនាំស្តីអំពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២២ ២០២៣
- សំ សុខ នីតិហិរញ្ញវត្ថុសាធារណៈនិងថវិកាឆ្នាំ២០០៦
- ច្បាប់ស្តីពីហរិញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

**សៀវភៅច្បាប់ផ្សេងៗ**

- យុទ្ធសាស្រ្តកៀគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល
- របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការវាយតម្លៃការអនុវត្តច្បា់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២២

# ឧបសម្ព័ន្ធទី១

# សារាចរណែនាំការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៣......សហវ.......

ថ្ងៃសុក្រ ៥រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០២១

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

## ១. សេចក្តីផ្តើម

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃ ពុធ ១១កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៥៣ អនក្រ.បក ចុះថ្ងៃ ពុធ ៣រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ និងអនុក្រឹត្យលេខ ២៥៤ អនក្រ.បក ចុះថ្ងៃ ពុធ ៣រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ។ ផ្អែកលើមូលដ្ឋាននៃច្បាប់ និងអនុក្រឹត្យខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៩៤០ សហវ.ប្រក ចុះថ្ងៃ ព្រហស្បតិ៍ ៤រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ និងប្រកាសលេខ ៩៤១ សហវ.ប្រក ចុះថ្ងៃ ព្រហស្បតិ៍ ៤រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ។

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ ដែលកម្ពុជាកំពុងស្ថិតក្នុងវិបត្តិជំងឺកូវីដ-១៩ នៅឡើយ បន្ទាប់ពី**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១** និងការបន្តរីករាលដាលនៃមេរោគកូរ៉ូណាបំប្លែងថ្មី ដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់សុខភាព សង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងកំពុងដាក់សម្ពាធកាន់តែធ្ងន់មកលើថវិកាជាតិ ។ រាជរដ្ឋាភិបាលបាន និងកំពុងបញ្ចេញចំណាយអន្តរាគមន៍យ៉ាងច្រើន ដើម្បីទប់ទល់នឹងវិបត្តិនេះ ព្រមជាមួយនឹង

ការដាក់ចេញនូវ "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយ **កូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**" សំដៅលើកស្ទួយជីវភាពរបស់ប្រជាជនទូទៅ ។ ទន្ទឹមនេះ, ថវិកាឆ្នាំ ២០២២ ក៏ជាថវិកាឆ្នាំទី ៤ នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ដែលតាមរយៈនេះ រាជរដ្ឋាភិបាលត្រូវបន្តខិតខំសម្រេចឱ្យបាននូវអាទិភាពគោលនយោបាយ និងគោលដៅអភិវឌ្ឍន៍សំខាន់ៗជាសារវន្ត, ដូចមានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**, នៅលើមាគ៌ានៃការកែទម្រង់ស៊ីជម្រៅ និងការជំរុញការអភិវឌ្ឍ ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលជាច្រើនដែលសម្រេចបានកន្លងមក, ទាំងខាងនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ពិសេសគឺ សន្តិភាព និងស្ថិរភាពនយោបាយដ៏រឹងមាំជាប់មិនដាច់ ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត និងមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍជាតិ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន ។ មួយវិញទៀត, ថវិកាឆ្នាំ ២០២២ ក៏ជាថវិកា ដែលត្រូវធានាជោគជ័យនៃការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ និងជោគជ័យនៃការបំពេញកាតព្វកិច្ចតំបន់ និងអន្តរជាតិរបស់កម្ពុជា ពិសេសគឺ ការធ្វើជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន នៅឆ្នាំ ២០២២ ។

ដើម្បីសម្រេចគោលដៅនេះ, ថវិកាឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **អភិក្រមគ្រឹះ** ជាយុទ្ធសាស្ត្រសំខាន់ចំនួន ៥ រួមមាន÷ (១)-ទប់ទល់ការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងរស់នៅជាមួយជំងឺកូវីដ-១៩ នៅក្នុងគន្លងប្រក្រតីថ្មី; (២)-អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៤,៨% និងបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជនផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញ និងបង្កើនចំណូលថវិកាជាតិ; (៣)-ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ; (៤)-បន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច សំដៅធានាស្ថិរភាពកំណើន គាំទ្រដល់ការស្តារសេដ្ឋកិច្ចនិងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជនតាមការសន្យា ព្រមទាំងពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និងសមត្ថភាពនៃវិស័យសាធារណៈ ក្នុងគោលដៅពង្រីកវិសាលភាព និងពង្រឹងគុណភាពនៃសេវាសាធារណៈ និងសេវាយុត្តិធម៌; និង (៥)-ធានាអនុវត្តឱ្យបានជោគជ័យនូវរបៀបវារៈនៃការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ពិសេសការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ ក៏ដូចជាការបំពេញកាតព្វកិច្ចតំបន់ និងអន្តរជាតិរបស់កម្ពុជា ពិសេសក្នុងនាមជាប្រធានអាស៊ាន ។

ផ្អែកលើអភិក្រមគ្រឹះជាយុទ្ធសាស្ត្រខាងលើ ថវិកាឆ្នាំ ២០២២ ត្រូវបានរៀបចំឡើង ដោយឈរលើ **គោលការណ៍បច្ចេកទេសសំខាន់ៗ** ចំនួន ៧ ទៀត រួមមាន÷

***១-ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល*** ក្នុងបរិការណ៍ដែលចំណូលក្នុងប្រទេសមាននិន្នាការថយចុះដោយសារផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ក្រសួង- ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដែលទទួលបន្ទុកកៀរគរចំណូលមិនមែនសារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធ ចាំបាច់

ត្រូវបន្តរក្សាចលនការនៃការខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូលថវិកាឱ្យអស់លទ្ធភាព ជាពិសេសពង្រឹងមន្ត្រីមានសមត្ថកិច្ច ក៏ដូចជាអង្គភាពពាក់ព័ន្ធនឹងការប្រមូលចំណូលរបស់ខ្លួនមិនឱ្យធ្លាក់ដៃក្នុងការបំពេញភារកិច្ច ទន្ទឹមនឹងការបន្តរក្សានូវភាពប្រយ័ត្នប្រយែង ព្រមទាំងការពង្រឹងអភិបាលកិច្ច និងយុត្តិធម៌ក្នុងការផ្តល់សេវា និងការប្រមូលពន្ធដារ ។

*២-ការធ្វើវិចារណកម្មលំដាប់អាទិភាព* តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ ជាពិសេសលើកម្មវិធី/សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន ក្នុងក្របខ័ណ្ឌនៃរក្សាលំនឹងជីវភាព សង្គម និងសេដ្ឋកិច្ច ព្រមទាំងការត្រៀមលក្ខណៈដើម្បីស្តារសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ក្នុងន័យនេះ វិធានការបច្ចេកទេសលម្អិតចំនួន ៤ ទៀត ត្រូវបានបន្តអនុវត្ត រួមមាន÷ *(១)-មិនផ្តល់ថវិកាសម្រាប់មុខចំណាយមិនចាំបាច់ និងចំណាយលែងចាំបាច់, (២)-រឹតបន្តឹងខ្លាំងក្នុងការផ្តល់ថវិកាសម្រាប់មុខចំណាយមិនសូវចាំបាច់, (៣)-បន្តផ្តល់ថវិកាចំពោះមុខចំណាយដែលចាំបាច់, និង (៤)-ហ៊ានចាយបន្ថែមលើមុខចំណាយដែលចាំបាច់ខ្លាំង* ។

*៣-ការយកចិត្តទុកដាក់លើមនុស្ស* ដោយរក្សាកម្រិតប្រាក់បៀវត្សអប្បបរមាជូនមន្ត្រីរាជការគ្រប់ប្រភេទ ព្រមទាំង របបតាវកាលិកចាំបាច់ផ្សេងៗ និងការគាំពារសង្គមផ្សេងៗទៀត ស្មើនឹងកម្រិតឆ្នាំ ២០២១ ប៉ុន្តែបន្តផ្តល់អាទិភាពដល់ការកសាង និងពង្រឹងធនធានមនុស្ស និងផ្តល់ការយកចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រចំពោះមនុស្សដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់លើការផ្តល់សេវាសាធារណៈ ព្រមទាំងការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងកម្មវិធីសាច់ប្រាក់ពលកម្ម ។

*៤-កំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព* តាមរយៈការបន្តគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ, និងគុណភាព ក្នុងការអនុវត្តកម្មវិធី/សកម្មភាព ក្នុងគោលដៅជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា ។

*៥-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត* តាមរយៈការជំរុញ និងបង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពអនុវត្តការងារផ្ទាល់ ដែលនៅក្រោមឱវាទក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល ឬនៅតាមមូលដ្ឋាន ជាពិសេសតាមសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព ទន្ទឹមនឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការទទួលខុសត្រូវនៅនឹងកន្លែង ។

*៦-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា* ដោយផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពចំណាយមិនមែនបុគ្គលិកដល់ក្រសួង-ស្ថាប័នដែលកៀរគរចំណូលបានដោយការខិតខំធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់ ។

*៧-ការរក្សាតុល្យភាព និងចីរភាពថវិកា÷* រក្សាតុល្យភាពនៃតម្រូវការបន្ទាន់ ជាមួយតម្រូវការនិងហានិភ័យរយៈពេលមធ្យម ក្រោមសម្ពាធនៃការធ្លាក់ចុះយ៉ាងគំហុកនៃចំណូល ស្របពេលដែលតម្រូវការចំណាយដែលចេះតែកើនឡើង, ទាំងចំណាយចរន្ត និងចំណាយវិនិយោគសាធារណៈ, ដែលចាំបាច់សម្រាប់ជំរុញកំណើននិងលើកស្ទួយភាពប្រកួតប្រជែង ព្រមទាំងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន, គម្រោងថវិកា

ឆ្នាំ ២០២២ នៅតែត្រូវបានរៀបចំដោយឆ្លើយតបបានទាំងស្រុងទៅនឹងគោលដៅរក្សាលំនឹងជីវភាព សង្គម សេដ្ឋកិច្ច ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងត្រៀមខ្លួនដើម្បីស្តារកំណើនសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ក្រោយវិបត្តិជំងឺកូវីដ-១៩ ។

ដូចនេះ ក្នុងក្របខ័ណ្ឌនៃកំណើនសេដ្ឋកិច្ច ដែលត្រូវបានគ្រោងក្នុងរង្វង់ ៤,៨% និងក្នុងគោលដៅបន្តបម្រើឱ្យបណ្តាអាទិភាពនៃ "យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤" នៅក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ បានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ ដូចតទៅ÷

- ចំណាយសរុបនៃថវិការដ្ឋស្មើនឹង ២៧,៩៥% នៃ ផ.ស.ស.,
- ចំណូលក្នុងប្រទេសថវិការដ្ឋត្រូវសម្រេចឱ្យបានស្មើនឹង ២០,៦១% នៃ ផ.ស.ស.,
- អតិរេកចរន្តត្រូវរក្សាឱ្យបានក្នុងកម្រិតប្រមាណ ២,៧៧% នៃ ផ.ស.ស.,
- ឱនភាពថវិកាជាតិសរុបនឹងមានទំហំស្មើនឹង -៧,៣៤% នៃ ផ.ស.ស. ដែលត្រូវបានបំពេញតុល្យភាពដោយ÷ **(១)-ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំ **៤,៦៨%** នៃ ផសស; **(២)-មូលនិធិទ្រទ្រង់ថវិកា** ក្នុងទំហំ **១,០២%** នៃ ផសស; **(៣)-ការបោះផ្សាយលក់មូលបត្ររដ្ឋ** ក្នុងទំហំ **០.៩៨%** នៃ ផសស ស្មើនឹង **១ ២១៩ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៣០០ លានដុល្លារអាម៉េរិក**; និង **(៤)**-ប្រាក់បញ្ញើរាជរដ្ឋាភិបាល ក្នុងទំហំ **១,៦៥%** នៃ ផសស ស្មើនឹង **២ ០៣២ ប៊ីលានរៀល**, សមមូលនឹង **៥០០ លានដុល្លារអាម៉េរិក** ដែលត្រូវបានគ្រោងយកមកប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយ និងវិធានការរក្សាលំនឹងទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ជាពិសេសសម្រាប់អនុវត្ត **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី** ។

ដូចនេះ ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ សម្រេចបានតាមគោលដៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើ**ការអនុវត្តថវិកាថ្នាក់ជាតិ**សម្រាប់ឆ្នាំ ២០២២ ដូចខាងក្រោម÷

## ២. លក្ខខណ្ឌ និងវិធានការក្នុងការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២២

### ២.១-ការរៀបចំ និងការអនុវត្តកម្មវិធីចំណូល-ចំណាយ

ដើម្បីឱ្យការអនុវត្តថវិកាមានភាពជឿទុកចិត្តបាន និងប្រព្រឹត្តទៅដោយរលូន ជាពិសេសដើម្បីធានាការឆ្លើយតបនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវពង្រឹងភាពជាម្ចាស់ក្នុងការរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសម្រាប់រយៈពេលពេញមួយឆ្នាំ ដែលមានបែងចែកលម្អិតទៅតាមខែ និងទៅតាមគំរូដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃតម្រូវការចំណាយជាក់ស្តែង ទៅតាមប្រតិទិននៃផែនការសកម្មភាពការងារ និងផែនការលទ្ធកម្ម និងក្នុងក្របខ័ណ្ឌនៃឥណទានថវិកាដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ។ ក្រសួង-ស្ថាប័នត្រូវធ្វើកម្មវិធីចំណូល-ចំណាយ ដែល

បានរៀបចំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា), ដោយឡែក មន្ទីរជំនាញរាជធានី-ខេត្ត ក្រោមឱវាទទាំងអស់ ត្រូវផ្ញើកម្មវិធីចំណូល (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ) និងកម្មវិធីចំណាយដែលបានរៀបចំទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយច្បាប់ ដើម្បីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) និងទៅក្រសួង-ស្ថាប័នដែលជាខ្សែបណ្ដោយរបស់ខ្លួនមួយច្បាប់សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត ។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយ ដែលស្នើឡើងដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវាយតម្លៃលើអាទិភាពនៃតម្រូវការ និងលទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ទៅតាមមាតិកាថវិកាសម្រាប់អនុវត្ត ។

ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសឱ្យកាន់តែបានត្រឹមត្រូវ និងសុក្រឹត ព្រមទាំងការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះ គឺជាប្រការចាំបាច់បំផុត ។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ អគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវអភិក្រមការងារ ដូចខាងក្រោម÷

**២.១.១-ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស**

- អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនូវរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ដែលកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និងខែទី ២ និងការប៉ាន់ស្មានការអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២០ នៃខែ នាចុងត្រីមាសនីមួយៗ* ។
- មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្ត ដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និងខែទី ២ និងការប៉ាន់ស្មានអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១៥ នៃខែ នាចុងត្រីមាសនីមួយៗ ដើម្បីទុកពេលវេលាឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុបរួចផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ២០ នៃខែ នាចុងត្រីមាសនីមួយៗ* ។
- អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចរៀបចំប្រជុំពិភាក្សាតាមការចាំបាច់ជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២៥ នៃខែ នាចុងត្រីមាសនីមួយៗ* ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសកម្មវិធីចំណូល-ចំណាយ

សម្រាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាថវិកាក្នុងកម្រិតឥណទានថវិកាអតិបរមាសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទនីមួយៗ ដោយចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ ។

**២.១.២-ការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស**

អាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយអគ្គនាយកដ្ឋានថវិកា, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី-ខេត្ត ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និងត្រូវពិនិត្យ ទូទាត់ និងបើកសាច់ប្រាក់ តែនៅក្នុងកម្រិតនៃកម្មវិធីចំណូល-ចំណាយថវិកា និងសាច់ប្រាក់ប្រចាំត្រីមាសនេះតែប៉ុណ្ណោះ ។ ក្នុងករណីដែលអាណត្តិបើកប្រាក់លើសពីរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាស, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវធ្វើសំណើសុំបន្ថែមកម្មវិធីចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**២.១.៣-ការតាមដានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស**

• អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួង-ស្ថាប័នទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល-ចំណាយប្រចាំខែ មកអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់* ។

• អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបញ្ជូនមកឱ្យអគ្គនាយកដ្ឋានថវិកានូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ និងរបាយការណ៍បុរេប្រទានប្រចាំខែ និងត្រូវបញ្ជូនមកឱ្យអគ្គនាយកដ្ឋានគោលនយោបាយនូវរបាយការណ៍ចំណូល-ចំណាយថវិកា, របាយការណ៍បុរេប្រទាន និងតារាងតុល្យភាពគណនីថវិកាប្រចាំខែ ដើម្បីឱ្យអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយ តាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ, ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន និងវាយតម្លៃនូវស្ថានភាពនៃអនុវត្តធៀបនឹងខែមុន, ត្រីមាសមុននៃឆ្នាំនេះ និងប្រៀបធៀបទៅនឹងខែ, ត្រីមាសដូចគ្នានៃឆ្នាំមុន *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់* ។

**២.២-ការអនុវត្តការប្រមូលចំណូលថវិកា**

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យស្មើនឹង ១៨,៩០% នៃ ផ.ស.ស. គឺស្មើនឹង ២៣ ៤៦២,៦ ប៊ីលានរៀល ដែលកើនឡើង ១៧,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។ តាមគោលដៅនេះ÷

**២.២.១-ចំណូលចរន្តថ្នាក់ជាតិ** ត្រូវសម្រេចឱ្យបានចំនួន ២២ ១៥៧,៣ ប៊ីលានរៀល ត្រូវជា ១៧,៨៥% នៃ ផ.ស.ស. គឺមានការកើនឡើង ១២,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ÷

❖ **ចំណូលសារពើពន្ធ** ត្រូវសម្រេចឱ្យបានចំនួន ២០ ២២៧ ប៊ីលានរៀល ត្រូវជា ១៦,២៩% នៃ ផ.ស.ស. គឺមានកើនឡើង ១៥,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷

- ចំណូលគយនិងរដ្ឋាករ ត្រូវបានគ្រោងចំនួន ១០ ៤០០ ប៊ីលានរៀល ត្រូវជា ៨,៣៨% នៃ ផ.ស.ស. គឺមានការកើនឡើង ៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១

- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ៩ ៨២៧ ប៊ីលានរៀល ត្រូវជា ៧,៩១% នៃ ផ.ស.ស. គឺមានការកើនឡើង ២២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងពេលដែលនៅឆ្នាំ ២០២២ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬបង្កើនអត្រាពន្ធនោះទេ ។

❖ **ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន ១ ៩៣០,៣ ប៊ីលានរៀល ត្រូវជា ១,៥៥% នៃ ផ.ស.ស. គឺមានការថយចុះ ១១,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷

- ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតនៅថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន ១ ៧៥៦,២ ប៊ីលានរៀល ថយចុះ ៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១,
- ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីកាស៊ីណូ ឆ្នោត អាជ្ញាប័ណ្ណ ត្រូវបានគ្រោងចំនួន ១៧៤,២ ប៊ីលានរៀល ថយចុះ ២៩,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។

២.២.២-**ចំណូលមូលធន** ត្រូវបានគ្រោងចំនួន ៨ ៣៨៧ ប៊ីលានរៀល ត្រូវជា ៦,៧៥% នៃ ផ.ស.ស. គឺមានកំណើន ២៨,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ÷

❖ **ចំណូលមូលធនក្នុងប្រទេស** ដែលជាចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ និងការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវសម្រេចឱ្យបានចំនួន ១ ៣០៥,៣ ប៊ីលានរៀល ត្រូវជា ១,០៥% នៃ ផ.ស.ស. គឺមានកំណើន ៤៩០,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២១ ។

❖ **ចំណូលមូលធនក្រៅប្រទេស** ត្រូវសម្រេចឱ្យបានចំនួន ៧ ០៨១,៨ ប៊ីលានរៀល ត្រូវជា ៥,៧០% នៃ ផ.ស.ស. គឺមានកំណើន ១២,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷

- មូលនិធិទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន ១ ២៦៨,៣ ប៊ីលានរៀល ត្រូវជា ១,០២%នៃ ផ.ស.ស. គឺមានកំណើន ៤៧,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១
- ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់គម្រោងវិនិយោគ ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណង និងពីការខ្ចី ត្រូវបានគ្រោងចំនួន ៥ ៨១៣,៥ ប៊ីលានរៀល ត្រូវជា ៤,៦៨% នៃ ផ.ស.ស. គឺមានការកើនឡើង ៦,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។

ដើម្បីសម្រេចបានតាមគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវរៀបចំអនុវត្ត និងតាមដានជាប្រចាំ នូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលម្អិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារមានកាតព្វកិច្ចប្រមូលចំណូលពន្ធដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជាមធ្យមចំនួនប្រមាណ **៨១៨ ៩១៧ លានរៀល** ក្នុងមួយខែ ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានកាតព្វកិច្ចប្រមូលចំណូលពន្ធ និងអាករ ដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជាមធ្យមចំនួនប្រមាណ **៨៦៦ ៦៦៧ លានរៀល** ក្នុងមួយខែ ។ ដោយឡែក ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិត្រូវប្រមូលឱ្យបានជាមធ្យមចំនួនប្រមាណ **១៦០ ៨៦២ លានរៀល** ក្នុងមួយខែ ។ ទន្ទឹមនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលម្អិត និងតាមប្រភេទនិងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឱ្យតាមសាខា, ទីស្នាក់ការ ឬ/និងមន្ត្រីដែលមានកាតព្វកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត ដោយ

ផ្អែកលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ, កិច្ចសន្យាសម្បទាននានា, ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និងសង្វាក់នៃការប្រមូលចំណូលកន្លងមក ។ អង្គភាពប្រមូលចំណូលត្រូវតាមដាន និងជំរុញជាប្រចាំនូវការអនុវត្តកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និងរិះរកវិធានការឱ្យបានទាន់ពេលវេលាក្នុងករណីពិនិត្យឃើញថា ការប្រមូលចំណូលសម្រេចបានលទ្ធផលទាបជាងកម្មវិធីកំណត់ ។

## ២.៣-វិធានការអនុវត្តការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

សម្រាប់ក្នុងរយៈពេលបន្ទាន់ និងចំពោះមុខនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ រួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ ដើម្បីសម្រេចឱ្យបានតាមគោលដៅដែលបានគ្រោងទុក តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ ដូចខាងក្រោម÷

**២.៣.១-ផ្នែកចំណូលគយ និងរដ្ឋាករ÷** ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដាក់ចេញវិធានមួយចំនួន ដូចខាងក្រោម÷

- **ការបន្តពង្រឹងការងារបច្ចេកទេសគយ និងប្រសិទ្ធភាពនៃការប្រមូលចំណូល រួមមាន÷**
  - បន្តពង្រឹងការអនុវត្តយន្តការវាយតម្លៃហានិភ័យលើធុរជននិងទំនិញ ក្នុងការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ការធ្វើចំណាត់ថ្នាក់ទំនិញ និងការផ្ទៀងផ្ទាត់ដើមកំណើតទំនិញ,
  - បន្តជំរុញការអនុវត្តវិធានបញ្ជាក់ជាមុន (Advance Ruling),
  - បន្តពិនិត្យមុខសញ្ញាទំនិញដែលមានហានិភ័យ ដោយត្រូវកំណត់មាត់ច្រកនាំចូល,
  - លើកកម្ពស់ការយល់ដឹងរបស់ធុរជនលើការងារបច្ចេកទេសគយ និងនីតិវិធីនៃការបំពេញបែបបទគយតាមរយៈការផ្សព្វផ្សាយមគ្គុទ្ទេសក៍ និងវគ្គបណ្តុះបណ្តាលអំពីតម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញ និងការអនុវត្តអត្រាពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ព្រមទាំងនីតិវិធីគយជាធរមាន,
  - ពង្រឹងបន្ថែមក្នុងការអនុវត្តការងារបច្ចេកទេសគយដល់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធនឹងការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ការធ្វើចំណាត់ថ្នាក់ទំនិញ និងការផ្ទៀងផ្ទាត់ដើមកំណើតទំនិញ ។
- **ការបន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម រួមមាន÷**
  - បន្តធ្វើសាមញ្ញកម្មនីតិវិធីគយ និងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងកិច្ចប្រតិបត្តិការគយ,
  - បន្តធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានាឱ្យបានកាន់តែទូលាយ ដូចជាប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធបញ្ជរតែមួយជាតិជាដើម,
  - បន្តធ្វើសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀត,
  - បន្តអនុវត្តយន្តការលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់ តាមរយៈការផ្តល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើនចំនួនធុរជនល្អបំផុត,

- បន្តពង្រឹងប្រសិទ្ធភាពនៃការបង្ការ និងបង្ក្រាបបទល្មើសគយ តាមរយៈការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការវិភាគព័ត៌មានសម្ងាត់និងកម្រិតហានិភ័យ និងការចែករំលែកព័ត៌មានសម្ងាត់,
- ពង្រឹងអនុលោមភាពនៃការអនុវត្តនីតិវិធីដឹកជញ្ជូនទំនិញ និងការគ្រប់គ្រងស្តុកទំនិញនៅតាមបណ្តាមាត់ច្រកនាំចូល,
- បន្តពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធនិងអាករ និងបន្តធ្វើវិចារណកម្មលើមុខទំនិញដែលទទួលបានគោលការណ៍លើកទឹកចិត្ត,
- បន្តកែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យ,
- បន្តពង្រឹងយន្តការនិងពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,
- តាមដាន និងជំរុញការអនុវត្តបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជរបស់ WTO,
- ពង្រឹងការត្រួតពិនិត្យលើការបំពេញបែបបទបញ្ចេញទំនិញពីគយលើមុខទំនិញរបស់ក្រុមហ៊ុនដែលនាំចេញនាំចូលមិនស្របតាមសកម្មភាពចម្បងនៃអាជីវកម្មរបស់ខ្លួន,
- ពង្រឹងការត្រួតពិនិត្យប្រវត្តិទំនិញ តាមគោលការណ៍គ្រប់គ្រងហានិភ័យ,
- ជំរុញការអនុវត្តនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing),
- បន្តជំរុញនិងពង្រីកការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ។

❖ **ការបន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច៖**

- បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើចំណូលពន្ធអាករគយដែលបាត់បង់ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា និងការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូលជាដើម,
- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលក្នុងករណីចាំបាច់,
- កែលម្អគោលនយោបាយពន្ធនិងអាករ សម្រាប់វិស័យអាទិភាពនានា,
- កែលម្អគោលនយោបាយពន្ធនិងអាករលើមុខទំនិញគេលសិលា និងថាមពល ស្របតាមតម្រូវការចាំបាច់ និងការវិវត្តមុខទំនិញទាំងនេះ,
- បន្តចូលរួមកែលម្អ និងអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជាវិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូចនិងមធ្យម,
- ពង្រឹងការងារសវនកម្មផ្ទៃក្នុង ដើម្បីធានានូវការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវ និងអនុលោមភាពច្បាប់ ។

**២.៣.២-ផ្នែកចំណូលពន្ធដារ៖** ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអនុវត្តវិធានការមុតស្រួច ដូចខាងក្រោម៖

❖ វិធានការគោលនយោបាយ

- បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីបង្កើនការប្រមូលចំណូលពន្ធ,
- បន្តរៀបចំយន្តការសំខាន់ៗសម្រាប់ពង្រឹងការអនុវត្តតារាងឧបសម្ព័ន្ធតម្លៃអចលនទ្រព្យថ្មីសម្រាប់មូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ និងតម្លៃមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ,
- កែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការស៊ើបអង្កេតបទល្មើសពន្ធដារ,
- តាមដាន វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ,
- បន្តតាមដាន វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តគោលនយោបាយពន្ធដារកម្ពុជា,
- បន្តចរចាជាមួយបណ្តាប្រទេសនានា ព្រមទាំងរដ្ឋសមាជិកអាស៊ាន, អាស៊ានបូក ៣ ដែលនៅសេសសល់ លើការងារកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) ដើម្បីជំរុញកំណើនវិនិយោគពីបរទេស និងបង្កើនមូលដ្ឋានពន្ធ,
- ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- ពិនិត្យលទ្ធភាពលើការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន,
- ពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ ។

❖ វិធានការរដ្ឋបាលសារពើពន្ធ

(១). ការចុះបញ្ជីអ្នកជាប់ពន្ធ

- បន្តពង្រឹងការប្រមូលផ្តុំព័ត៌មានអចលនទ្រព្យ តាមរយៈការចុះផ្តល់សេវាពន្ធដារលើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យដល់ទីកន្លែងនៅតាមបណ្តាខេត្ត,
- បន្តជំរុញការចុះបញ្ជីចំពោះសហគ្រាសថ្មីៗ ដើម្បីបង្កើនមូលដ្ឋានអ្នកជាប់ពន្ធ (Tax Base),
- រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងការចុះបញ្ជីពន្ធដារ,
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុលពន្ធ ដើម្បីសម្រួលដល់ការចុះបញ្ជីពន្ធដាររបស់អ្នកជាប់ពន្ធ,
- ជំរុញការចុះបញ្ជីសហគ្រាសឱ្យបាន ២០% ក្នុងមួយឆ្នាំ ធៀបនឹងចំនួនសហគ្រាសដែលបានអង្កេតក្នុងឆ្នាំ ២០១៧-២០១៨,
- ជំរុញការចុះបញ្ជីអ្នកជាប់ពន្ធតាមរយៈទិន្នន័យចុះបញ្ជីពីក្រសួង-ស្ថាប័នពាក់ព័ន្ធ,
- ពង្រឹងការផ្ទេរសហគ្រាសពីតូចទៅមធ្យម និងមធ្យមទៅធំ និងបញ្ច្រាសមកវិញ,
- បន្តពង្រឹងការកៀរសហគ្រាសដែលបាត់ខ្លួន ក្នុងគោលដៅលុបចេញពីបញ្ជីអ្នកជាប់ពន្ធ ។

(២). ការផ្តល់សេវាអ្នកជាប់ពន្ធ

- ពង្រឹងការពិគ្រោះយោបល់នៅបញ្ជរផ្ទាល់ និងទទួលភ្ជាប់ពី Call Center សម្រាប់ការស្នើសុំបង់ពន្ធប្រថាប់ត្រាលើផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើចំណេញមូលធន,
- ពង្រឹងការផ្សព្វផ្សាយអប់រំដល់សាធារណជន អាជ្ញាធរដែនដី និងមន្ត្រីរាជការនៅស្ថាប័ននានា ដើម្បីបញ្ច្រាបវប្បធម៌បង់ពន្ធ តាមរយៈសិក្ខាសាលា ការផ្សព្វផ្សាយតាមគេហទំព័រ បណ្តាញទំនាក់ទំនងសង្គម (Facebook) នៃអគ្គនាយកដ្ឋានពន្ធដារ និងបណ្តាញព័ត៌មានផ្សេងៗ,
- រៀបចំកម្រងសំណួរ និងប្រមូលទិន្នន័យអំពីការពេញចិត្តរបស់អ្នកជាប់ពន្ធលើការផ្តល់សេវានៃការបង់ពន្ធប្រថាប់ត្រា និងពន្ធលើអចលនទ្រព្យ,
- ពន្លឿនការឆ្លើយតបចម្ងល់ និងបញ្ហារបស់អ្នកជាប់ពន្ធ,
- រៀបចំសិក្ខាសាលាស្តីពីការផ្ទេរថ្លៃចំនួនពីរដងក្នុងមួយឆ្នាំ,
- រៀបចំវេទិកាស្តីពីថ្ងៃពន្ធដាឱ្យបានយ៉ាងតិចមួយដងក្នុងមួយឆ្នាំ,
- ធ្វើការអប់រំអ្នកជាប់ពន្ធក្នុងអំឡុងពេលសវនកម្ម,
- បន្តរៀបចំវគ្គបណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារ និងចេញវិញ្ញាបនបត្រភ្នាក់ងារសេវាកម្មពន្ធដារ,
- បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាពាក់ព័ន្ធនឹងពន្ធដារ,
- រៀបចំវគ្គបណ្តុះបណ្តាលសាធារណជនអំពីជំនាញពន្ធដារ រួមទាំងការបណ្តុះបណ្តាលនៅតាមបណ្តាសាកលវិទ្យាល័យ,
- រៀបចំកម្រងសំណួរ-ចម្លើយជាប្រចាំ (FAQs) ដែលអ្នកជាប់ពន្ធងាយស្វែងរកបានតាមប្រព័ន្ធអេឡិចត្រូនិក,
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ Call Centre ដើម្បីឆ្លើយតបទៅអ្នកជាប់ពន្ធ ប្រកបដោយវិជ្ជាជីវៈ និងទាន់ពេលវេលា,
- បន្តផ្តល់មធ្យោបាយក្នុងការពិគ្រោះយោបល់ដែលមានភាពងាយស្រួល រហ័ស ដូចជា GDT Live Chat, Email, Call Center (1277), Facebook និងពិគ្រោះយោបល់ដោយផ្ទាល់,
- បន្តរៀបចំសិក្ខាសាលាស្តីពីច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជូនអ្នកជាប់ពន្ធ ព្រមទាំងសិក្ខាសាលាផ្សព្វផ្សាយស្តីពីវិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ ក៏ដូចជាសិក្ខាសាលាស្តីពីកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា,
- ពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការដោះស្រាយរាល់ចម្ងល់ និងបញ្ហាផ្សេងៗរបស់អ្នកជាប់ពន្ធតាមរយៈលិខិត និងជួបអ្នកជាប់ពន្ធផ្ទាល់ឱ្យបានឆាប់រហ័ស,

- បន្តធ្វើការអប់រំអ្នកជាប់ពន្ធតាមរយៈវេទិកាផ្សាយផ្ទាល់ស្តីពីពន្ធដារ ដូចជា កម្មវិធីពន្ធដារកម្ពុជា - GDT Cambodia ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន,
- រៀបចំកម្មវិធី និងជួបពិភាក្សាជាមួយវិស័យឯកជន ក៏ដូចជាចូលរួមក្នុងវេទិកា/ សិក្ខាសាលា/ កម្មវិធីពាក់ព័ន្ធនឹងពន្ធដារ ដែលរៀបចំដោយវិស័យឯកជន ឬស្ថាប័នផ្សេងទៀត,
- ទទួលមតិយោបល់ត្រលប់ពីអ្នកជាប់ពន្ធតាមគ្រប់មធ្យោបាយ ដើម្បីកែលម្អរដ្ឋបាលសារពើពន្ធ,
- រៀបចំនិងធ្វើបច្ចុប្បន្នភាពខិត្តប័ណ្ណផ្សព្វផ្សាយ និងឃ្លីបអំពីប្រភេទពន្ធនីមួយៗ ដើម្បីផ្សព្វផ្សាយអំពីវប្បធម៌នៃការបង់ពន្ធ និងកាតព្វកិច្ចពន្ធដារ,
- ការផ្សព្វផ្សាយជូនដល់អ្នកជាប់ពន្ធស្តីពីការស៊ើបអង្កេតបទល្មើសពន្ធដារ តាមរយៈការរៀបចំសិក្ខាសាលា ឯកសារបោះពុម្ព និងឃ្លីបផ្សព្វផ្សាយ,
- បន្តកែលម្អគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការស្វែងរកព័ត៌មានឱ្យបានងាយស្រួលនិងឆាប់រហ័ស,
- រៀបចំផែនការ និងពង្រីកបញ្ជរពិគ្រោះយោបល់នៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ ដើម្បីទទួលសំណួរ សំណូមពរ និងឆ្លើយតបរាល់ចម្ងល់របស់អ្នកជាប់ពន្ធដោយផ្ទាល់មាត់,
- ផ្តល់សេវាឱ្យបានទាន់ពេលវេលាស្របតាមកម្រងសេវាសាធារណៈចំពោះការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដោយផ្សព្វផ្សាយជាសាធារណៈអំពីបញ្ជីរំហូរការងារ និងវីដេអូខ្លីអំពីការចុះបញ្ជី និងបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ,
- ពង្រឹង និងពន្លឿនយន្តការបង្វិលសងអាករលើតម្លៃបន្ថែម តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិ,
- ពន្លឿនការពិនិត្យឯកសារបង្វិលសង និងការផ្ទៀងផ្ទាត់វិក្កយបត្រព្រមទាំងឯកសារពាក់ព័ន្ធ ។

**(៣). ការចាត់ចែងលិខិតប្រកាស**

- ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ E-Filing និង E-payment ដើម្បីកាត់បន្ថយការជួបផ្ទាល់រវាងអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារ,
- បន្តពង្រឹងការពិនិត្យផ្ទៀងផ្ទាត់វិក្កយបត្រអាករលើតម្លៃបន្ថែម និងប្រភេទពន្ធផ្សេងៗ,
- ពង្រីកសេវាជូនដំណឹង ឬរំលឹកអ្នកជាប់ពន្ធមកដាក់លិខិតប្រកាសពន្ធទាន់ពេលវេលា តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,
- បន្តពង្រឹងការផ្ទៀងផ្ទាត់លើលិខិតប្រកាសចំពោះចំណូល-ចំណាយ និងគណនីយោង ដោយផ្អែកលើហានិភ័យ,
- បន្តពង្រឹងការព្យួរ ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ចំពោះសហគ្រាសដែលប្រកាសគ្មានផលរបរ ៣ ខែ ឬ ៦ ខែជាប់គ្នា,
- បន្តជំរុញការដាក់លិខិតប្រកាសឱ្យបានទាន់ពេលកំណត់ចំពោះសហគ្រាសដែលបានបង់ពន្ធ តែមិនបានដាក់លិខិតប្រកាស,

- ពង្រឹងការដាក់លិខិតប្រកាសពន្ធតែមប្រិ៍សារពើពន្ធ តាមរយៈការធ្វើបច្ចុប្បន្នភាពបញ្ជីសហគ្រាសមិនបានដាក់លិខិតប្រកាស,
- ពង្រឹងការប្រកាសបង់ពន្ធលើអចលនទ្រព្យ ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រងពន្ធលើអចលនទ្រព្យ ។

**(៤). ការធ្វើសវនកម្ម**

- ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យប្រភពចំណូល ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច (Business Cycle),
- ពង្រឹងការត្រួតពិនិត្យលើការប្រកាសបង់ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់តាមរយៈការអញ្ជើញម្ចាស់អចលនទ្រព្យដោយផ្ទាល់ ការត្រួតពិនិត្យការប្រកាសបង់ពន្ធឡើងវិញនៅពេលអ្នកជាប់ពន្ធស្នើសុំបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះ,
- បន្តអញ្ជើញម្ចាស់អចលនទ្រព្យធំៗឱ្យមកបង់ពន្ធលើអចលនទ្រព្យឬពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- បន្តជ្រើសរើសអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ដោយមានការដាក់ពិន្ទុតាមបែបវិទ្យាសាស្ត្រច្បាស់លាស់សម្រាប់ជាអាទិភាពក្នុងការធ្វើសវនកម្ម,
- អនុវត្តតាមប្រកាសលេខ ២៧០ សហវ. ប្រក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៩ ស្តីពីសវនកម្មពន្ធដារ,
- កាត់បន្ថយការធ្វើសវនកម្មត្រួតជាន់គ្នា ដើម្បីសម្រួលបន្ទុករបស់អ្នកជាប់ពន្ធ (សវនកម្មពេញលេញ និងមានកម្រិត),
- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យ និងធ្វើបច្ចុប្បន្នភាពរៀងរាល់ ២ ឆ្នាំម្តង,
- រៀបចំរបាយការណ៍ស្តីពីការជ្រើសរើសអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់សម្រាប់ជាអាទិភាពក្នុងការធ្វើសវនកម្ម,
- រៀបចំកិច្ចប្រជុំវាយតម្លៃប្រចាំខែ រវាងថ្នាក់ដឹកនាំទទួលបន្ទុក និងសវនករ,
- បន្តពង្រឹងការអនុវត្តការប្រើប្រាស់តែមប្រិ៍សម្រាប់បារី តាមរយៈការចុះត្រួតពិនិត្យការបិទតែមប្រិ៍លើបារីដែលផ្គត់ផ្គង់ដោយភ្នាក់ងារចែកចាយ ផ្សារទំនើប និងហាងលក់ទំនិញ,
- ទប់ស្កាត់ការចៀសវាង និងការកិបកេងបន្លំពន្ធតាមរយៈការពង្រឹងការធ្វើសវនកម្មចំពោះសហគ្រាសដែលជាបុគ្គលទាក់ទិន ឬសហគ្រាសសម្ព័ន្ធញាតិ,
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ តាមរយៈការជ្រើសរើសអង្គភាពរងសវនកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពនិងគុណភាពការងារ របស់អង្គភាពចំណុះអគ្គនាយកដ្ឋានពន្ធដារ,
- ពង្រឹងប្រសិទ្ធភាព និងគុណភាពការងារតាមរយៈការអនុវត្តអនុសាសន៍ជាលទ្ធផលនៃសវនកម្មផ្ទៃក្នុងដែលស្របតាមមុខងារ វិធាន និងនីតិវិធីជាធរមាន និងរាយការណ៍ពីផែនការសកម្មភាពសម្រាប់កែលម្អ ។

**(៥). ការស៊ើបអង្កេត÷**ពង្រឹងមុខងារស៊ើបអង្កេតបទល្មើសពន្ធដារឱ្យមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ និងបង្ក្រាបការគេចវេះពន្ធ និងការប្រព្រឹត្តបទល្មើសពន្ធដារ តាមរយៈ÷

- ការបន្តរៀបចំ កែលម្អ និងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសពន្ធដារ,
- ការពង្រឹងការប្រមូលព័ត៌មាន និងទទួលព័ត៌មានសម្ងាត់ឱ្យទាន់ពេលវេលា ដើម្បីកំណត់ និងជ្រើសរើសអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ,
- ការបន្តរៀបចំ កែលម្អ និងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីវិធីសាស្ត្រក្នុងការកំណត់ហានិភ័យអ្នកជាប់ពន្ធដើម្បីកំណត់អត្តសញ្ញាណអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ ដើម្បីឱ្យមានភាពពេញលេញ និងឆ្លើយតបនឹងការវិវឌ្ឍបរិបទធុរកិច្ច,
- ការបង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មលើការកំណត់អត្តសញ្ញាណអ្នកប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយផ្អែកលើសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសពន្ធដារ,
- ការពង្រឹងការអនុវត្តនីតិវិធីស៊ើបអង្កេតបទល្មើសពន្ធដារ រួមមាន÷
    - ការស្វែងរកអ្នកជាប់ពន្ធ និង/ឬឃាត់ខ្លួនអ្នកជាប់ពន្ធមកសាកសួរ,
    - ការដាក់បណ្តឹងទៅព្រះរាជអាជ្ញានិងតុលាការ,
    - ការឆែកឆេរ និងរឹបអូសឯកសារនិងភ័ស្តុតាង,
    - ការឃុំគ្រងទ្រព្យសម្បត្តិ និងឃាត់ខ្លួនជនសង្ស័យ ។
- ការជ្រើសរើសអ្នកជាប់ពន្ធដែលគេចវេះពន្ធធ្ងន់ធ្ងរដើម្បីធ្វើការស៊ើបអង្កេត,
- ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានកំណត់បទល្មើពន្ធដារ ស៊ើបអង្កេតបទល្មើសពន្ធដារ និងប្តឹងចោទប្រកាន់បទល្មើសទៅព្រះរាជអាជ្ញានិងតុលាការ និងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារស៊ើបអង្កេតបទល្មើសពន្ធដារ ។

**(៦). ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា**

- បន្តជំរុញការប្រមូលបំណុលពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- ដោះស្រាយរាល់ការតវ៉ានានាពាក់ព័ន្ធនឹងពន្ធលើវិស័យអចលនទ្រព្យ,
- អនុវត្តវិធានការទារ និងតឹងទារបំណុលពន្ធចំពោះសហគ្រាសដែលមានហានិភ័យខ្ពស់,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងបំណុល (Tax Arrears System),
- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ តាមរយៈការចុះអង្កេតដល់ទីតាំងសហគ្រាសក្នុងគោលដៅគ្រប់គ្រងបំណុលពន្ធឱ្យមានប្រសិទ្ធភាព,
- កំណត់បំណុលពន្ធជាអាទិភាពដែលអាចប្រមូលបានតាមរយៈការធ្វើចំណាត់ថ្នាក់បំណុលពន្ធ,
- បន្តពង្រឹងការអនុវត្តការប្រមូលបំណុលពន្ធ និងវិធានការតឹងទារបំណុលពន្ធ,

- បង្កើតមធ្យោបាយបន្ថែមក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការអញ្ជើញមកទូទាត់បំណុលពន្ធឱ្យបានលឿនដល់សហគ្រាសតាមរយៈសារអេឡិចត្រូនិក,
- បង្កើតយន្តការផ្តល់ព័ត៌មាន និងរំលឹកអ្នកជាប់ពន្ធអំពីបំណុលពន្ធចលនទ្រព្យនិងអចលនទ្រព្យ,
- បន្តពង្រឹងលទ្ធផលដោះស្រាយបណ្តឹងតវ៉ាពន្ធដារ តាមរយៈការដាក់ចេញនូវកម្មវិធីប្រជុំវាយតម្លៃប្រចាំខែ រវាងថ្នាក់ដឹកនាំទទួលបន្ទុក និងមន្ត្រី ដើម្បីដោះស្រាយបញ្ហាប្រឈម ។

**(៧). បច្ចេកវិទ្យាព័ត៌មាន**

- ធ្វើទំនើបកម្មនូវប្រព័ន្ធ E-Filing និង E-Payment ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធ E-Filling,
- រៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មលើការកំណត់ហានិភ័យអ្នកជាប់ពន្ធត្រូវបានបង្កើត និងធ្វើតេស្តសាកល្បង,
- កសាង និងអនុវត្តប្រព័ន្ធត្រួតពិនិត្យដំណើរការប្រតិបត្តិការស្ទួលទាន់ពេលវេលា ដើម្បីពង្រឹងប្រសិទ្ធភាពតាមដានវឌ្ឍនភាពសូចនាករសមិទ្ធកម្មគន្លឹះ,
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,
- សិក្សា និងពិនិត្យលទ្ធភាព ដើម្បីឈានបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួម (Big Data),
- ចូលរួមជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៃច្រកចេញចូលនៃប្រព័ន្ធអ៊ិនធឺណិតជាតិ (National Internet Gateway) និងប្រព័ន្ធទូទាត់ (Payment Gateway),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស (Biz Registration System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី លើប្រព័ន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្តតាម Online (Online Vehicle Transferring Management System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធចុះបញ្ជីតាម Online (Online Registration System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីលើប្រព័ន្ធ Help Desk System ដើម្បីផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាព, ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីលើកម្មវិធីពិនិត្យ និងតាមដានឯកសារ (GDT Check & Track App),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងសវនកម្ម (Tax Audit System),

- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីអចលនទ្រព្យ (Property Tax System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធគ្រប់គ្រងសន្លឹកតែមប្រិ៍ (Stamp Management System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធបង់ប្រាក់ពន្ធតាម Online (E-Payment System) និងអាចដំណើរការលើ Smart Devices បាន,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងការបង់ពន្ធ (Tax Payment Single Invoice System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងតាមដានឯកសារ (Document Tracking System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ចំណូលពន្ធដារដើម្បីងាយស្រួលក្នុងការពិនិត្យ តាមដាន និងវិភាគលើចំណូល (Tax Revenue Reporting System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HR System),
- អនុវត្តផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសារពើពន្ធ ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញនិងប្រទាក់ក្រឡា, ប្រព័ន្ធវិភាគទិន្នន័យ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអ្នកជាប់ពន្ធពេញលេញ, ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ និងប្រព័ន្ធចែករំលែកទិន្នន័យអន្តរស្ថាប័ន ដោយរួមបញ្ចូលទាំងផែនការវិនិយោគ,
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជានាប្រសិទ្ធភាពការងារ,
- មន្ត្រីពាក់ព័ន្ធអាចរកឯកសារសម្រាប់គោលបំណងសវនកម្ម និងស៊ើបអង្កេត តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យ,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធផ្លាស់ប្តូរទិន្នន័យ (សន្ទានកម្ម) របស់អគ្គនាយកដ្ឋានពន្ធដារ ជាមួយប្រព័ន្ធផ្លាស់ប្តូរទិន្នន័យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធផ្លាស់ប្តូរទិន្នន័យ (សន្ទានកម្ម) របស់អគ្គនាយកដ្ឋានពន្ធដារជាមួយប្រព័ន្ធផ្លាស់ប្តូរទិន្នន័យរបស់ FMIS និងក្រសួងសាធារណការនិងដឹកជញ្ជូន,
- ជំរុញ និងពង្រឹងការផ្តល់ឯកសារពាក់ព័ន្ធនឹងអ្នកជាប់ពន្ធឱ្យបានត្រឹមត្រូវ និងទៀងទាត់តាមគោលការណ៍ណែនាំ ដើម្បីរក្សាទុកក្នុងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ និងឃ្លាំងឯកសារ ។

**២.៣.៣-ផ្នែកចំណូលមិនមែនសារពើពន្ធ÷** ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ វិធានការមួយចំនួននឹងត្រូវដាក់ចេញ ដូចខាងក្រោម÷

- ពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នប្រមូលចំណូល ដើម្បីបន្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ អនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីពង្រឹងការគ្រប់គ្រងស្ថាប័ន ការទទួលខុសត្រូវច្បាស់លាស់ ការដាក់ទណ្ឌកម្ម សវនកម្ម និងអធិការកិច្ច ជាដើម,
- ពង្រីកវិសាលភាពការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដល់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់,
- ពង្រីកវិសាលភាពការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) នៅរដ្ឋបាលថ្នាក់ជាតិសម្រាប់ជំហានទី ៣,
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់,
- ជំរុញអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមអនឡាញដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ,
- បន្តស្វែងរកមុខចំណូលថ្មីៗ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលដែលមានស្រាប់ ពិសេសមុខចំណូលដែលមិនប៉ះពាល់ដល់កម្រិតជីវភាពរបស់ប្រជាជនទូទៅ,
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល,
- បន្តពង្រឹងការគ្រប់គ្រង និងអនុវត្តនូវកិច្ចសន្យាជួលអគារ អចលនទ្រព្យ ជួលកោះ និងឆ្នេរ ដោយផ្អែកលើគោលការណ៍ទីផ្សារ ព្រមទាំងតាមដានយ៉ាងម៉ឺងម៉ាត់ការអនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុនការបង់ចំណូលចូលរដ្ឋ និងការអនុវត្តយន្តការទឹងទារបំណុល ពិន័យ លុបចោលកិច្ចសន្យា ឬដកហូតដកប្រាក់កក់ ក្នុងករណីក្រុមហ៊ុនមិនបំពេញតាម,
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

**២.៤-ការអនុវត្តចំណាយថវិកា**

រាជរដ្ឋាភិបាលត្រូវចំណាយថវិការដ្ឋសរុបចំនួន ៣៤ ៧០៨,៦ ប៊ីលានរៀល ត្រូវជា ២៧,៩៥% នៃ ផ.ស.ស. មានកំណើន ៨,៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ។ **ចំណាយចរន្តថវិកាថ្នាក់ជាតិ** មានចំនួន ១៩ ១១១,៧ ប៊ីលានរៀល ត្រូវជា ១៥,៣៩% នៃ ផ.ស.ស. គឺកើនឡើង ៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។ **ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោង ១៣ ៤៦៥,២ ប៊ីលានរៀល, មានសមាមាត្រស្មើនឹង ៤១,៣% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ១០,៨៤% នៃ ផ.ស.ស., កើនឡើង ៣,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។

ទន្ទឹមនេះ ដើម្បីធានាបានថា ថវិកាឆ្នាំ ២០២២ ពិតជាដើរតួនាទីជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពពិតប្រាកដសម្រាប់អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល, ការគ្រប់គ្រងនូវការអនុវត្តថវិកាត្រូវតែហ្មត់ចត់ និងម៉ឺងម៉ាត់ ទាំងក្នុងការគ្រប់គ្រង, ការប្រមូលចំណូល និងក្នុងការអនុវត្តចំណាយ ដោយត្រូវពង្រឹងការគោរពច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ, ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុដទៃទៀត ជាពិសេសការអនុវត្តចំណាយត្រូវមានប្រសិទ្ធភាព ចំទិសដៅអាទិភាពពិតប្រាកដ មានភាពសន្សំសំចៃខ្ពស់ និងស្ថិតក្នុងរង្វង់នៃលទ្ធភាពឥណទានថវិកាដែលមាន ។ ទន្ទឹមគ្នានេះដែរ ត្រូវជំរុញអនុវត្តឱ្យបានជោគជ័យនូវបណ្តាផែនការសកម្មភាព និងវិធានការកែលម្អការគ្រប់គ្រងថវិកា និងបន្តដាក់ចេញនូវផែនការសកម្មភាព និងវិធានការថ្មីៗទៀត ដើម្បីជម្នះ និងទប់ទល់ផលប៉ះពាល់អវិជ្ជមាននានាបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមផ្សេងៗទៀតដែលអាចកើតមានជាយថាហេតុ ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមគូសរំលេចនូវបណ្តានីតិវិធីហិរញ្ញវត្ថុសាធារណៈ និងវិធានការអនុវត្តដូចខាងក្រោម÷

**២.៤.១-ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម**

ការស្នើសុំ និងការផ្តល់ធានាចំណាយ ត្រូវអនុវត្តតាមប្រភេទចំណាយធំៗបី ដូចខាងក្រោម÷

• **ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)÷** ចំណាយដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខ័ណ្ឌ និងកាំប្រាក់ពីក្រសួងមុខងារសាធារណៈដែលមានគោលរបប និងគោលការណ៍កំណត់ ពុំតម្រូវឱ្យមានការសុំធានាចំណាយដាច់ដោយឡែកឡើយ ដោយអនុញ្ញាតឱ្យបោះផ្សាយអាណត្តិបើកប្រាក់ ដោយឈរលើមូលដ្ឋានឥណទានថវិកាដែលមានតែម្តង ។ ក្នុងន័យនេះ ជាយថាហេតុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចនឹងចាត់វិធានការបង្កកឥណទានថវិកាចំណាយជំពូកផ្សេងទៀត ក្នុងករណីពិនិត្យឃើញថា ឥណទានថវិកាបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័នមានមិនគ្រប់ចំនួន ស្របតាមការគណនាដោយផ្អែកលើទិដ្ឋាការបញ្ជាក់ពីភាពត្រឹមត្រូវនៃចំនួនក្របខ័ណ្ឌ និងកាំប្រាក់ពីក្រសួងមុខងារសាធារណៈ ។ ដូច្នេះ ក្នុងពេលអនុវត្ត ក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់ប្រកប-ដោយការទទួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រងឥណទានថវិកាបន្ទុកបុគ្គលិកនេះ ឱ្យបានគ្រប់គ្រាន់ ដើម្បីចៀសវាងការរាំងស្ទះដល់ការបើកផ្តល់ប្រាក់បៀវត្ស ។ ឥណទានថវិកាជំពូក ៦៤ នឹងមិនត្រូវបានអនុញ្ញាតឱ្យបន្ថែមជូននោះទេ វៀរលែងតែក្នុងករណីមានតម្រូវការបន្ថែមដោយសាររាជរដ្ឋាភិបាលមានការកែប្រែគោលនយោបាយឬផ្តល់គោលការណ៍ដោយឡែក ដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័នជ្រើសរើសក្របខ័ណ្ឌថ្មី ជាពិសេសក្នុងអំឡុងឆ្នាំអនុវត្ត ។ ទន្ទឹមនេះ អនុវត្តតាមការសម្រេចរបស់រាជរដ្ឋាភិបាល លើវិធានការគ្រប់គ្រងបន្ទុកបុគ្គលិកនេះ, គ្រប់ក្រសួង-ស្ថាប័នត្រូវគោរពឱ្យបានម៉ឺងម៉ាត់តាមគោលការណ៍÷ (១)-ការដំឡើងឋានន្តរស័ក្តិនិងថ្នាក់ជូនមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីរាជការស៊ីវិលផ្សេងៗទៀត មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទសម្រាប់ឆ្នាំ ២០២១ និងឆ្នាំ ២០២២ ត្រូវអនុវត្តជាធម្មតាអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និង (២)-ការបម្រែបម្រួលស្ថានភាពថវិកានៅក្នុងតារាងទូទាត់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល នៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីរាជការស៊ីវិល

ផ្សេងទៀត មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទ ដែលត្រូវបានដំឡើងឋានន្តរស័ក្តិ និងថ្នាក់នៅឆ្នាំ ២០២១ និងឆ្នាំ ២០២២ ត្រូវបានអនុវត្តចាប់ពីខែ ឧសភា ឆ្នាំ ២០២២ ដោយមិនមានការអនុវត្តប្រតិសកម្មឡើយ ។

ជាមួយគ្នានេះ, គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវ÷

- ពង្រឹងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់នូវចំនួនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ក្នុងគោលបំណងផ្ទៀងផ្ទាត់ធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីក្របខ័ណ្ឌចូលថ្មី ក្នុងករណីមានការសម្រេចដោយឡែកពីប្រមុខរាជរដ្ឋាភិបាល ។ ទន្ទឹមនេះ មន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលត្រូវចូលបម្រើការងារវិញ ត្រូវតែជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ ។

- ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការប្រើប្រាស់ប្រាក់រង្វាន់ពីកម្រៃសេវាសាធារណៈ ទាំងសម្រាប់ការលើកទឹកចិត្តដល់មន្ត្រីរាជការ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងទាំងសម្រាប់គាំទ្រដល់ការពង្រឹងយន្តការប្រមូលចំណូល ។

- **ចំណាយក្រៅបន្ទុកបុគ្គលិក÷** រួមមាន ចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ចំណាយលើអគ្គិសនី ទឹក ទូរស័ព្ទ ទូរគមនាគមន៍ និងចំណាយផ្សេងៗទៀតដែលមានគោលការណ៍ និងគោលរបបកំណត់រួចហើយ ពុំតម្រូវឱ្យមានការស្នើសុំធានាចំណាយឡើយ ។

ពាក់ព័ន្ធនឹងមុខសញ្ញាចំណាយតាមរជ្ជទេយ្យបុរេប្រទាន ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវរៀបចំបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ដោយត្រូវកម្រិតកំណត់ទឹកប្រាក់តាមមុខសញ្ញាចំណាយឱ្យសមស្របតាមចរិតចំណាយតាមរជ្ជទេយ្យបុរេប្រទាន ដូចមានលម្អិតក្នុងឧបសម្ព័ន្ធទី ១ នៃប្រកាស ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ដោយចៀសវាងយកចំណាយដែលជាកម្មវត្ថុសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឬអនុវត្តតាមនីតិវិធីទូទាត់ត្រង់ មកគ្រោងចូលក្នុងរជ្ជទេយ្យបុរេប្រទាន ហើយពុះច្រៀកការទិញ ឬចំណាយ ឬបំបែកគម្រោងជាគម្រោងតូចៗ ។ ដោយឡែក ចំពោះអាជ្ញាធរ ឬអង្គភាពថវិកាដែលមានមាតិកាចំណាយតែមួយខ្ទង់ក្នុងជំពូក ៦៥ "ឧបត្ថម្ភធន" ត្រូវរៀបចំតារាងលម្អិតផ្ទៃក្នុងតាមមុខសញ្ញាចំណាយតាមមាតិកាថវិកានៃចំណាត់ថ្នាក់សេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានច្បាស់លាស់ក្នុងការបង្កើតរជ្ជទេយ្យបុរេប្រទាន ស្របតាមឧបសម្ព័ន្ធទី ១ នៃប្រកាស ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ដោយមិនមែនផ្អែកតាមមូលដ្ឋាន ៣០% ធៀបនឹងឥណទានថវិកាសរុបនៃអនុគណនីដែលមានមួយខ្ទង់នៃជំពូក ៦៥ "ឧបត្ថម្ភធន" នោះទេ ។

ចំពោះចំណាយប្រាក់បេសកកម្មក្នុងប្រទេស, ចំណាយសម្រាប់ការបណ្តុះបណ្តាល កិច្ចប្រជុំផ្សេងៗ សិក្ខាសាលា ត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងតាមនីតិវិធីទូទាត់ត្រង់ ដោយត្រូវអនុលោមតាមអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ

និងប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។ ចំពោះចំណាយប្រភេទនេះ អាណាប័កត្រូវគ្រោងចំណាយសម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន តាមរយៈរដ្ឋទេយ្យករបុរេប្រទាន និងតាមនីតិវិធីទូទាត់ត្រង់ ទៅតាមស្ថានភាពអនុវត្តជាក់ស្តែង ។ រដ្ឋទេយ្យករបុរេប្រទាន/រដ្ឋទេយ្យករបុរេប្រទានរង ត្រូវទុកដាក់ថែរក្សានូវសាច់ប្រាក់ដែលបានទទួលពីគណនេយ្យករសាធារណៈ ព្រមទាំង ទុកដាក់ថែរក្សាលិខិតយុត្តិការកាន់កាប់បញ្ជីបេឡាដោយឡែកសម្រាប់តាមដានចំណូល-ចំណាយ និងប្រាក់ដែលនៅសល់ ។ ទន្ទឹមនេះ ការទូទាត់ត្រូវបានអនុញ្ញាតឱ្យធ្វើទៅតាមទំហំទឹកប្រាក់ចំណាយជាក់ស្តែង ដោយមិនមានកំណត់ទឹកប្រាក់អតិបរមាក្នុងមួយសក្ខីប័ត្រចំណាយឡើយ ។ អាណាប័កត្រូវប្រមូល និងរៀបចំអាណត្តិបើកប្រាក់/អាណត្តិនិយ័តកម្ម និងលិខិតយុត្តិការចំណាយដើម្បីស្នើសុំទូទាត់តែម្តង ។ ទោះជាយ៉ាងនេះក្តី ក៏មិនមានន័យថា អាណាប័កនឹងទទួលបានការទូទាត់ ឬការបើកផ្តល់តាមសំណើជាស្វ័យប្រវត្តិនោះទេ ។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវផ្តោតការយកចិត្តទុកដាក់ ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរៀបចំសំណើឱ្យទាន់ពេលវេលា ដោយភ្ជាប់មកជាមួយនូវឯកសារ និងលិខិតយុត្តិការត្រឹមត្រូវ និងគ្រប់គ្រាន់ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។ ចំពោះអត្រាគោលរបប និងនីតិវិធីចំណាយនេះ ត្រូវបន្តអនុវត្តរហូតដល់មានបទដ្ឋានគតិយុត្តថ្មីមកជំនួស ។

ចំពោះមុខសញ្ញាចំណាយមួយចំនួន ដែលជាចំណាយជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់ ក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានអនុញ្ញាតឱ្យអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន តាមលំនាំរដ្ឋទេយ្យបុរេប្រទាន ដោយអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបេឡាឡើងវិញ ។

ជារួម នីតិវិធីអនុវត្តចំណាយថវិកាត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលត្រូវបានដាក់ចេញ រួមមាន÷

- អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលតម្រូវឱ្យគ្រប់ភ្នាក់ងារប្រតិបត្តិគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមមាតិកាគណនីនៃប្លង់គណនេយ្យថវិកាថ្មី និងប្រភេទចំណាយក្នុងគម្រោង/កម្មវិធីហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ

- ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៧៧០ សហវ.ប្រក ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីចំណាយថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ប្រព័ន្ធធារាសាស្ត្រ
- ប្រកាសលេខ ៦៦៣ សហវ. ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៥៣៣ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីចំណាយថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវថ្នល់ ផ្លូវជនបទ ស្ពាន និងលូ
- ប្រកាសលេខ ១០៨៤ សហវ.អថ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ២០៧ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៩ ស្តីពីនីតិវិធី និងបែបបទនៃការអនុវត្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់)
- ប្រកាសលេខ ១០២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៨៨២ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៧៣២ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៥៤៩ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ៥០៣ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ទិញចំណីសត្វ និងចំណីត្រីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសលេខ ៥៩៤ សហវ.ប្រក ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០២១ ស្តីពីសិទ្ធិអំណាចការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា

- ប្រកាសអន្តរក្រសួងលេខ ៣០២ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល
- ប្រកាសអន្តរក្រសួងលេខ ៧២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីគោលរបប និងនីតិវិធីចំណាយថវិកាសម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ប្រកាសលេខ ១០២ សហវ. ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសអន្តរក្រសួងលេខ ៣៦៦ សហវ. ប្រក ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការអនុវត្តថវិកាសម្រាប់ដំណើរការសាលារៀនសាធារណៈ
- ប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យ រជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាវិនិយោគសាធារណៈ និងជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានអនុវត្តដោយអង្គភាពរដ្ឋ
- សារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីរាជការ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ។

• **ចំណាយផ្សេងទៀត** ដែលត្រូវបានចាត់ទុកថាមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម ហើយដែលមិនស្ថិតក្នុងប្រភេទចំណាយដែលត្រូវបានគូសរំលេចខាងលើ ក្រសួង-ស្ថាប័នត្រូវស្នើសុំធានាចំណាយជាមុន ដោយត្រូវមានការពន្យល់ច្បាស់លាស់អំពីភាពចាំបាច់, អំពីគោលការណ៍អនុញ្ញាត ឬ/និង អំពីឯកសារគាំទ្រផ្សេងៗ ។

### ២.៤.២-ចំណាយដែលតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

មុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តម្រូវឱ្យមានការសុំធានាចំណាយ ដោយក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងត្រូវគោរពឱ្យបាននូវគោលការណ៍សំខាន់ជាសារវន្ត ដូចខាងក្រោម÷

- មុខចំណាយត្រូវស្របតាមផែនការលទ្ធកម្ម ។ ចំពោះចំណាយនេះ បើមិនមានបញ្ចូលក្នុងផែនការលទ្ធកម្មទេ មិនត្រូវបានអនុញ្ញាតឱ្យស្នើសុំ ឬផ្តល់ធានាចំណាយឡើយ លើកលែងតែករណីដែលមានចែងនៅក្នុងសារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន ដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា ។

- ការរៀបចំមុខចំណាយសម្រាប់ផែនការលទ្ធកម្ម ត្រូវស្របតាមស្មារតីនៃការចរចាថវិកា ។

- ក្នុងករណីក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មិនបានផ្ញើផែនការលទ្ធកម្មមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទាន់ពេលវេលាកំណត់នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) ត្រូវផ្អែកលើស្មារតីនៃការចរចាថវិកា និងកំណត់ហេតុប្រជុំ អនុម័តផែនការលទ្ធកម្មជូនតែម្តង ។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងចាត់វិធានការនានា រួមទាំងការដកសិទ្ធិសម្រេចនូវកម្រិតទឹកប្រាក់ក្នុងកិច្ចលទ្ធកម្មសាធារណៈមួយផ្នែក ឬទាំងស្រុងមកវិញ ចំពោះក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាដែលខកខាន ឬយឺតយ៉ាវក្នុងការផ្ញើផែនការលទ្ធកម្ម ។**

- ទន្ទឹមនេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានរៀបចំកែសម្រួលផែនការលទ្ធកម្មបានត្រឹមត្រូវ និងផ្ញើមកទាន់ពេលវេលា ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) តែមិនទទួលបាននូវការអនុម័តទាន់ពេលវេលាមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា ផែនការលទ្ធកម្មនោះត្រូវបានចាត់ទុកថាទទួលបានការអនុម័តដោយស្វ័យប្រវត្តិពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ការផ្តល់ធានាចំណាយ និងការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវតែមានការស្នើសុំជាលាយល័ក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិជាដាច់ខាត ។

- ការស្នើសុំ និងផ្តល់ធានាចំណាយ ទាំងចំណាយចរន្ត និងចំណាយមូលធន/ចំណាយវិនិយោគ ត្រូវអនុវត្តក្នុងវង្ឋឥណទានថវិកាដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងក្នុងក្របខ័ណ្ឌនៃការធ្វើវិចារណកម្មចំណាយជាយថាហេតុរបស់រាជរដ្ឋាភិបាល ។

- ការអនុវត្តចំណាយសម្រាប់ការជួសជុល ក្នុងក្របខ័ណ្ឌចំណាយចរន្ត ក្រសួង-ស្ថាប័នត្រូវរួសរាន់លើកសំណើសុំធានាចំណាយនៅក្នុងត្រីមាសទី ១ ឬយ៉ាងយូរត្រឹមត្រីមាសទី ២ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងធានាឱ្យការទូទាត់អាចអនុវត្តបានទាន់ពេលវេលា លើកលែងតែចំណាយជួសជុលហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលជាកម្មវត្ថុនៃការយោងបន្តទៅការិយបរិច្ឆេទឆ្នាំបន្ទាប់ ។ ទោះជាយ៉ាងនេះក្តី ក្រសួង-ស្ថាប័នក៏ចាំបាច់ត្រូវត្រៀមថវិកាទុកសម្រាប់អនុវត្តការងារជួសជុលតូចតាច ដែលអាចកើតមានជាយថាហេតុ ជាពិសេសការងារដែលមានទឹកប្រាក់ក្រោម ៤០ លានរៀល ឬមុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្ម តាមនីតិវិធីស្ទង់តម្លៃដែលអាចសុំធានាចំណាយនៅក្នុងត្រីមាសទី ៣ នៃឆ្នាំបាន ។ ដោយឡែកចំពោះចំណាយសម្រាប់ការជួលសេវាកម្មលើការសិក្សាស្រាវជ្រាវ ឬពិសោធន៍ ក្រសួង-ស្ថាប័ន ក៏ត្រូវរួសរាន់

លើកសំណើសុំធានាចំណាយនៅក្នុងត្រីមាសទី ១ ឬយ៉ាងយូរត្រឹមត្រីមាសទី ២ នៃឆ្នាំថវិកាផងដែរ ដើម្បីធានាភាពទាន់ពេលវេលានៃការបើកផ្តល់សាច់ប្រាក់ និងការទូទាត់បិទបញ្ជីចំណាយ ។

- ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រង និងអនុវត្តចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ (គម្រោងវិនិយោគផ្ទាល់) ក្រសួងដែលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាពិសេស ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយមត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការពន្លឿនការស្នើសុំគោលការណ៍ធានាចំណាយឱ្យបានចាប់ពីដើមខែមករា នៃឆ្នាំអនុវត្តថវិកា ព្រមទាំងត្រូវជំរុញឱ្យដំណើរការនៃការស្ថាបនា ស្តារ និងជួសជុលផ្លូវ-ថ្នល់ និងប្រព័ន្ធធារាសាស្ត្រប្រព្រឹត្តទៅនៅក្នុងអំឡុងរដូវរាំងភ្លៀង ដែលជាពេលវេលាអំណោយផលសម្រាប់ផ្នែកបច្ចេកទេសនៃការងារសាងសង់ ព្រមទាំងត្រូវគិតគូររៀបចំកិច្ចដំណើរការសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឱ្យបានទាន់ពេលវេលាផងដែរ ។ ជាមួយគ្នានេះ ក្រសួងអាណាប័កក៏ត្រូវសិក្សាគម្រោង ដោយធានាឱ្យមានការឆ្លើយតបទៅភាពធន់នឹងការប្រែប្រួលអាកាសធាតុ ។ ដោយឡែក ក្រសួង-ស្ថាប័នផ្សេងៗទៀត (ក្រៅពីក្រសួងទាំងបីខាងលើ) ដែលទទួលបានថវិកាចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ (គម្រោងវិនិយោគផ្ទាល់) ក៏ត្រូវពន្លឿនការស្នើសុំគោលការណ៍ធានាចំណាយ និងជំរុញការអនុវត្តកិច្ចលទ្ធកម្មឱ្យបានទាន់ពេលវេលា ដើម្បីឆាប់ទទួលបានកិច្ចសន្យាអនុវត្តគម្រោងក្នុងគោលដៅបង្កើនប្រសិទ្ធភាពអនុវត្តគម្រោងឱ្យបានទាន់រដូវកាល និងទទួលបានការទូទាត់ទាន់ពេលវេលាតាមលក្ខខណ្ឌនៃកិច្ចសន្យា ។ លើសពីនេះទៀត, ក្រសួង-ស្ថាប័នដែលទទួលបានថវិកាបុរេប្រទាន (គម្រោងវិនិយោគផ្ទាល់) សម្រាប់ការចាប់ផ្តើមអនុវត្តការងារត្រូវរួសរាន់រៀបចំស្នើសុំទូទាត់ជម្រះថវិកាបុរេប្រទានឱ្យបានទាន់ពេលវេលា ដើម្បីជៀសវាងការកកស្ទះថវិកាបុរេប្រទានមិនបានទូទាត់យូរឆ្នាំ ដែលជាបច្ច័យនាំឱ្យក្លាយទៅជាបុរេប្រទានរ៉ាំរ៉ៃ ។

- មុខចំណាយដែលស្នើសុំ ត្រូវមានឥណទានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្ត ។ ចំពោះការចេញធានាចំណាយដោយគ្មានឥណទានថវិកា គឺមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ ក្នុងន័យនេះ ការស្នើសុំធានាចំណាយត្រូវគិតដល់÷

- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទាន និងចំណាយថវិកាបុរេ-ប្រទាន ដោយរាប់ទាំងចំណាយថវិកាបុរេប្រទានមុនឆ្នាំ ២០២២ ប្រសិនបើមាន
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលបានធានាចំណាយរួច
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលចាំបាច់ខានមិនបាន ដែលអាចកើតមាននាពេលខាងមុខ ។

- ដើម្បីបង្កើនប្រសិទ្ធភាពចំណាយ និងធានាបាននូវភាពទាន់ពេលវេលានៃការអនុវត្តថវិកាកម្មវិធីក្រសួង-ស្ថាប័ន ក៏ដូចជាអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវបានអនុញ្ញាតឱ្យរៀបចំលើកសំណើសុំថវិកាចំណាយជាកញ្ចប់ប្រចាំឆមាស មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្តល់ទិដ្ឋាការធានាចំណាយ ដោយផ្អែកលើ

ភាពច្បាស់លាស់ និងត្រឹមត្រូវនៃសកម្មភាពរបស់កម្មវិធី និងភាពត្រឹមត្រូវនៃផែនការលទ្ធកម្ម ។ លើកលែងតែសកម្មភាពថ្មីមិនមាននៅក្នុងផែនការសកម្មភាពនៃថវិកាកម្មវិធី និងចំណាយដែលមានវេទយិតភាពខ្ពស់ ដែលត្រូវជាកម្មវត្ថុនៃការពិភាក្សា និងផ្តល់ធានាចំណាយដោយឡែកជាករណីពិសេស។ **រាល់សកម្មភាព ដែលបានផ្តល់ធានាចំណាយរួចហើយ ប្រសិនបើក្រសួង-ស្ថាប័នមិនព្រមអនុវត្ត នឹងត្រូវជាកម្មវត្ថុនៃការលុបធានាចំណាយចោលវិញ នៅឆមាសបន្ទាប់ ។**

- ចំពោះមុខចំណាយធំៗ និងសំខាន់ៗ សម្រាប់បម្រើឱ្យសេចក្តីត្រូវការក្នុងការផ្តល់សេវាសាធារណៈ និងកិច្ចដំណើរការរបស់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទនីមួយៗ បែរជាមានការយឺតយ៉ាវ ឬមិនមានការរួសរាន់ស្នើសុំធានាចំណាយឱ្យបានទាន់មុនខែ មិថុនា ឆ្នាំ ២០២២, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបង្កក ឬកាត់ចេញតែម្តងនូវមុខចំណាយទាំងនោះ, ទោះបីមានក្នុងផែនការលទ្ធកម្មហើយក៏ដោយ, លើកលែងតែមុខចំណាយនោះមានភាពចាំបាច់ និងមានការពន្យល់ឱ្យបានច្បាស់លាស់អំពីមូលហេតុ ។

- គម្រោងចំណាយត្រូវមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយត្រូវមានបទដ្ឋានបច្ចេកទេស ឬយថាប្រភេទច្បាស់លាស់ដែលអាចជាមូលដ្ឋានសម្រាប់ការពិនិត្យអំពីភាពសមស្របនៃថ្លៃ, និងអំពីភាពចាំបាច់នៃគម្រោង ឬការងារ ។ ក្នុងការលើកសំណើសុំធានាចំណាយ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ចាំបាច់ត្រូវគិតគូរឱ្យបានស្រេចបាច់អំពីតម្លៃស្របតាមទីផ្សារអំពីបរិមាណ និងគុណភាពនៃទំនិញ និងសំណង់ ដែលត្រូវធ្វើកិច្ចលទ្ធកម្មសាធារណៈ មុននឹងសុំធានាចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់ធានាចំណាយដោយផ្អែកលើភាពសមស្របនៃថ្លៃទីផ្សារធ្វើជាមូលដ្ឋាន ។

- គម្រោងចំណាយត្រូវមានភាពចាំបាច់ ដែលផ្តល់ផលប្រយោជន៍ពិតប្រាកដសម្រាប់ឱ្យក្រសួង-ស្ថាប័នសម្រេចបេសកកម្មការងាររបស់ខ្លួន ដោយចៀសវាងឱ្យបាននូវការបង្កើតចំណាយមិនចាំបាច់ និងខ្ជះខ្ជាយ ។

- ឥណទានថវិកាដែលបានកាត់/សន្សំពីការផ្តល់ធានាចំណាយ និងការអនុវត្តកិច្ចលទ្ធកម្មនៃគម្រោងចំណាយរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ នឹងត្រូវបានបង្កកមិនអនុញ្ញាតឱ្យចំណាយបន្ថែម ឬធ្វើនិយ័តកម្មសម្រាប់បម្រើឱ្យចំណាយផ្សេងទៀតឡើយ វៀរលែងតែមានការពន្យល់ច្បាស់លាស់ពីសេចក្តីត្រូវការចាំបាច់បំផុតប៉ុណ្ណោះ ។

- មិនត្រូវស្នើសុំ និងផ្តល់ធានាចំណាយទៅលើការអនុវត្តនូវសកម្មភាពដែលនាំឱ្យមានការជ្រើសរើសមន្ត្រីថ្មី ឬមន្ត្រីជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្តដោយគ្មានការគ្រោងទុកក្នុងគម្រោងថវិកា ឬគ្មានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ។

- តម្លៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសឥណទានថវិកាដែលបានផ្តល់ធានាចំណាយឡើយ ។ ចំពោះករណីដែលការអនុវត្តនីតិវិធីលទ្ធកម្មលើសពីឥណទានថវិកាដែលបានផ្តល់ពេលធានាចំណាយ ឬមាន

តម្រូវការដូវបរិមាណ ទំហំការងារយថាប្រភេទ ក៏ដូចជាគុណភាព, តាមសំណើរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ, អគ្គនាយកដ្ឋានថវិកា/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម ឬក្រុមលទ្ធកម្ម ត្រូវពិភាក្សាគ្នាដើម្បីរិះរកវិធានការដោះស្រាយប្រកបដោយតម្លាភាព និងស្របតាមនីតិវិធីជាធរមាន ។

នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលបានដាក់ចេញដូចខាងក្រោម÷

- ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- អនុក្រឹត្យលេខ ១៣ អនក្រ. បក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៩ ស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ១៦១៣ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ១៦១៤ សហវ.ប្រក ចុះថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការចុះការជម្រះនិងការផ្សព្វផ្សាយបញ្ជីខ្មៅ
- ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម
- ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីក្រមសីលធម៌លទ្ធកម្ម
- ប្រកាសលេខ ៩៨៨ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ
- ប្រកាសលេខ ២៤៩ សហវ. ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា

- ប្រកាសលេខ ១៨៦៦ សហវ. ប្រក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
- ប្រកាសអន្តរក្រសួងលេខ ៥៦៨ សហវ. ប្រក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់
- ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៩ ស្តីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៩ ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃ និងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាក្នុងកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន ដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា
- សារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០០១ សហវ.អលសា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- សេចក្តីណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩ ស្តីពីនីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ
- សេចក្តីណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់
- សេចក្តីណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម ។

- ដោយឡែក **ចំពោះការអនុវត្តចំណាយសម្រាប់ការទិញរថយន្ត** គឺត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម÷

• ដោយផ្អែកតាមស្មារតីនៃការចរចាថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបូកសរុបរួមនូវតម្រូវការទិញរថយន្តរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត រួមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានគ្រោងក្នុងឥណទានថវិកាឆ្នាំ ២០២២ និងទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល រួចហើយ ។ ដូចនេះ ក្រសួង-ស្ថាប័នមិនត្រូវបានអនុញ្ញាតឱ្យដាក់បញ្ចូលគម្រោងទិញរថយន្តផ្សេងទៀត ក្នុងផែនការលទ្ធកម្មឡើយ ។

• ផ្អែកតាមលទ្ធភាពឥណទានថវិកា និងតម្រូវការប្រើប្រាស់រថយន្តទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យក្រសួង-ស្ថាប័នមួយចំនួនលើកសំណើសុំទិញរថយន្តត្រឹមកម្រិតស្តង់ដារ (Standard Option) សម្រាប់ទាំងរថយន្ត Van និងទាំងរថយន្ត Pick-UP ។

• ក្រសួង-ស្ថាប័ន ត្រូវស្នើសុំគោលការណ៍ធានាចំណាយសម្រាប់ទិញរថយន្ត ដោយផ្អែកតាមចំនួនរថយន្តដែលទទួលបានគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល និងមានភ្ជាប់ជាមួយនូវបញ្ជីប៉ាន់តម្លៃ និង យថាប្រភេទលម្អិតនៃរថយន្ត (Quotation and Technical Specification) ជាផ្លូវការពីក្រុមហ៊ុនផ្គត់ផ្គង់រថយន្តដែលបានទទួលសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ដោយត្រូវគិតបញ្ចូលពន្ធ និងអាករផ្សេងៗគ្រប់ប្រភេទ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យផ្តល់ធានាចំណាយ ព្រមជាមួយនឹងការផ្តល់ប្រាក់បុរេប្រទានជូនក្រសួង-ស្ថាប័នចំនួន ៤០% នៃទឹកប្រាក់ដែលផ្តល់ធានាចំណាយសម្រាប់កក់នៅពេលចុះកិច្ចសន្យា ។ ការទូទាត់បង្គ្រប់ត្រូវធ្វើឡើងបន្ទាប់ពីរថយន្តត្រូវបានប្រគល់ទទួលត្រឹមត្រូវតាមកិច្ចសន្យា ។ បន្ទាប់មក ក្រសួង-ស្ថាប័នត្រូវបោះផ្សាយអាណត្តិនិយ័តកម្មស្មើទឹកប្រាក់ដែលបានបុរេប្រទាន និងអាណត្តិបើកប្រាក់ទូទាត់បង្គ្រប់តាមកិច្ចសន្យា ដោយភ្ជាប់ជាមួយនូវឯកសារលិខិតយុត្តិការគ្រប់គ្រាន់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

• អនុញ្ញាតឱ្យអង្គភាពលទ្ធកម្មរបស់ក្រសួង-ស្ថាប័ន និងក្រុមលទ្ធកម្មនៃអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ, ដោយមិនមានកម្រិតទឹកប្រាក់, អនុវត្តវិធីសាស្ត្រចុះកិច្ចសន្យាផ្ទាល់ទិញរថយន្តជាមួយក្រុមហ៊ុនផ្គត់ផ្គង់រថយន្តណាដែលបានទទួលសិទ្ធិនាំចូលផ្តាច់មុខតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនកណ្តាលឡើយ ។ ក្រសួង-ស្ថាប័ន ត្រូវអនុវត្តនីតិវិធីបន្តឱ្យបានសមស្របតាមគោលការណ៍លទ្ធកម្មសាធារណៈជាធរមាន ។

**២.៤.៣- ការប្រគល់ទទួល(ទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា)**

ការប្រគល់ទទួលទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា គឺជាដំណាក់កាលបន្ទាប់ពីក្រសួង-ស្ថាប័ន បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងឯកសារគតិយុត្ត និងលិខិតបទដ្ឋានពាក់ព័ន្ធ ។ ការប្រគល់ទទួល គឺពិនិត្យមើលពីភាពត្រឹមត្រូវ ទាំងមុខទំនិញ ឯកតា បរិមាណ តម្លៃ ប្រភព និងគុណភាព ព្រមទាំងផ្ទៀងផ្ទាត់មិនឱ្យលើសពីទឹកប្រាក់នៃការធានាចំណាយ និង

មិនឱ្យខុសពីបទដ្ឋានបច្ចេកទេស និងយថាប្រភេទដែលបានជានាទចំណាយ និងចុះកិច្ចសន្យាឡើយ ។ ដូចនេះ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រដ្ឋ មិនត្រូវបានអនុញ្ញាតឱ្យទទួលយក ទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាជាដាច់ខាត ប្រសិនបើមិនមានកិច្ចសន្យា ឬប្រសិនបើទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សាមិនត្រូវបានអនុវត្តបានគ្រប់ចំនួន និងត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាទេ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននិត្យានុកូលភាពគ្រប់គ្រាន់ក្នុងការមិនទូទាត់ចំពោះករណីបែបនេះ ហើយក្រសួង-ស្ថាប័នដែលអនុវត្តខុសត្រូវទទួលខុសត្រូវលើភាពមិនប្រក្រតី តាមបទប្បញ្ញត្តិជាធរមាន ។

**២.៤.៤- ការបើកប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ**

បន្តអនុវត្ត និងពង្រីកនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) រួមទាំងការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមប្រព័ន្ធធនាគារតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។ ដូច្នេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលា ដើម្បីធានាប្រសិទ្ធភាពនៃការបើកផ្តល់បៀវត្ស ឱ្យបានទៀងទាត់រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ។ ចំពោះ ក្រសួង-ស្ថាប័នមួយចំនួនទៀត ដែលមិនទាន់អនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារបានពេញលេញនៅឡើយ ត្រូវពិនិត្យលទ្ធភាពក្នុងការពង្រីកការអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារនៅឆ្នាំ ២០២២ នេះ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬទាក់ទងផ្ទាល់ជាមួយគណៈកម្មការចម្រុះ ទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ ។

ដើម្បីធានាការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀតឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់នូវសារាចរលេខ ០៧ សរ, ចុះថ្ងៃពុធ ៥ កើត ខែមិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត របស់រាជរដ្ឋាភិបាល ។

ចំពោះចំនួនក្របខ័ណ្ឌ និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវតែពិនិត្យ និងអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលចេញដោយក្រសួងមុខងារសាធារណៈ និងរាល់ក្របខ័ណ្ឌគតិយុត្តដែលនៅមានជាធរមាន ជាពិសេសអនុក្រឹត្យ សារាចរណែនាំ និងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា, ការត្រួតពិនិត្យឡើងវិញនូវចំនួន និងការគ្រប់គ្រងមន្ត្រីរាជការ, និងការកែសម្រួលប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជាដើម ។

ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំអនុវត្តថវិកា ក្រសួង-ស្ថាប័នដើម ត្រូវតែធានាថា មន្ត្រីរាជការដែលទទួលបានការអនុញ្ញាតឱ្យផ្ទេរនេះ នៅបន្តទទួលបើកប្រាក់បៀវត្សនៅក្នុងក្របខ័ណ្ឌនៃក្រសួង-ស្ថាប័នដើម រហូតដល់ដំណាច់ឆ្នាំ ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័នដែលអនុញ្ញាតឱ្យមន្ត្រីរាជការរូបនោះផ្ទេរចូល មិនត្រូវបានអនុញ្ញាតឱ្យស្នើសុំបន្ថែមឥណទានថវិកាសម្រាប់បើកបៀវត្សជូនមន្ត្រីរាជការដែលផ្ទេរចូលនៅក្នុងឆ្នាំអនុវត្តថវិកានោះទេ ប៉ុន្តែមានកាតព្វកិច្ចត្រូវគ្រោងប្រាក់បៀវត្សរបស់មន្ត្រីរាជការផ្ទេរចូល ឱ្យបានទាន់ពេលវេលានៃការរៀបចំថវិកាឆ្នាំបន្ទាប់ ។ ម្យ៉ាងទៀត ក្នុងករណីមានសំណើសុំផ្ទេរមន្ត្រីក្របខ័ណ្ឌពីមន្ទីរជំនាញរាជធានី-ខេត្ត មករដ្ឋបាលកណ្តាលនៃក្រសួង-ស្ថាប័ន, គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវលើកសំណើទៅក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាអំពីមុខងារដែលនាំឱ្យមានតម្រូវការផ្ទេរបុគ្គលិកពីមន្ទីរជំនាញរាជធានី-ខេត្តមករដ្ឋបាលកណ្តាលនៃក្រសួង-ស្ថាប័នក្នុងគោលដៅជួយដោះស្រាយបញ្ហាខ្វះខាតមន្ត្រីរាជការនៅផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗនោះ ។

### ២.៤.៥-ការផ្ទេរចលនាឥណទានថវិកា

ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួនតាមប្រកាសស្តីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានលម្អិតនៅក្នុងសៀវភៅថវិកា ។ ការផ្ទេរចលនាឥណទានថវិកា ត្រូវបានអនុញ្ញាតនៅដើមត្រីមាសទី ២ ក្រោយពីការអនុវត្តត្រីមាសមុនចប់សព្វគ្រប់ ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានថវិកាមិនគ្រប់គ្រាន់ តែចាំបាច់ត្រូវចំណាយ ការធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវពន្យល់ឱ្យបានច្បាស់លាស់អំពីមូលហេតុ ជាពិសេសអំពីភាពចាំបាច់នៃការងារ និងអំពីភាពសល់ទំនេរនៃឥណទានថវិកា ដែលត្រូវផ្ទេរចេញបន្ទាប់ពីបណ្តាសកម្មភាពដែលបានគ្រោងត្រូវបានអនុវត្តរួច ។ ប៉ុន្តែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្នើឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវគោរពឱ្យបាននូវមុខសញ្ញាឥណទានថវិកាដែលសំខាន់សម្រាប់សកម្មភាពគន្លឹះ ដែលបម្រើឱ្យគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមី ក្នុងករណីពិនិត្យឃើញថា មិនបានគោរពនូវគោលការណ៍ខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមិនអនុញ្ញាតឱ្យមានការផ្ទេរចលនាឥណទានឡើយ ។

ដូចនេះ រាល់សំណើសុំនិយ័តភាពត្រូវធ្វើស្របតាមគោលការណ៍ស្តីពីការផ្ទេរចលនាឥណទានថវិកា ដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ។ ជាមួយគ្នានេះ *ក្រសួង-ស្ថាប័ន ទាំងរដ្ឋបាលកណ្តាល ទាំងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ចាំបាច់ត្រូវកត់សម្គាល់ផងដែរថា គោលការណ៍ណែនាំនេះ មានចែងអំពីការផ្ទេរប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មនៃថវិកាកម្មវិធី ព្រមជាមួយនឹងការកំណត់នូវអនុគណនីចំណាយមួយចំនួន ដែលមិនត្រូវបានផ្តល់ប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មទេ រួមទាំងមុខចំណាយលើការប្រើប្រាស់អគ្គិសនី ទឹក សោហ៊ុយប្រៃសណីយ៍ ទូរគមនាគមន៍ សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងប្រាក់បំណាច់ម៉ោងបន្ថែម ហើយតម្រូវឱ្យស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច ។*

## ២.៤.៦- គោលការណ៍បន្ថែមសម្រាប់ការអនុវត្តចំណាយមិនមែនបន្ទុកបុគ្គលិក

ដើម្បីបង្កើនប្រសិទ្ធភាពចំណាយកម្រិតបច្ចេកទេស និង កម្រិតប្រតិបត្តិការ ជាពិសេស ដើម្បីសន្សំសំចៃចំណាយ ក្នុងបរិការណ៍នៃការបើកប្រទេសឡើងវិញលើគ្រប់វិស័យជាបន្តបន្ទាប់ ចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២១ តាមគន្លងប្រក្រតីថ្មីនៃការរៀនរស់នៅជាមួយនឹងជំងឺកូវីដ-១៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំបន្ថែមដោយឡែក មួយចំនួនដូចខាងក្រោម÷

**(ក)- ចំណាយលើការរៀបចំ ពិធីបុណ្យ វគ្គបណ្តុះបណ្តាល, សន្និបាត, សន្និសីទ, សិក្ខាសាលា, ពិព័រណ៍ និងកិច្ចប្រជុំកម្រិតជាតិ និងកម្រិតអន្តរជាតិគ្រប់ប្រភេទ**

ក្នុងស្មារតីនៃការបង្កើនការសន្សំសំចៃខ្ពស់ មិនខ្ជះខ្ជាយថវិកាជាតិ គ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំតែពិធី/ព្រឹត្តិការណ៍ ដែលជាកាតព្វកិច្ចហើយខានមិនបាន និងជាសកម្មភាពចាំបាច់ដែលផ្តល់ផលចំណេញដល់ប្រទេសជាតិ ។ ពិធី/ព្រឹត្តិការណ៍ទាំងនោះ ត្រូវអនុលោម និងអនុវត្តតាមគោលការណ៍សំខាន់ៗ រួមមាន÷

- ✓ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវចំណុច ៣.៧ នៃសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ១១៨៧ សជណ.សរ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨ លើការរៀបចំពិធីជប់លៀង, ការទិញវត្ថុអនុស្សាវរីយ៍ និងការទិញសម្ភារៈផ្សេងៗបម្រើក្នុងពិធី គឺត្រូវមានលក្ខណៈសន្សំសំចៃខ្ពស់បំផុត,
- ✓ ការរៀបចំពិធីបុណ្យ, សន្និបាត, សន្និសីទ, សិក្ខាសាលាដែលមានទ្រង់ទ្រាយធំ, ពិព័រណ៍ និងកិច្ចប្រជុំក្នុងប្រទេសកម្រិតជាតិគ្រប់ប្រភេទ និងកម្រិតអន្តរជាតិកម្រិតអាស៊ាន តំបន់ និងពិភពលោក ចាំបាច់ត្រូវមានផែនការច្បាស់លាស់ និងត្រូវមានគ្រោងនៅក្នុងផែនការថវិកា ស្របតាមស្មារតីនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន,
- ✓ **ត្រូវអនុវត្តចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិ ត្រឹមកម្រិតឥណទានថវិកាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** និងត្រូវទូទាត់ជម្រះចំណាយឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗ ដោយមិនអនុញ្ញាតឱ្យយោងទៅទូទាត់ និងប្រើឥណទានថវិកាឆ្នាំបន្ទាប់ឡើយ ព្រមទាំងត្រូវជានាការចូលរួមរបស់មន្ត្រី ក្នុងចំនួនចាំបាច់ និងតិចបំផុត ក្នុងការទ្រទ្រង់ដំណើរការរៀបចំ ។ ក្នុងករណីមានត្រូវការចាំបាច់ ជាក់ស្តែងក្នុងការអនុវត្តសកម្មភាពបន្ថែមដែលនាំឱ្យមានចំណាយកើនឡើង ត្រូវលៃលកប្រើប្រាស់ឥណទានថវិកាផ្ទៃក្នុងដែលមានក្នុងឆ្នាំអនុវត្តថវិកា,
- ✓ ជ្រើសរើសការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិ នៅទីតាំងដែលនៅជិតបំផុត ដើម្បីកាត់បន្ថយចំណាយដែលមិនចាំបាច់ ជាពិសេសចំណាយលើសោហ៊ុយបេសកកម្ម,

- ✓ កាត់បន្ថយចំណាយ និងសកម្មភាពដែលមានលក្ខណៈប្រមូលផ្តុំអ្នកចូលរួមមិនអាចបំពេញបាន តាមវិធានសុខាភិបាល ដូចជា ពិធីជប់លៀង ឬបដិសណ្ឋារកិច្ច ជាដើម,
- ✓ ត្រូវចៀសវាងអនុវត្តសកម្មភាពដោយមិនមានស្នើសុំគោលការណ៍ចំណាយជាមុន ដែលនាំឱ្យមិនមានឥណទានថវិកាគ្រប់គ្រាន់សម្រាប់ទូទាត់ ។ ក្នុងករណីមិនអនុលោមតាមគោលការណ៍កំណត់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននិត្យានុកូលភាពគ្រប់គ្រាន់ ក្នុងការមិនពិនិត្យទូទាត់ថវិកាជូនក្រសួង-ស្ថាប័ន ចំពោះសំណើពាក់ព័ន្ធនឹងការងារនេះឡើយ ។ ការរៀបចំពិធី/ព្រឹត្តិការណ៍នានាជាលក្ខណៈអន្តរជាតិ រួមទាំងការទទួលភ្ញៀវអន្តរជាតិផង ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍បដិការ ប៉ុន្តែត្រូវស្របតាមលទ្ធភាពនៃថវិការបស់ជាតិផងដែរ,
- ✓ បន្តស្មារតីសន្សំសំចៃខ្ពស់ និងបង្កើនប្រសិទ្ធភាពចំណាយថវិកាជាតិ ដោយពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តតាមប្រព័ន្ធនិម្មិត (Online) ។ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ទាំងនៅរដ្ឋបាលថ្នាក់ជាតិ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាចរៀបចំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិដោយផ្ទាល់ ក្នុងករណីដែលមានតម្រូវការក្នុងការ-ពិភាក្សាគ្នាល្អិតល្អន់ដើម្បីឈានដល់ការសម្រេចចិត្តណាមួយ ឬពាក់ព័ន្ធនឹងការបណ្តុះបណ្តាលដែលទាមទារឱ្យមានការបង្ហាញជូនសិក្ខាកាមដោយផ្ទាល់,
- ✓ មុខសញ្ញាចំណាយមួយចំនួនដែលមិនមានតម្រូវការចាំបាច់ ជាអាទិ៍ ការបោះពុម្ពឯកសារ សម្ភារៈ ការជួលទីតាំង ការរៀបចំកន្លែង អាហារជប់លៀង បដិសណ្ឋារកិច្ច វត្ថុអនុស្សាវរីយ៍ និង ចំណាយផ្សេងៗ មិនត្រូវបានអនុញ្ញាតឱ្យលើកគម្រោងចំណាយ តាមគោលការណ៍នៃប្រកាស លេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយ សម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងអន្តរជាតិទាំងស្រុងឡើយ លើកលែង តែចំណាយរបស់ក្រុមការងារ ឬលេខាធិការដ្ឋានដឹកនាំកិច្ចប្រជុំផ្ទាល់ដែលតម្រូវឱ្យមានចំណាយទាំងនេះ ។

**(ខ)- ប្រាក់បេសកកម្មក្រៅប្រទេស**

កន្លងមកនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើនប្រាក់បេសកកម្មក្រៅប្រទេសជូនដល់មន្ត្រីរាជការ ដើម្បីធានាបាននូវការសន្សំសំចៃខ្ពស់បំផុត ដោយចៀសវាងឱ្យបាននូវការចំណាយលើបេសកកម្មក្រៅប្រទេស ដែលមិនរួមចំណែកដល់ការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំដល់គ្រប់ក្រសួង-ស្ថាប័នធ្វើអាទិភាវូបនីយកម្មបេសកកម្មក្រៅប្រទេស ដោយពិនិត្យឡើងវិញអំពីភាពចាំបាច់/សារប្រយោជន៍ ឬផលប្រយោជន៍ដែលកម្ពុជាទទួលបានពីការចូលរួមនោះ ក្នុងការសម្រេចគោលដៅអាទិភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ចំនួនដងនៃបេសកកម្ម និងទំហំនៃគណៈប្រតិភូឱ្យនៅចំនួនអប្បបរមា និងពាក់ព័ន្ធជាចាំបាច់ ។ ក្រសួង-ស្ថាប័នត្រូវប្រកាន់ ស្មារតីហ៊ានបដិសេធនូវការអញ្ជើញ

បេសកកម្មក្រៅប្រទេសទាំងឡាយណា ដែលផ្តល់ប្រយោជន៍តិចតួច ឬមិនសូវមានប្រយោជន៍ ឬមិនមានប្រយោជន៍ដល់ក្រសួង-ស្ថាប័ន ហើយដែលយើងត្រូវចេញសោហ៊ុយខ្លួនឯង ។ **ក្រសួង-ស្ថាប័នត្រូវបំពេញបេសកកម្មក្រៅប្រទេស ដោយផ្អែកជាចាំបាច់លើភាពទំនេរនៃឥណទានថវិកាជាមុនរបស់ក្រសួង-ស្ថាប័ន និងមិនមែនជាកម្មវត្ថុនៃការស្នើសុំឥណទានបន្ថែម ឬផ្ទេរចលនាឥណទានថវិកានោះទេ** ។ ក្នុងន័យនេះ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមគូសបញ្ជាក់ថា ចំណាយបេសកកម្មក្រៅប្រទេសត្រូវធ្វើឡើងតែក្នុងឥណទានថវិកាដែលបានវិភាជប្រចាំឆ្នាំ** មានផែនការច្បាស់លាស់ជាមុន និងត្រូវមានប្រព័ន្ធរបាយការណ៍ដែលបង្ហាញពីសារប្រយោជន៍នៃបេសកកម្មទាំងនោះ ។ ជារួម, ក្រសួង-ស្ថាប័ន ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ តាម**សារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៦ សរណន ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីគោលការណ៍អនុវត្តចំណាយលើសោហ៊ុយបេសកកម្មក្រៅប្រទេស** ដែលមានខ្លឹមសារ ដូចខាងក្រោម÷

- ✓ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តចំណាយបេសកកម្មនៅក្រៅប្រទេស ត្រឹមកម្រិតឥណទានអតិបរមាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវទូទាត់ឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗ ហើយមិនត្រូវអនុវត្តចំណាយបេសកកម្មនៅទៅក្រៅប្រទេស ដោយមិនមានឥណទានថវិកាសម្រាប់ទូទាត់នោះទេ ។
- ✓ បន្តស្មារតីសន្សំសំចៃខ្ពស់លើចំណាយថវិកាជាតិ ដោយពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តតាមប្រព័ន្ធនិម្មិត ឬប្រើប្រាស់មន្ត្រីនៅប្រចាំប្រទេសនោះ ដើម្បីចូលរួមជំនួស ។ ការចុះបេសកកម្មទៅក្រៅប្រទេសតែក្នុងករណីចាំបាច់ដែលមិនអាចអនុវត្តតាមប្រព័ន្ធនិម្មិតបាន ឬមិនអាចប្រើប្រាស់មន្ត្រីនៅប្រចាំប្រទេសនោះដើម្បីចូលរួមជំនួសបាន ។
- ✓ មិនអនុញ្ញាតឱ្យអនុវត្តចំណាយមុន លើចំណាយបេសកកម្មទៅក្រៅប្រទេស ដោយមិនមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និង/ឬពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។ ក្នុងករណីនៅតែបន្តមានក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលខុសត្រូវក្នុងការដោះស្រាយចំណាយនេះដោយផ្ទាល់ក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់ខ្លួន ។
- ✓ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវណែនាំដល់ប្រធានអង្គភាព និងមន្ត្រីក្រោមឱវាទ ឱ្យចាត់វិធានការរឹតបន្តឹងការគ្រប់គ្រងចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេសឱ្យបានម៉ឺងម៉ាត់ និងក្នុងស្មារតីសន្សំសំចៃខ្ពស់ ។

**(គ)- ប្រាក់បេសកកម្មក្នុងប្រទេស**

ដូចគ្នាដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើនប្រាក់បេសកកម្មក្នុងប្រទេសជូនដល់មន្ត្រីរាជការដើម្បីធានាភាពថ្លៃថ្នូរ និងការអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ថែមទៀត នៅក្នុងអំឡុងពេលបំពេញបេសកកម្ម តាមបណ្តារាជធានី-ខេត្ត ទូទាំងប្រទេស ។ ក្នុងន័យនេះ **ក្រសួង-ស្ថាប័ន និងអង្គភាពចំណាយ**

ពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តចំណាយត្រឹមកម្រិតឥណទានដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងអនុវត្តប្រកបដោយតម្លាភាពនូវចំនួនថ្ងៃ និងចំនួនមន្ត្រីចុះបេសកកម្មពិតប្រាកដ ត្រូវលុបបំបាត់ឱ្យបាននូវការបំប៉ោងចំនួនថ្ងៃ និងចំនួនមន្ត្រីចុះបេសសកកម្ម លើសពីការអនុវត្តជាក់ស្តែង ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវការរៀបចំកម្មវិធីនៅតាមរាជធានី-ខេត្ត ដើម្បីគោលដៅទទួលបានប្រាក់បេសកកម្ម ឬក៏យកបេសកកម្ម ធ្វើជាត្រីមុខ ។

ស្របតាមសារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការទូទាត់ត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការ គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវបើកផ្តល់ប្រាក់បេសកកម្មជូនដល់មន្ត្រីរាជការដែលមានភារកិច្ចបំពេញបេសកកម្មការងារ ទាំងនៅក្នុងប្រទេស និងទៅក្រៅប្រទេស ដោយបង្វែរត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការផ្ទាល់តែម្តង ដោយមិនអនុញ្ញាតឱ្យបើកជាសាច់ប្រាក់ផ្ទាល់នោះឡើយ ។

**(ឃ)- ចំណាយទិញឧបករណ៍ និងសម្ភារៈថែទាំសុខភាព**

ចំណាយសម្រាប់ទិញឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ និងសម្ភារការពារពាក់ព័ន្ធមួយចំនួនទៀត បម្រើដល់ការការពារសុខភាព, ថែរក្សាអនាម័យ និងកម្ចាត់មេរោគ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងក្នុងអនុគណនី ៦០០៧៨ (សម្ភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ) និងត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ១០០% លើកលែងតែ មន្ទីរពេទ្យ និងមណ្ឌលសុខភាព ដែលមាននីតិវិធីអនុវត្តដោយឡែក ។

## ២.៥-ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឆ្នាំ ២០២២ គឺជាឆ្នាំទី ៧ នៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ដំណាក់កាលទី ៣ ។ ប្រព័ន្ធនេះ ត្រូវបានរៀបចំដោយអនុលោមទៅតាមស្តង់ដារឧត្តមានុវត្តន៍ទាំងមូលដ្ឋានគណនេយ្យ ទាំងប្រតិបត្តិការហិរញ្ញវត្ថុ ។ នៅក្នុងដំណាក់កាលអនុវត្តថវិកាប្រតិបត្តិការ ចំណូល-ចំណាយថវិកាជាតិ រួមទាំងការទូទាត់ទាំងអស់ត្រូវធ្វើឡើងតាម FMIS ដោយមានការកត់ត្រា, តាមដាន, និងគ្រប់គ្រងដោយស្វ័យប្រវត្តិ ។ ដូចនេះ ដើម្បីឱ្យការទូទាត់ចំណូល-ចំណាយថវិកាជាតិ អាចធ្វើទៅបានចាំបាច់ត្រូវមានឥណទានថវិកានៅក្នុងប្រព័ន្ធ ហើយទន្ទឹមនេះ រាល់ប្រតិបត្តិការចលនាឥណទានថវិកា (ទាំងការផ្ទេរ និងការបន្ថែមឥណទានថវិកា) ដែលធ្វើឡើងនៅគ្រប់អង្គភាពអនុវត្តថវិកាទាំងអស់ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ ។

ក្នុងគោលដៅខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការណែនាំដោយឡែកបន្ថែមទៀត អំពីនីតិវិធី និងតម្រូវការពាក់ព័ន្ធផ្សេងៗ ដើម្បីស្នើសុំកិច្ចសហប្រតិបត្តិការ និងកិច្ចសហការពីគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ។

# ៣. ការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការធ្វើរបាយការណ៍

គ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងសមត្ថភាព និងតួនាទីរបស់អគ្គនាយកដ្ឋានសវនកម្ម/នាយកដ្ឋានសវនកម្មផ្ទៃក្នុង/អគ្គាធិការដ្ឋានរបស់ខ្លួន ជាមួយគ្នានឹងការពង្រឹងសមត្ថភាព និងតួនាទីរបស់អគ្គាធិការដ្ឋាននៃក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការត្រួតពិនិត្យការអនុវត្តថវិកាជាតិ ជាពិសេសការត្រួតពិនិត្យជាក់ស្តែងរាល់ការប្រមូលចំណូល និងការអនុវត្តចំណាយថវិកាជាតិ ដោយវាយតម្លៃនូវការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ/របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំតាមបណ្តាក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរ-ជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ដើម្បីរួមចំណែកទប់ស្កាត់កំហុសឆ្គង និងពង្រឹងអភិបាលកិច្ចក្នុងការគ្រប់គ្រង និងការអនុវត្តហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាដើម្បីបង្កើននូវប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

ដើម្បីបង្កើនគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេសដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ឱ្យបានទៀងទាត់ទៅតាមគំរូដែលបានផ្ញើជូន និងទៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

- **របាយការណ៍ហិរញ្ញវត្ថុ**
  - របាយការណ៍ប្រចាំខែ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់* ។
  - របាយការណ៍ប្រចាំត្រីមាស *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែទៅដើមត្រីមាសបន្ទាប់* ។
  - របាយការណ៍ឆមាសទី ១ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី ២ នៃខែ កក្កដា* ។
  - របាយការណ៍ប្រចាំឆ្នាំបឋម *ត្រូវផ្ញើយ៉ាងយឺតបំផុតត្រឹម ខែ មករា ឆ្នាំ ២០២៣ មកអគ្គនាយកដ្ឋានថវិកា និងត្រូវផ្ញើរបាយការណ៍សម្រេចចុងក្រោយមកអគ្គនាយកដ្ឋានរតនាគារជាតិយ៉ាងយឺតបំផុតត្រឹមខែ មីនា ឆ្នាំ ២០២៣* ។

- **របាយការណ៍សមិទ្ធកម្ម**

ដើម្បីជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុប និងតាមដានការអនុវត្តថវិកាកម្មវិធី និងធ្វើរបាយការណ៍បូកសរុបអំពីសមិទ្ធកម្ម, គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ដែលអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំទាំងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម ទៅតាមគំរូ និងកាលបរិច្ឆេទ ដូចមានចែងក្នុង **គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី** ។ ផ្អែកតាមប្រកាសលេខ ៥៥៤ សហវ. ប្រក ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា របាយការណ៍សមិទ្ធកម្មត្រូវធ្វើឡើងតាមការិយបរិច្ឆេទថ្មី ដូចខាងក្រោម៖

- ផ្តល់តារាងសូចនាករលទ្ធផលក្នុងឆ្នាំ ឬធាតុចេញ (Output) និងលទ្ធផលចុងក្រោយ (Outcome) ដែលគ្រោងនឹងសម្រេចឱ្យបាននៅឆ្នាំ ២០២២ (តាមទម្រង់ដែលបានកំណត់) ស្របទៅតាម

កញ្ចប់ថវិកាដែលបានវិភាជ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនិងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា) *ឱ្យបានមុនដំណាច់ខែ មករា ឆ្នាំ ២០២២*

- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស (តាមទម្រង់ដែលមានភ្ជាប់) កម្រិតចង្កោមសកម្មភាព និង/ឬ កម្រិតអនុកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនិងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា) *យ៉ាងយូរបំផុត ២០ ថ្ងៃ បន្ទាប់ពីបញ្ចប់ការអនុវត្តនៃឆមាសទី ១*
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ (តាមទម្រង់ដែលមានភ្ជាប់) ពីកម្រិតចង្កោមសកម្មភាពដល់កម្រិតកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនិងនាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា, និងអគ្គនាយកដ្ឋានរតនាគារជាតិ) *យ៉ាងយូរបំផុតត្រឹមខែ មីនា នៃឆ្នាំបន្ទាប់ គឺឆ្នាំ ២០២៣* ។

ទន្ទឹមនេះ ផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុ/របាយការណ៍សមិទ្ធកម្មអនុវត្តខាងលើ ដើម្បីបង្កើនប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើអធិការកិច្ចហិរញ្ញវត្ថុជាក់ស្តែង តាមការចាំបាច់លើការអនុវត្តថវិកាកម្មវិធីរបស់គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញ រាជធានី-ខេត្តក្រោមឱវាទទាំងអស់ ។

## ៤. នីតិវិធីនៃការគ្រប់គ្រង និងអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលបំណងធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងភាពឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។ ផ្អែកតាមខ្លឹមសារនៃលិខិតលេខ ២៣៩៨ សហវ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុវត្តតាមក្របខ័ណ្ឌគតិយុត្តថ្មី និងតាមនីតិវិធីហិរញ្ញវត្ថុថ្មីជាធរមាន ។ នីតិវិធីគ្រប់គ្រង និងអនុវត្តថវិកា ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្ត ដែលបានដាក់ចេញដូចខាងក្រោម÷

- ព្រះរាជក្រឹត្យលេខនស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យ លេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- អនុក្រឹត្យលេខ ០១៥ អនក្រ. បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- ប្រកាសលេខ ០១៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៨ ស្តីពីការដាក់ឱ្យអនុវត្ត គោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរជ្ជទេយ្យបុរេប្រទាន និង គណនេយ្យរជ្ជទេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និង
- លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត ដែលនឹងត្រូវដាក់ឱ្យអនុវត្តសម្រាប់បម្រើកិច្ចដំណើរការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ។

ទន្ទឹមនេះ ដើម្បីបង្កើនប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ ការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវត្រួតពិនិត្យ វាយតម្លៃដោយសវនកម្ម/អធិការកិច្ចផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័នសាមី និងធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាំបាច់ ។

## ៥. វិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវពង្រឹងតាមវិធានការដូចខាងក្រោម÷

- ជំរុញរៀបចំកម្មវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីដាក់ឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋប្រើប្រាស់ក្នុងឆ្នាំ ២០២១

- ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់និងលិខិតបទដ្ឋានទាំងឡាយ ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងនីតិបុគ្គលសាធារណៈ ត្រូវទទួលខុសត្រូវរៀបចំតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០២១ ឱ្យបានតាមពេលកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចឱ្យបានតាមការកំណត់ក្នុងការរៀបចំតារាងប្រៀបធៀបកើនឡើង និង ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០២១ នៅថ្នាក់ក្រោមជាតិ ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិ ចូលក្នុងបញ្ជីសារពើភ័ណ្ឌ

- បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយសវនកម្ម/អធិការកិច្ចផ្ទៃក្នុងរបស់ខ្លួនតាមការចាំបាច់

-បន្តពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការគ្រប់គ្រង ការប្រើប្រាស់ និងកាចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋក្រោមឱវាទ តាមការចាំបាច់ ។

## ៦. វិធានការរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា

ក្នុងករណីដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសម្រេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នត្រូវមានវិធានការដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងសហការជាមួយក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា ដើម្បីបន្តបង្កើនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីខាងក្រៅ និងរក្សាឱ្យបានស្ថិរភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅកម្ពុជា,

- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តថវិកា និងសកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងអនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងត្រៀមវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដោយចៀសវាងប៉ះពាល់ដល់សកម្មភាពអាទិភាពខ្ពស់ ក្នុងករណីមានការតម្រឹមចំណាយជាយថាហេតុ,

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យ លើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតម្រូវក្នុងករណីចាំបាច់ ។

## ៧. វិធានការលើកកម្ពស់តម្លាភាពនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

ក្នុងការលើកកម្ពស់តម្លាភាពនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរៀបចំបង្ហោះនៅលើគេហទំព័រនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវឯកសារពាក់ព័ន្ធនឹងច្បាប់ថវិកាឆ្នាំ ២០២២ រួមទាំងការរៀបចំឯកសារថវិកាសង្ខេប (Budget In Brief) និងតារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែ ដើម្បីផ្តល់ជាព័ត៌មានដល់សាធារណជនទូទៅ ឱ្យបានយល់អំពីគោលដៅនៃការប្រើប្រាស់ថវិកាឆ្នាំ ២០២២ ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវផ្សព្វផ្សាយនៅលើគេហទំព័ររបស់ខ្លួនផងដែរនូវរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន រួមមាន÷ គោលបំណងគោលនយោបាយ និងកម្មវិធីដែលក្រសួងបានដាក់អនុវត្ត និងការបែងចែកថវិកាទៅតាមរចនាសម្ព័ន្ធកម្មវិធី តាមគំរូតារាងជូនភ្ជាប់ ។

## ៨. ទណ្ឌកម្មនិងការទទួលខុសត្រូវចំពោះមន្ត្រីសាធារណៈ

មន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវការអនុវត្តអភិបាលកិច្ចល្អឱ្យមានប្រសិទ្ធភាពខ្ពស់ តាមវិធានការច្បាប់ និងលិខិតបទដ្ឋានជាធរមានដូចខាងក្រោម÷

- ចាត់វិធានការរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈណាដែលបានប្រព្រឹត្តនូវកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទទួលទោសតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងទទួលតាមកម្រិតទោសទណ្ឌនៃក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិព្រហ្មទណ្ឌ,

- គ្រប់មន្ត្រីសាធារណៈត្រូវហ៊ានទទួលខុសត្រូវនូវកំហុសឆ្គងដែលបានប្រព្រឹត្ត និងកំពុងអនុវត្តប្រតិបត្តិការលើការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ ទៅតាមបទដ្ឋានគតិយុត្ត នៃវិន័យហិរញ្ញវត្ថុសាធារណៈ សារាចរប្រកាស អនុក្រឹត្យ ដែលបានណែនាំដោយរាជរដ្ឋាភិបាល,

- ចាត់វិធានការតាមវិន័យរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈ ក្រោយពីបានរកឃើញនូវសកម្មភាពដែលបានធ្វើឱ្យបាត់បង់ប្រាក់កាស ឬខូចខាតទ្រព្យសម្បត្តិសាធារណៈ ទោះតម្លៃនៃការបាត់បង់ ឬខូចខាតរួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬខូចខាតបានក្លាយជាបំណុលសាធារណៈក្តី មន្ត្រីសាធារណៈនោះត្រូវសង និងត្រូវបង់ជាសាច់ប្រាក់ចូលថវិការដ្ឋវិញ ។

## ៩. សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ ២០២២ ត្រូវបានគិតគូរ និងរៀបចំឡើងក្នុងបរិការណ៍ដែលកម្ពុជា ក៏ដូចជាពិភពលោកទាំងមូលកំពុងស្ថិតនៅកណ្តាលនៃវិបត្តិជំងឺកូវីដ-១៩ នៅឡើយ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលតម្រង់ការប្រើប្រាស់ធនធានដើម្បី, ម្ខាង, ទ្រទ្រង់ដល់កិច្ចខិតខំប្រយុទ្ធនឹងជំងឺកូវីដ-១៩, ម្ខាងទៀត, ស្តារ និងជំរុញសេដ្ឋកិច្ចឱ្យបន្តស្ថិតនៅលើគន្លងនៃកំណើនខ្ពស់ និងរស់រវើកឡើងវិញ ព្រមទាំងស្តារជីវភាពរបស់ប្រជាជនទូទៅក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ នៃ **កម្មវិធីនយោបាយ, យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣** ពិសេសការជំរុញល្បឿននៃការអនុវត្តកិច្ចការកែទម្រង់លើគ្រប់វិស័យក្នុងឆ្នាំ ២០២២ ដែលជាឆ្នាំទី ៤ នៃអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា សំដៅកសាងមូលដ្ឋានគ្រឹះថ្មីៗបន្ថែម ក្នុងដំណើរឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិ មានអនាគតដ៏រុងរឿងភ្លឺស្វាង ត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ ។

សរុបមក, ថវិកាឆ្នាំ ២០២២ ត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង, ទាំងក្នុង និងក្រៅប្រទេស, សំដៅបន្តការពារអាយុជីវិត លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនពលរដ្ឋ ព្រមទាំងស្តារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជា ទន្ទឹមនឹងការរៀនរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ហើយអាចប្រសិទ្ធនាមបានថាជា "**ថវិកាសម្រាប់បន្តការប្រយុទ្ធប្រឆាំង និងការកសាងសមត្ថភាពរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លង**

ប្រក្រតីថ្មី ដើម្បីបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ" ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ដែលបានលើកឡើងខាងលើ ពិសេសការបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងផ្តល់លទ្ធផលជាក់ស្តែង ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៥ យ៉ាង គឺ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" ។ ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ សូមមេត្តាផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**__កន្លែងទទួល៖__**
- អគ្គលេខាធិការដ្ឋានក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់រាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២
# ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
# សាធារណៈ

# ច្បាប់ស្តីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ព្រះរាជក្រមលេខ: នស/រកម/០៥០៨/០១៦

ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨

# ច្បាប់

## ស្តីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

នស/រកម/០៥០៨/០១៦

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានអនុម័តកាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

នស/រកម/០៥០៨/០១៦

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានអនុម័តកាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

## ស្តីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ មានគោលដៅកំណត់គោលការណ៍ជាមូលដ្ឋានសម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល និង សម្រាប់រៀបចំច្បាប់ហិរញ្ញវត្ថុជាពិសេសសម្រាប់ដំណាក់កាលនីមួយៗនៃដំណើរការរៀបចំ អនុម័ត និង អនុវត្តថវិកា ការត្រួតពិនិត្យលទ្ធផលថវិកា ការកំណត់មុខងារ ការទទួលខុសត្រូវ ព្រមទាំងកម្មវិធាកលើកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលគ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគោរពគោលការណ៍បូរណភាព អាជ្ញាភាព ឯកត្តភាព សមាគតភាព សកលភាព សង្គតិភាព គណនេយ្យភាព តម្លាភាព ស្ថិរភាព ភាពគ្រប់ជ្រុងជ្រោយ និង សមិទ្ធកម្ម ។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះគ្របដណ្តប់ទាំងហិរញ្ញវត្ថុសាធារណៈជាតិ ទាំងទំនាក់ទំនង និង អន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និង ហិរញ្ញវត្ថុឯកជនអន្តរជាតិ ហើយត្រូវធានាការគោរពគោលការណ៍ថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ភាពផ្សាភ្ជាប់គ្នារវាងថវិកា និង គោលនយោបាយ និង គណនេយ្យភាពចំពោះសមិទ្ធកម្ម ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពជាច្បាប់គោល ដែលត្រូវយកធ្វើជាមូលដ្ឋាន និង ត្រូវគោរពអនុវត្តតាម សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

សម្រាប់ប្រើប្រាស់នៅក្នុងច្បាប់នេះ វាក្យស័ព្ទខាងក្រោមមានន័យ ដូចតទៅ :

**ច្បាប់ហិរញ្ញវត្ថុ** សំដៅដល់ច្បាប់ដែលគ្រោងចំណូល និង ចំណាយប្រចាំឆ្នាំរបស់រដ្ឋ បទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងវិស័យហិរញ្ញវត្ថុ និងការទូទាត់ផ្សេងៗ ដែលត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្តមុខងារ កម្មវិធី និង ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង បទប្បញ្ញត្តិស្តីពីវិស័យហិរញ្ញវត្ថុដែលច្បាប់កំណត់ ។

**ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** គ្រោង និង អនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋ ។

**ច្បាប់កែតម្រូវ** សំដៅដល់ច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ច្បាប់ទូទាត់ថវិកា** សំដៅដល់ច្បាប់ត្រួតពិនិត្យ និង វាយតម្លៃលទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល** សំដៅដល់ក្រសួង ស្ថាប័ន ឬ អង្គភាព ដែលទទួលហិរញ្ញប្បទានទាំងស្រុង ឬ មួយផ្នែកនៃថវិកាជាតិ ឬ/ និង ដែលគ្រប់គ្រងទ្រព្យសកម្ម និង បំណុលរបស់រដ្ឋ ឬ/ និង គណនេយ្យ ដែលច្បាប់បង្កើត ព្រមទាំងគ្រប់គ្រងចាត់ចែងសកម្មភាពទាំងឡាយណាដែលនាំឱ្យរដ្ឋជាប់កាតព្វកិច្ចហិរញ្ញវត្ថុ ឬ បំណុលផ្សេងៗ ។

**រយៈពេលមធ្យម** សំដៅដល់រយៈពេលដែលមិនតិចជាង ៣ ឆ្នាំ និង មិនលើសពី ៥ ឆ្នាំ ។

**អាទិភាពគោលនយោបាយ** សំដៅដល់យុទ្ធសាស្ត្រសម្រាប់សម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលឆ្លុះបញ្ចាំងនៅក្នុងផែនការរដ្ឋ ដែលរួមមានគោលនយោបាយជាតិ គោលនយោបាយតាមវិស័យ និង តាមអនុវិស័យ ។

**កម្មវិធី** សំដៅដល់ក្រុមនៃអនុកម្មវិធី ឬ/និង ក្រុមនៃចង្កោមសកម្មភាពដែលមានលក្ខណៈឯករាជ្យ តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយត្រូវបានរៀបចំឡើងដើម្បីរួមចំណែកសម្រេចបាននូវគោលបំណង គោលនយោបាយរួមមួយ និងមានបញ្ជាក់ពីសកម្មភាព

**រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។

**ថវិកា** សំដៅដល់សំណុំនៃគណនីដែលពិពណ៌នាសម្រាប់ឆ្នាំនីមួយៗអំពីធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ឬ របស់ស្ថាប័ន ឬ របស់អង្គភាពណាមួយ ។

**ថវិកាជាតិ ឬ ថវិការដ្ឋ** សំដៅដល់គម្រោងតុល្យភាពនៃធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ។ ថវិកាជាតិ ឬ ថវិការដ្ឋ រួមមានថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ ។ ថវិកាថ្នាក់ជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ជាតិ ។ ថវិកាថ្នាក់ក្រោមជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**អចលកម្មហិរញ្ញវត្ថុ** សំដៅដល់ការវិនិយោគលើមូលបត្រ ឬ មូលបត្រ ដែលបានមកពីការចូលរួមទុនជាមួយសហគ្រាស ឬ ក្រុមហ៊ុន ។ អចលកម្មហិរញ្ញវត្ថុនេះ ជាទ្រព្យសកម្មហិរញ្ញវត្ថុថេរមិនចរន្ត ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាអចលកម្មហិរញ្ញវត្ថុ រួមមានមូលបត្រគ្រប់ប្រភេទទាំងអស់វិញ្ញាបនបត្រខ្ចីប្រាក់ ប័ណ្ណសន្យាប៉ាវរង ផលប័ត្រពាណិជ្ជកម្ម ប័ណ្ណសងតាមបញ្ជារូបិយណត្តិ និង មូលប្បទានបត្រជាដើម ។

**ផលហិរញ្ញវត្ថុ** សំដៅដល់ផលហិរញ្ញវត្ថុទាំងអស់ដែលបានមកដោយការយកអតិរេកសាច់ប្រាក់បណ្តោះអាសន្ន ទៅវិនិយោគលើមូលបត្រអាចជួញដូរបាន និង ក្នុងរយៈពេលខ្លី ។ ផលហិរញ្ញវត្ថុនេះមានជាអាទិ៍ អត្រាការប្រាក់លើបំណុលប្រាក់ចំណេញ ដែលបានមកពីការវិនិយោគក្នុងរយៈពេលមួយយប់លើប័ណ្ណរតនាគារបរទេស ផលដែលបានមកពីការធានាឱ្យមានសំវិធានធន និង កម្រៃផ្សេងទៀត ដែលបានមកពីប្រតិបត្តិការហិរញ្ញវត្ថុ ។

**មាត្រា ៥.-**

ថវិកាត្រូវមានគោលការណ៍គន្លឹះ ១១ យ៉ាង ដែលត្រូវអនុវត្តជាចំខាតគឺ :

១- ភាពជាអាជ្ញា

២- ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ

៣- ភាពគ្រប់ជ្រុងជ្រោយ

៣- ច្បាប់ទូទាត់ថវិកា ។

មាត្រា ៩.-

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ គ្រោង និង អនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាននិង បន្ទុកដែលត្រូវចំណាយសរុបរបស់រដ្ឋ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជ-រដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវន្ត ពិសេសតាមរយៈការធានាឱ្យបាននូវតុល្យភាពថវិកា ។

មាត្រា ១០.-

ក្រៅពីអ្វីដែលមានចែងក្នុងច្បាប់នេះ របបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុនៃច្បាប់ដោយឡែក ។

មាត្រា ១១.-

ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ។

## ជំពូកទី ២

## រចនាសម្ព័ន្ធថវិកា និង សិទ្ធិអំណាច

### ផ្នែកទី ១

### រចនាសម្ព័ន្ធថវិកា

មាត្រា ១២.-

ថវិកាត្រូវរៀបចំ ទៅតាមចំណាត់ថ្នាក់រដ្ឋបាលដែលផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ចំណាត់ថ្នាក់សេដ្ឋកិច្ចដែលផ្អែកទៅលើប្រភេទចំណាយ ចំណាត់ថ្នាក់មុខងារដែលផ្អែកទៅលើ គោលបំណង និង ចំណាត់ថ្នាក់តាមកម្មវិធី ។

ROYAUME DU CAMBODGE · ROYAL · UNITE

មាត្រា ១៣.-

ធនធានអចិន្ត្រៃយ៍របស់រដ្ឋមាន ចំណូលចរន្ត និង ចំណូលមូលធន ។

- ចំណូលចរន្ត ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :
  - ក្រុមទី ១ : ចំណូលពិត
    - ប្រភេទទី ១ : ចំណូលសារពើពន្ធ
    - ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ
  - ក្រុមទី ២ : ចំណូលតាមដីកា
    - ប្រភេទទី ៣ : ចំណូលតាមដីកា
- ចំណូលមូលធន ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :
  - ក្រុមទី ១ : ចំណូលពិត
    - ប្រភេទទី ១ : ចំណូលពីប្រភពផ្ទាល់
    - ប្រភេទទី ២ : ចំណូលពីប្រភពខាងក្រៅ
  - ក្រុមទី ២ : ចំណូលតាមដីកា
    - ប្រភេទទី ៣ : ចំណូលតាមដីកា

ប្រភេទចំណូលនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៤.-

គណនីថវិការួមមាន ថវិការដ្ឋ ថវិកាឧបសម្ព័ន្ធ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និង គណនីពិសេសរតនាគារជាតិ ។ គណនីថវិកាផ្សេងៗទៀត អាចបង្កើតបានក្នុងច្បាប់ហិរញ្ញវត្ថុ ។

ថវិកាឧបសម្ព័ន្ធអនុវត្តចំពោះអង្គភាពរដ្ឋ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ដែលមិនមែនជានីតិបុគ្គល ។ ថវិកាឧបសម្ព័ន្ធ ត្រូវបង្កើត ឬ លុបចោល ដោយច្បាប់ហិរញ្ញវត្ថុ ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធ ត្រូវប្រព្រឹត្តទៅក្នុងលក្ខខណ្ឌ និង តាមវិធានដូចគ្នានឹងកិច្ចប្រតិបត្តិការថវិការដ្ឋដែរ ។

ROYAL ... CAMBODGE

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត ។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមាន ចំណូលផ្ទាល់ និង ជាយថាហេតុ មានការឧបត្ថម្ភ តុល្យភាព ដោយថវិការដ្ឋ ។ រីឯចំណាយជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និង ការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់ថវិការដ្ឋដែរ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃថវិកាឧបសម្ព័ន្ធ និង ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។

មាត្រា ១៥.-

ចំណូលសារពើពន្ធរួមមានចំណូលបានមកពីពន្ធ និង អាករក្នុងប្រទេស និង ពន្ធ និង អាករលើពាណិជ្ជកម្មក្រៅប្រទេស និង ចំណូលសារពើពន្ធដទៃទៀត ។

ចំណូលមិនមែនសារពើពន្ធរួមមានចំណូលបានមកពីការចាត់ចែង ការធ្វើអាជីវកម្មនិង ការលក់ទ្រព្យសម្បត្តិរដ្ឋ ផលបានមកពីសម្បទាន កម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យ និង ការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយ ផលហិរញ្ញវត្ថុ ផលផ្សេងៗ និងផលពិសេស និង ចំណូលមិនមែនសារពើពន្ធដទៃទៀត ។

ចំណូលមូលធនរួមមានចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ ហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ការខ្ចី និង ចំណូលមូលធនផ្សេងទៀត ។

មាត្រា ១៦.-

ពន្ធ អាករ និង ចំណូលសារពើពន្ធផ្សេងៗ ត្រូវកំណត់ដោយច្បាប់ និង ត្រូវប្រមូល និង ត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អត្រាពន្ធ អាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និង វិវាទ ដែលទាក់ទងនឹងការកំណត់ការប្រមូល និង ការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និង តាមបែបបទ ដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និង អាករនីមួយៗ ។

គ្មានបទប្បញ្ញត្តិណាមួយ ទោះជាប្រភេទណាក៏ដោយ គ្មានអនុសញ្ញាអន្តរជាតិណាមួយ ដែលអាចធ្វើឱ្យមានការប្រែប្រួលនាំមកនូវការចាត់ចំណូលនោះឡើយ ។ ករណីខាងលើអាច

ពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ។

មាត្រា ១៩.-

ចំណូលត្រូវកត់ត្រាចូលទាំងស្រុងហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ ។ ការបង្កើនដោយអាណាប័កនូវទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយ ត្រូវបានហាមឃាត់ដាច់ខាត ។

មាត្រា ២០.-

ចំណូលទាំងមូល ត្រូវវិភាជន៍សម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់ ។ ប៉ុន្តែចំណូលខ្លះ អាចត្រូវវិភាជន៍ សម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់ និង ក្រោមលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់ ។

មាត្រា ២១.-

បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមាន ចំណាយចរន្ត និង ចំណាយមូលធន ។ បន្ទុកនេះ ត្រូវបានចែកជាក្រុម និង ប្រភេទ ។

មាត្រា ២២.-

ចំណាយចរន្តនៃថវិកាត្រូវបានបែងចែកជា ២ ក្រុម និង ៦ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត
  - ប្រភេទទី ១ : មធ្យោបាយសេវា
  - ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ
  - ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ
  - ប្រភេទទី ៤ : ចំណាយផ្សេងៗ
- ក្រុមទី ២ : ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក
  - ប្រភេទទី ៥ : ចំណាយតាមដីកា

-ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក

ប្រភេទចំណាយនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២៣.-

ចំណាយមូលធននៃថវិកា គឺសម្រាប់ការអនុវត្តកម្មវិធី ការអនុវត្តគម្រោងវិនិយោគ ការចូលរួមភាគកម្ម និង ការទូទាត់បំណុល ។

ចំណាយមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

- ក្រុមទី ១ : ចំណាយពិត
  - -ប្រភេទទី ១ : ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល
  - -ប្រភេទទី ២ : អចលកម្ម
- ក្រុមទី ២ : ចំណាយតាមដីកា
  - -ប្រភេទទី ៣ : ចំណាយតាមដីកា

ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស គឺជាឥណទានមានលក្ខណៈជាប់ស្ពាន ហើយពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពទៅប្រភេទចំណាយណាមួយផ្សេងទៀតបានឡើយ ។

មាត្រា ២៤.-

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ វិភាជន៍ឥណទានទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវថវិកាឧបសម្ព័ន្ធ និង ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលទៅតាមប្រភេទចំណាយចរន្ត និង ចំណាយមូលធន ។ ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលទាំងនោះ ប្រមូលផ្តុំឥណទានទាំងអស់សម្រាប់បម្រើការងាររបស់ខ្លួននៅរដ្ឋបាលថ្នាក់ជាតិ ។

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជន៍ឥណទានជាកញ្ចប់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME du CAMBODGE
MINISTRE du PALAIS ROYAL

មាត្រា ២៥.–

ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលម្អិតនៅក្នុងផ្នែកក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និង គោលដៅនៃឥណទានថវិកា ។ ឥណទានទាំងនេះ អាចធ្វើជាកម្មវត្ថុសម្រាប់ការរៀបចំថវិកាតាមកម្មវិធី និង ការប្រមូលផ្តុំតាមវិស័យផងដែរ ។ ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ចំណាយចរន្តនៃប្រភេទ ២ "បន្ទុកហិរញ្ញវត្ថុ" និង ប្រភេទ ៦ "ចំណាយមិនបានគ្រោងទុក" មិនត្រូវបានបែងចែកឱ្យទៅក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលណាមួយឡើយ ។ ឥណទាននេះ ទុកសម្រាប់សងការប្រាក់នៃប្រាក់ខ្ចី និង បន្ទុកហិរញ្ញវត្ថុផ្សេងៗ ព្រមទាំងឥណទានត្រៀមបម្រុងសម្រាប់ចំណាយផ្សេងៗលើមុខសញ្ញាដែលកើតឡើងជាយថាហេតុ ។ ឥណទានត្រៀមបម្រុង ត្រូវបានអនុញ្ញាតសម្រាប់ការចំណាយទាំងឡាយណាដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់ នៅពេលដែលឥណទាននោះ ត្រូវបានអនុម័ត ។ ការបែងចែកឥណទានត្រៀមបម្រុងទាំងនេះ តាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រភេទ ១ នៃចំណាយមូលធន គឺសម្រាប់ការទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និង ទូទាត់បំណុលប្រហាក់ប្រហែល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗ ចំណាយសំណង និង ចំណាយបង្វិលសងវិញ ព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និង ទូទាត់បំណុលប្រហាក់ប្រហែល ។

មាត្រា ២៦.–

ឥណទានថវិកាមានពីរប្រភេទគឺ កំហិតកំណត់ និង ប៉ាន់ប្រមាណ ។ ឥណទានកំហិតកំណត់គឺត្រូវបានផ្តល់ជាការសន្យា និង ការអនុញ្ញាតត្រឹមកម្រិតខ្ពស់បំផុតមួយ ដែលចំណាយ

### ១-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែ មីនា ដល់ខែ ឧសភា)

នៅសប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ។

នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលបានកំណត់ដោយរាជរដ្ឋាភិបាល ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និង ផែនការសកម្មភាពជាអាទិភាពរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់វិស័យ និង គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ។ ផែនការយុទ្ធសាស្ត្រថវិកា ទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

### ២-ការរៀបចំគម្រោងថវិកា (ពីខែ មិថុនា ដល់ខែកញ្ញា)

នៅសប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញនិងឯកសារពាក់ព័ន្ធ ដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ហើយផ្ញើជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនូវគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គម្រោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូល ចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ខេត្ត និង រាជធានី ដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលព្រមទាំងអភិបាលគ្រប់ខេត្ត និង រាជធានី មកពិភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូល ចំណាយថវិកាទាំងនោះឱ្យបានសមស្របតាមបទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និងបង្កើនចំណូលឱ្យបានសមស្រប ។

នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញរួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

### ៣ -ការអនុម័តថវិកា (ពីខែ តុលា ដល់ខែ ធ្នូ)

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេចរួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត-និង ដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទីមួយនៃខែធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

មាត្រា ៤៥.-

ចំណាយមូលធន ត្រូវផ្អែកលើកម្មវិធី ឬ គម្រោងដោយឡែកៗ ដែលមានការយល់ព្រមជាមុន និង ដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបាននូវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ កម្មវិធី ឬ គម្រោងទាំងអស់នោះគឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយមូលធនសរុបរបស់កម្មវិធី និង គម្រោង និង សម្រាប់កំណត់រយៈពេលនៃការសន្យា និង ការទូទាត់សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ ។

មាត្រា ៤៦.-

ដើម្បីគោរពតាមប្រតិទិននៃមាត្រា ៣៩ នៃច្បាប់នេះ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិក្នុងការគ្រោងចំណូលចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនបានលើកគម្រោងចំណូល ចំណាយរបស់ខ្លួនតាមកាលកំណត់ ដោយផ្អែកលើលទ្ធផលនៃឆ្នាំកំពុងអនុវត្ត ។

មាត្រា ៤៧.-

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវ :

១-របាយការណ៍វិភាគពីនិន្នាការ និង ការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និង ការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្ត ពិសេសតុល្យភាពថវិកា ។

២-របាយការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងនិន្នាការចំណាយចរន្តដោយវិភាគ និង បង្ហាញពីស្ថានភាពឥណទានពាក់ព័ន្ធនឹងការអនុម័តឆ្នាំមុនទៅនឹងតម្រូវការ និង វិធានការថ្មី ដែលមានសារសំខាន់ចាំបាច់សម្រាប់ការគ្រប់គ្រងថ្មី ។

៣-កម្រងកម្មវិធី និង គម្រោងចំណាយមូលធន ដែលរំលេចនូវឥណទានវិនិយោគឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់សម្រាប់កម្មវិធី និង គម្រោងក្នុងឆ្នាំ ការគ្រោងរួមឥណទានដែលមានប្រភេទដូចគ្នាចាំបាច់សម្រាប់បន្តកម្មវិធី និង គម្រោងទាំងនេះ និង



ការវិភាគកម្មវិធី និង គម្រោងថ្មី ព្រមទាំងតម្រូវការឥណទានសម្រាប់កម្មវិធី និង គម្រោងថ្មីទាំងនេះ ដោយកំណត់តាមប្រតិទិនប្រើប្រាស់ដែលបានគ្រោងទុក ។

៤-ឯកសារពាក់ព័ន្ធផ្សេងៗទៀតដែលចាំបាច់សម្រាប់ជាព័ត៌មាន និង សម្រាប់ការត្រួតពិនិត្យរបស់រដ្ឋសភា និង ព្រឹទ្ធសភា ។

មាត្រា ៤៨.-

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ចែកចេញជាពីរផ្នែក :

ផ្នែកទី ១ សេចក្តីព្រាងច្បាប់អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានសាធារណៈ និង កំណត់ធនធានទាំងនោះ ជាទឹកប្រាក់សរុប ។ សេចក្តីព្រាងច្បាប់ត្រូវកំណត់ទិសដៅ និង មធ្យោបាយអនុវត្តចំពោះចំណាយមូលធន ។ សេចក្តីព្រាងច្បាប់បានកំណត់នូវឥណទានត្រូវផ្តល់ខ្ពស់បំផុត ដែលជាគុណប្រយោជន៍ដល់ថវិការដ្ឋ និង គណនីពិសេសរបស់រតនាគារជាតិ ។ សេចក្តីព្រាងច្បាប់រួមមានបទប្បញ្ញត្តិទាំងឡាយ ដែលទាក់ទងដល់ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលមូលធន និង ទាក់ទងដល់គ្រប់បទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត ។

ផ្នែកទី ២ រួមមានតារាងបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ដែលទាក់ទងដល់ចំណូលនៃថវិការដ្ឋ ។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយចរន្តរបស់ថវិការដ្ឋ បែងចែកទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ហើយបែងចែកទៅតាមប្រភេទចំណាយ ដែលត្រូវអនុម័ត ។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយមូលធន បែងចែកទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល និង ជាជំពូកដែលចែកចេញជា ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ សេចក្តីព្រាងច្បាប់ត្រូវកំណត់បញ្ជីគណនីពិសេសរបស់រតនាគារជាតិ ដែលមានលក្ខណៈរដ្ឋបាល និង កំណត់គណនីពិសេសនីមួយៗនូវចំនួនទឹកប្រាក់ចំណូល និង ចំនួនទឹកប្រាក់ចំណាយ ។

មាត្រា ៤៩.-

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវអនុម័តដោយរដ្ឋសភា និង ពិនិត្យដោយព្រឹទ្ធសភា និង ត្រូវ

ROYAUME DU CAMBODGE
ព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើដោយព្រះរាជក្រម ហើយត្រូវចេះផ្សាយឱ្យអនុវត្តជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥០.-

ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែមករានៃឆ្នាំការិយបរិច្ឆេទនោះ ថវិកាឆ្នាំមុនត្រូវបានបន្តដោយស្របច្បាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម :

១-ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និង ចំណូលគ្រប់ប្រភេទផ្សេងទៀតត្រូវបានអនុញ្ញាត និង បន្តឱ្យប្រមូលក្នុងលក្ខខណ្ឌ និង តាមបែបបទដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និង ក្នុងក្របខ័ណ្ឌច្បាប់ ព្រមទាំងបទបញ្ញាដែលមានជាធរមាន

២-ចំណាយចរន្ត ក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ដោយគិតតាមវិធីមួយភាគដប់ពីរជាបណ្តោះអាសន្នក្នុងខែនីមួយៗ រហូតដល់ថវិកាថ្មីត្រូវបានអនុម័ត

៣-ចំណាយមូលធននៃថវិកាក្រៅពីរំលស់បំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ក្នុងក្របខ័ណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយអាចលើសពីនេះប្រសិនបើចាំបាច់ ដោយមិនឱ្យការទូទាត់នោះលើសពីកម្រិតឥណទានភ្ជាប់សន្យាដែលបានអនុម័តក្នុងថវិកាឆ្នាំមុន ។

៤-ចំណាយទាំងឡាយ ដែលជាកាតព្វកិច្ចទាក់ទងទៅនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិ និង អន្តររដ្ឋាភិបាល និង កាតព្វកិច្ចទាក់ទងទៅនឹងបន្ទុកបំណុលសាធារណៈរួមមានការរំលស់ប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ឬ ការបង់ពិន័យជាយថាហេតុ ត្រូវបានកំបាំងជាបន្តមិនឱ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន ។

—

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

**មាត្រា ៦៥.-**

ចំណាយថវិការដ្ឋរួមទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ និង ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងគណនីពិសេសរបស់រតនាគារជាតិក្នុងការទិញ ការផ្គត់ផ្គង់ ការសាងសង់ និង ការផ្តល់សេវា ត្រូវអនុវត្តតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវបានកំណត់ដោយច្បាប់ និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

## ផ្នែកទី ៣

## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៦៦.-**

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលព្រមទាំងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិការបស់ខ្លួន ។ ចំពោះការប្រមូលចំណូល និង ការអនុវត្តចំណាយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួនដែលច្បាប់បានកំណត់ ។

**មាត្រា ៦៧.-**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និង ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រីមានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមួយគត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា និង ការសន្សាផ្នែកហិរញ្ញវត្ថុនានា និង មានសិទ្ធិ ក្នុងការឱ្យប្រាក់គេខ្ចីទាំងក្នុង និងក្រៅប្រទេស ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ មន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬ ឱ្យប្រាក់គេខ្ចី ឬ ចេញជាលិខិតធានា ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀតដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុលឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបាន

ផ្ទុ

មាត្រា ៦៨.-

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និង ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេ ឬ បំណុលដែលគេជំពាក់រដ្ឋ ។ ការរៀបចំកម្មវិធីដោះស្រាយបំណុល ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

មាត្រា ៦៩.-

លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និង ទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេនៃការឱ្យប្រាក់គេខ្ចីនៃការបោះផ្សាយមូលបត្ររដ្ឋ នៃការធានា និង នៃការសន្យាផ្នែកហិរញ្ញវត្ថុនានា ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

មាត្រា ៧០.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈ និង ណែនាំក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ។ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ស្ថាប័នថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និង សហគ្រាសសាធារណៈ ត្រូវគោរពតាមច្បាប់ អនុក្រឹត្យ ប្រកាស និង សេចក្តីណែនាំទាំងឡាយស្តីពីលទ្ធកម្មសាធារណៈ ។

## ជំពូកទី ៥

## គណនេយ្យ និង ការត្រួតពិនិត្យលទ្ធផល

### ផ្នែកទី ១

### ក្របខ័ណ្ឌគណនេយ្យ និង ការទូទាត់ថវិកា

មាត្រា ៧១.-

គោរពតាមគោលការណ៍គណនេយ្យភាព រដ្ឋមន្ត្រី ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចរៀបចំ និង

ផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវរបាយការណ៍ស្តីពីការអនុវត្តថវិកា របាយការណ៍ស្តីពីការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់គេ ការបោះផ្សាយមូលបត្ររដ្ឋ ការធានា និង ការសន្យានានាផ្នែកហិរញ្ញវត្ថុ ការទទួលហិរញ្ញប្បទានឥតសំណង និង ដែលពាក់ព័ន្ធនឹងចំណូលមានប្រភពមកពីការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ និង ព័ត៌មានចាំបាច់ផ្សេងៗទៀតតាមតម្រូវការរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចកំណត់កាលបរិច្ឆេទនៃការផ្តល់និងគំរូនៃរបាយការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌខាងលើនៃមាត្រានេះ ដើម្បីជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត ។

មាត្រា ៧២.-

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌ និង គ្រប់គ្រងកិច្ចប្រតិបត្តិការការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាភាពត្រឹមត្រូវ និង ស្របតាមបទដ្ឋាន បទប្បញ្ញត្តិ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។

ដោយឡែក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការណែនាំអំពីការរៀបចំក្របខ័ណ្ឌ កិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

មាត្រា ៧៣.-

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យសាធារណៈទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រមូលផ្តុំនៅរតនាគារជាតិ និង អនុវត្តដោយគណនេយ្យករសាធារណៈ ។

មាត្រា ៧៤.-

ប្រព័ន្ធគណនេយ្យសាធារណៈ ត្រូវមានសង្គតិភាពទៅនឹងនិយាមគណនេយ្យអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ប្រព័ន្ធគណនេយ្យនេះ ។

មាត្រា ៧៥.-

បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់គ្រប់លក្ខខណ្ឌ ដែលធ្វើឱ្យប្រតិបត្តិការគណនេយ្យ និង ហិរញ្ញវត្ថុ អាចកត់ត្រា វិភាគ និង គ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រកបដោយគណនេយ្យភាព ភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព ។

មាត្រា ៧៦.-

ការទូទាត់ថវិកា គឺជាកម្មវត្ថុនៃច្បាប់ ។

មាត្រា ៧៧.-

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ពិនិត្យកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលក្នុងគណនីទោលរបស់រតនាគារជាតិ និង អាណាប័ណ្ណចំណាយដែលបានប្រព្រឹត្តនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា ។ សេចក្តីព្រាងច្បាប់នេះទុកជាមោឃៈនូវឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងឱ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុង "គណនីលទ្ធផល" របស់រតនាគារជាតិ ។

មាត្រា ៧៨.-

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទៅតាមមាតិកាថវិកានីមួយៗ ដោយផ្អែកលើទិន្នន័យចំណូល ចំណាយ ដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយអាណាប័កពាក់ព័ន្ធ ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

ស្តីពីស្ថានភាពនៃការសម្រេចបាននូវតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ។

៣-តារាងតុល្យការរបស់រាជរដ្ឋាភិបាល ។

ក្រោយពីបានប្រកាសឱ្យប្រើច្បាប់ទូទាត់ថវិកា ត្រូវបោះផ្សាយដូចគ្នានឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។

## ផ្នែកទី ២

## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៨២.-**

គណនេយ្យករសាធារណៈ ទទួលបន្ទុកប្រមូលចំណូល ទូទាត់ចំណាយ រក្សាទុកដាក់មូលនិធិមូលបត្រ ផលិតផល និង សម្ភារៈដែលជាកម្មសិទ្ធិរបស់ស្ថាប័នសាធារណៈ ។ មានតែគណនេយ្យករសាធារណៈមួយគត់ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តប្រតិបត្តិការទាំងឡាយ និង ដោះស្រាយបញ្ហាមូលនិធិពាក់ព័ន្ធដទៃទៀតជាមួយចំណូល និង ចំណាយ ។

ក្នុងសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈ មានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និង ជាប្រាក់កាស ។

**មាត្រា ៨៣.-**

គណនេយ្យករសាធារណៈ ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ គណនេយ្យករសាធារណៈមានអំណាចពិសេសរបស់ខ្លួន ។ មុនចូលកាន់តំណែង គណនេយ្យករសាធារណៈ ត្រូវតែធ្វើសច្ចាប្រណិធានជាផ្លូវការតាមបែបបទត្រឹមត្រូវនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ។ អាណាប័កដើមខ្សែ និង អាណាប័កផ្ទេរសិទ្ធិព្រមទាំងគណនេយ្យករសាធារណៈដទៃទៀត ត្រូវទទួលស្គាល់គណនេយ្យករសាធារណៈ ដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៩៤.-**

រាល់ការអនុវត្តចំណូល និង ចំណាយនៃថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញត្តិ និង សេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រាល់ការកត់ត្រា ចំណូល និង ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមប្លង់គណនេយ្យ និង មាតិកាថវិកា ហើយរាល់របាយការណ៍គណនេយ្យ និង ហិរញ្ញវត្ថុ ត្រូវមានតម្លាភាព និង ផ្សព្វផ្សាយជាសាធារណៈ ។

រាល់ប្រតិបត្តិការហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាន និង ទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំទូទាត់ថវិកាប្រចាំឆ្នាំ ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ៩៥.-**

មន្ត្រីសាធារណៈគ្រប់ប្រភេទ និង គ្រប់ឋានៈ ដែលបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និង ភារកិច្ចរបស់ខ្លួន ដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និង ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។ ក្នុងករណីកំហុសរបស់មន្ត្រីសាធារណៈនោះ បានធ្វើឱ្យមានការបាត់បង់ប្រាក់កាស ឬ ខូចខាតទ្រព្យសម្បត្តិសាធារណៈ នោះតម្លៃនៃការបាត់បង់ ឬ ការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬ ខូចខាតនេះ នឹងក្លាយជាបំណុលចំពោះមន្ត្រីសាធារណៈនោះដែលត្រូវសង និង បង់ចូលថវិការដ្ឋវិញ ។